ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ អធិបតេយ្យភាពរបស់កម្ពុជាកំពុងប្រឈមនឹងហានិភ័យ ប៉ុន្តែមិនមែនដោយសារតែជម្លោះព្រំដែនបច្ចុប្បន្ននេះទេ

◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាខាលវែង ចុះសួរសុខទុក្ខ និងផ្តល់អំណោយដល់ជនភៀសសឹកកម្ពុជាពីការឈ្លានពានរបស់ថៃនៅឃុំប្រម៉ោយ ស្រុកខាលវែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣០៧ ខែកក្កដា ឆ្នាំ២០២៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



បំណែកគ្រាប់នៅសេសសល់ បន្ទាប់ពីកងទ័ពថៃវាយប្រហារទៅលើប្រាសាទព្រះវិហារ ក្នុងទឹកដីប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨។ (ប្រភពរូបថត៖ ទូរទស្សន៍អនឡាញ ព័ត៌មានប្រជាជនកម្ពុជា)

## មាតិកា

### សំបុត្រ


◆ អធិបតេយ្យភាពរបស់កម្ពុជាកំពុងប្រឈមនឹងហានិភ័យ ប៉ុន្តែមិនមែនដោយសារតែជម្លោះ ......១


### ផ្នែកឯកសារ


◆ ឈី ហួយ ហៅ ខៃ ប្រធានបច្ចេកទេសពេទ្យ ..... ៤

◆ សោម យនះ ប្រែក្លាយបដិវត្តន៍.................... ៨


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ សាខាកាកបាទក្រហមកម្ពុជា ខេត្តស្ទឹងត្រែង និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ............១០

◆ រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ និងអង្គការសកម្មភាពកំចាត់មីនដប៉ុន........................១២

◆ ការផ្សាភ្ជាប់រវាងសត្វដំរី និងជនជាតិដើម ...... ១៤

◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សារវាលវែង ចុះសួរសុខទុក្ខ និងផ្ដល់អំណោយដល់ ..................១៧

◆ ជនជាតិចាមនៅភូមិស្វាភ្នំក្នុងរបបខ្មែរក្រហម .. ២០

◆ អដ្ឋិធាតុជួបជុំជាមួយក្រុមគ្រួសារ............... ២២

◆ និស្សិតសាកលវិទ្យាល័យ Wisconsin-Madison នៅព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ ...................... ២៥

◆ ពិធីបេះផ្លែក្រវាញរបស់ជនជាតិដើម ...........២៧

◆ មជ្ឈមណ្ឌលចងចាំសហគមន៍..................... ៣១

◆ ហោអដ្ឋិធាតុវត្តលង្កា ប្រគល់អដ្ឋិធាតុជូនក្រុម .. ៣៦

◆ សិស្សមកពីអង្គការដើម្បីភាពញញឹមនៃ....... ៣៨

◆ សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្ដុលផ្សារ.... ៤១

◆ សិស្សអនុវិទ្យាល័យ លំទង មកអានឯកសារ.. ៤៣

◆ ទីតាំងឧក្រិដ្ឋកម្មពាកន្លែងត្រូវដាក់បញ្ចូលក្នុង ... ៤៦

◆ អ្នកភូមិកោះញ៉ោ ទទួលបានសេវាសុខភាព និងសង្គមតាមរយៈការធ្វើដំណើរដោយទូកចម្លង.......... ៥១


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ .. ៥៤

◆ មជ្ឈមណ្ឌលផ្សះផ្សារវាលវែង រៀបចំកិច្ច.... ៥៧

◆ វេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលខេត្ត និងសមាគមអង្គការសង្គមស៊ីវិល ប្រចាំខេត្តកំពង់ចាម ...... ៦១

◆ វេទិកាស្រាវជ្រាវស្ដីពី «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នក.......... ៦៣


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ ដំណឹងស្វែងរកប្អូនស្រីដែលបាត់ខ្លួន.............៦៨



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧ ៥៣.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្មេរលេខនេះ ៖** ឆាំង យុ, លី សុខឃាង, ស្រេង លីដា, សូ ហ្សារីណា, ឡុង ដានី, ឈុំ រ៉ា, ស្រ៊ាង លីហួរ, សូ ហ្សារីណា, រស់ សំពៅ, វី ស៊ីថា, សួត វិចិត្រ, អេង សុខម៉េង, ស៊ាង ចិន្តា, មឿន ស្រីណុច, ទូច វណ្ណេត និង អាណា ម៉ា

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ុកីង និង ដ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដា៉វរដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# អធិបតេយ្យភាពរបស់កម្ពុជាកំពុងប្រឈមនឹងហានិភ័យ ប៉ុន្តែមិនមែនដោយសារតែជម្លោះព្រំដែនបច្ចុប្បន្ននេះទេ

ឆាំង យុ



ប្រាសាទតាមាន់ធំ នៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្ដរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការប៉ះទង្គិចគ្នាថ្មីៗនេះនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ បានធ្វើឱ្យជម្លោះដ៏រ៉ាំរ៉ៃមួយជុំវិញបញ្ហាព្រំដែនកម្ពុជាផ្ទុះឡើងវិញ ក៏ប៉ុន្តែទោះបីជាព្រឹត្តិការណ៍នេះបង្កជាសោកនាកម្ម និងភាពចម្រូងចម្រាស យ៉ាងណាក្ដី ជាពិសេសករណីនៃការស្លាប់របស់យុទ្ធជនកម្ពុជាម្នាក់ដែលជាក់ស្ដែងអាចបញ្ចៀសបាន គឺសុទ្ធតែមិនមែនជាបញ្ហាប្រឈមចំពោះអធិបតេយ្យភាពរបស់កម្ពុជា ដែលយើងគួរភ័យខ្លាចនោះឡើយ។

អធិបតេយ្យភាពរបស់កម្ពុជា គឺធំធេងណាស់លើសពីការប៉ះទង្គិច និងជម្លោះព្រំដែនទ្រង់ទ្រាយតូចជាមួយប្រទេសជិតខាង។ ប្រជាជនកម្ពុជាគួរមានមោទកភាព និងទំនុកចិត្តកាន់តែខ្លាំងឡើង ចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលបានអនុវត្តសកម្មភាពប្រកបដោយវិន័យវិជ្ជាជីវៈ និងយុទ្ធសាស្ត្រការទូតក្នុងការដោះស្រាយជម្លោះតាមវិធីសាស្ត្រដ៏ល្អប្រសើរបំផុតឆ្ពោះទៅសន្តិភាព ព្រមទាំងអាចរក្សាបាននូវ



អតីតឯកអគ្គរាជទូតថៃ និងប្រតិភូការងាររបស់លោក បានធ្វើទស្សនកិច្ចមកកាន់ព្រះរាជបណ្ណាល័យ ហូងម៉ែ និងទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងរាជធានីភ្នំពេញ។ ខែកក្កដា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




គម្រោងប្រវត្តិសាស្ត្រភូមិនិងប្រវត្តិសាស្ត្រយោធារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនត្រឹមតែផ្តល់ជាឱកាសដល់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រនៅមូលដ្ឋាន និងទាហាន ក្នុងការស្វែងយល់ និងស្រាវជ្រាវអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម នៅក្នុងសហគមន៍របស់ខ្លួន ឬនៅសមរភូមិ ប៉ុណ្ណោះទេប៉ុន្តែថែមទាំងពង្រីកការស្រាវជ្រាវដោយផ្តោតទៅលើការការពារ និងការអភិរក្សបេតិកភណ្ឌវប្បធម៌នៅក្នុងប្រទេសកម្ពុជាថែមទៀតផង។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (រួមមាន ផាត សិលា, អ៊ិន វណ្ណារ៉ា, ស៊ាង ចិន្តា, មីន សាណាស់ និង ដេង ពង្សរ៉ាស៊ី) បានសហការជាមួយនឹងសហការីផ្នែកច្បាប់ មកពីសាកលវិទ្យាល័យ ធូលេន និងសាលាច្បាប់នៃសាកលវិទ្យាល័យ ចចតោរ។ ខែមិថុនា ឆ្នាំ២០១៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សេចក្តីថ្លៃថ្នូររបស់កម្ពុជា។ នេះគឺជាពេលវេលាមួយសម្រាប់មោទកភាពជាតិ និងការរួបរួមជាតិ។

អធិបតេយ្យភាពរបស់ប្រជាជាតិខ្មែរ បានលាតសន្ធឹងមកអស់រយៈកាលជាច្រើនសតវត្សរ៍ ហើយប្រជាជនខ្មែរបានរក្សាពង្សាវតាររបស់ខ្លួនបានជាច្រើនជំនាន់អស់រយៈកាលរាប់ពាន់ឆ្នាំមកហើយ។ ហេតុនេះបញ្ហាប្រឈមចំពោះអធិបតេយ្យភាពនៃប្រទេសរបស់យើង គួរតែត្រូវវិភាគដោយគិតគូរពីប្រវត្តិសាស្ត្រនេះ។ ទន្ទឹមនឹងនេះដែរ អធិបតេយ្យភាពរបស់ប្រជាជាតិមួយ គឺមិនមែនសំដៅតែទៅលើការការពារព្រំដែនទេ។ ផ្ទុយទៅវិញ នៅក្នុងសង្គមទំនើប អធិបតេយ្យភាពគឺជាការគួចត្របាញ់បញ្ចូលគ្នានូវការប្តេជ្ញាចិត្ត និងធនធានជាយុទ្ធសាស្ត្រពីសំណាក់ពលរដ្ឋ, យោធា, ស្ថាប័នសង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងការការពារជាតិ។

អធិបតេយ្យភាពរបស់កម្ពុជា គឺជាសមិទ្ធផលពីការគិតគូររបស់សង្គមទាំងមូល ដែលលើសពីស្ថានការណ៍, បញ្ហា និងការប្តេជ្ញាចិត្តជាក់លាក់ចំពោះវិបត្តិបច្ចុប្បន្នជាមួយប្រទេសថៃ។

អធិបតេយ្យភាពរបស់កម្ពុជាកំពុងប្រឈមនឹងហានិភ័យ ប៉ុន្តែមិនមែនដោយសារតែជម្លោះព្រំដែនបច្ចុប្បន្ននេះទេ។

ផ្ទុយទៅវិញ អធិបតេយ្យភាពរបស់យើង កំពុងប្រឈមនឹងហានិភ័យ ក្នុងនិន្នាការរយៈពេលវែង (គឺក្នុងរយៈកាលរយឆ្នាំទៅមុខ) ដោយកើតមានលើប្រទេសជាច្រើនដែលមានសន្ទុះនៃការអភិវឌ្ឍន៍លឿនគួរជាទីកត់សម្គាល់។ សន្ទុះនៃការអភិវឌ្ឍន៍លឿនគួរជាទីកត់សម្គាល់ អាចផ្តល់ជាអារម្មណ៍ស្រណុកសុខស្រួល និងទំនុកចិត្ត ក៏ប៉ុន្តែយើងមិនត្រូវបាត់បង់ការផ្តោតអារម្មណ៍ ថាមពល ឬការប្តេជ្ញាចិត្តចំពោះបញ្ហាដែលមិនទាន់ដោះស្រាយនៅថ្ងៃនេះ និងបញ្ហាប្រឈមនៅថ្ងៃស្អែកនោះទេ។

អធិបតេយ្យភាពរបស់កម្ពុជា ត្រូវបានគំរាមកំហែងដោយនិន្នាការផ្ទៃក្នុងដែលមិនអាចមើលឃើញ និងកៀរគរបន្តិចម្តងៗ ចេញពីបញ្ហាតូចតាច, ភាពខ្ជិលច្រអូស, ភាពព្រងើយកន្តើយ និងភាពល្ងង់ខ្លៅ ដែលកើតឡើងនៅពេលដែលប្រជាជនបានឃ្លាតចាកឆ្ងាយពីអតីតកាលដ៏សោកសង្រេង។ បញ្ហាប្រឈមសម្រាប់អនាគត នឹងមិនបង្អែបង្អង់ចំពោះប្រជាជនកម្ពុជានោះទេ ហើយបញ្ហាទាំងនោះ គឺជាការគំរាមកំហែងដ៏គ្រោះថ្នាក់ចំពោះអធិបតេយ្យភាពរបស់យើង ជាងបញ្ហាព្រំដែនទៅទៀត។ យើងកំពុងស្ថិតនៅដំណាក់កាលនៃការផ្លាស់ប្តូរដ៏សម្បើមមួយ។ យើងមិនត្រូវព្រងើយកន្តើយ ចំពោះការរំលោភបំពានព្រំដែននោះទេ ប៉ុន្តែយើងមិនគួរជាប់ជំពាក់ជាមួយនឹងបញ្ហានេះ ហើយភ្លេចអំពីការវិវត្តឥតឈប់ឈរ ដែលកំពុងកើតមាននៅក្នុងតំបន់ លើសកលលោក និងនៅក្នុងជំនាន់នេះឡើយ។ ប្រជាជនកម្ពុជា ត្រូវខិតខំប្រឹងប្រែងឱ្យស្វាហាប់ជាងមុន ឈ្លាសវៃជាងមុន និងឱ្យមានប្រសិទ្ធភាពជាងមុន ប្រសិនបើយើងមិនមែនចង់បានត្រឹមតែការអាចរស់រានមានជីវិត ក៏ប៉ុន្តែសម្រេចបាននូវការរីកចម្រើនទៅមុខនៅក្នុងតំបន់និងពិភពលោក។ កម្ពុជា គួរប្រើប្រាស់ឱកាសនៃការឈ្លានពានដោយប្រទេសថៃ (និងការរំលោភបំពានពីមុនៗ) នេះគឺមិនមែនដើម្បីបង្ហាញអារម្មណ៍ ក៏ប៉ុន្តែជាកម្លាំងជំរុញសមហេតុសមផលក្នុងការអនុវត្តសកម្មភាព និងការវិនិយោគជាយុទ្ធ-សាស្ត្រ ប្រកបដោយការយល់ដឹង ដែលនឹងធានានូវអធិបតេយ្យភាពរបស់កម្ពុជាសម្រាប់អនាគត។



ផ្លូវឡើងទៅប្រាសាទតាមាន់ធំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រោងប្រជុំតាហានជួរមុខនៅប្រាសាទតាមាន់ធំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈី ហួយ ហៅ ខៃ ប្រធានបច្ចេកទេសពេទ្យ តំបន់៥ ភូមិភាគពាយ័ព្យ

*មីន សាណាស់*




*ពេទ្យបុរាណក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ឈី ហួយ ហៅ ខៃ កើតនៅភូមិព្រះវិយា (បច្ចុប្បន្នភូមិទៃយា) ឃុំផ្អក ស្រុកមានជ័យថ្មី (បច្ចុប្បន្នស្រុកស្វាយជ្រំ) ខេត្តស្វាយរៀង។ នៅក្នុងកំណត់ហេតុចម្លើយសារភាពរបស់ ខៃ ឯកសារលេខ J០០៦១៥ មិនបានបង្ហាញពីប្រវត្តិរូបផ្ទាល់ខ្លួន ឪពុកម្តាយ និងក្រុមគ្រួសារច្បាស់លាស់ឡើយ។ ក្នុងឆ្នាំ១៩៦២ ខៃបានចូលរៀននៅសាលាបឋមសិក្សាកំពង់រាប ខេត្តស្វាយរៀង។ ដល់ឆ្នាំ១៩៦៤ ឪពុក ខៃ បានមកយក ខៃ ឱ្យទៅរស់នៅភូមិប៉ាហ៊ីថ្មី ខេត្តប៉ៃលិន។ បន្ទាប់ពីបានទៅរស់នៅភូមិប៉ាហ៊ីថ្មី ខៃក៏បានចូលរៀននៅសាលាចិនឈ្មោះ អ៊ីហួ។ ខៃរៀនសូត្រនៅសាលាចិនបានមួយរយៈ ក៏បានស្គាល់ និងទទួលការអប់រំមនោសញ្ចេតនាបែបរាប់អាន ដូចជាផ្តល់ជាសម្ភារប្រើប្រាស់ពីឈ្មោះ ម៉ាប់ អតីតទាហានស័ក្តិ១ និងឈ្មោះ លីម ឃីមហួ អតីតទាហានស័ក្តិ៥។ នៅពាក់កណ្តាលឆ្នាំ១៩៦៤ ខៃ រួមទាំងឈ្មោះ បាប់ សេង, ឡាក់ ហួ និង ប៉ាង់ សង បានចូលគោរពទង់ សេ-អ៊ី-អា តាមរយៈឈ្មោះ ម៉ាប់ ជាអ្នក*

ខុទ្ទេសនាម និង ឈ្មោះ លីម ឃីមហួ ជាអ្នកទទួលស្គាល់។ ក្រោយពីពិធីបញ្ចូលជា សេ-អ៊ី-អា ខៃ បានឡើងប្តេជ្ញាចិត្ត ខិតខំបម្រើក្រុម សេ-អ៊ី-អា នេះជារៀងរហូត ព្រមទាំងការទទួលភារកិច្ច ដើរតាមដានអ្នកធ្វើការឱ្យកម្លាំងខ្មែរក្រហមនៅតំបន់ប៉ៃលិន ដោយចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍។ បើសិនជាមានព័ត៌មានអ្វីមួយ គឺត្រូវយកមករាយការណ៍ជូនឈ្មោះ ម៉ាប់ និង លីម ឃីមហួ។

នៅខែមេសា ឆ្នាំ១៩៧០ ម៉ាប់ និង លីម ឃីមហួ បានខុទ្ទេសនាម ខៃ ឱ្យទាក់ទងជាមួយឈ្មោះ សាន រស់នៅក្នុងតំបន់ព្រៃខៀវ ដើម្បីបង្កប់ខ្លួនតាមដានស្វែងរកកម្លាំងខ្មែរក្រហម បន្ទាប់មក ខៃ បានមករស់នៅជាមួយ សាន។ ខៃ រស់នៅជាមួយ សាន បានមួយរយៈ ក៏នៅខែសីហា ឆ្នាំ១៩៧០ សាន បានចាត់តាំង ខៃឱ្យទៅរស់នៅជាឈ្មោះ ហម បន្ត។ ហម បាននាំ ខៃ ដើរធ្វើសកម្មភាពទាក់ទងតាមផ្ទះប្រជាជនក្នុងភូមិ កុំឱ្យជឿលើអង្គការ។ ខែតុលា ឆ្នាំ១៩៧០ ហម ក៏ផ្លាស់ទៅរៀនពេទ្យនៅភូមិឆាំងមាន់ ខេត្តបាត់ដំបង។ ដល់ខែវិច្ឆិកា ឆ្នាំ១៩៧០ អង្គការក៏ផ្លាស់ ខៃ ឱ្យមកនៅអង្គភាព១០៨ ជាមួយឈ្មោះ ធន ជាស្នងការវរសេនាតូច។ ខៃ រស់នៅជាមួយ ធន ក៏បានធ្វើសកម្មភាពទាក់ទងជាមួយឈ្មោះ គង់ ជាប្រធានកងតូច, ឈ្មោះ ខន ប្រធានក្រុម, ឈ្មោះ តិម ប្រធានកងតូច, ឈ្មោះ ឈានបច្ចេកទេសយោធា១០៨ និង ឈ្មោះ សយ មានតួនាទីជានីរសារ។ ក្នុងទំនាក់ទំនងជាមួយអ្នកទាំងអស់នេះគឺ ខៃ បានលើកផែនការឱ្យធ្វើការទាក់ទងទៅ ទាហាននៅបន្ទាយត្រែង (ឃុំបន្សាយត្រែង ស្រុកថ្មគោល ខេត្តបាត់ដំបង)។ ឈ្មោះ សយ ត្រូវទៅ ទាក់ទងឈ្មោះ ម៉ែ នៅភូមិស្វាយសរ ដើម្បីឱ្យទាហាន លន់ នល់ វាយបុកទៅ ខាងអូរតាគី ដែលជាកន្លែងយុវជនរបស់អង្គការសម្រាក។ ខណៈពេលនោះធ្វើឱ្យស្លាប់ឈ្មោះ កុយ ក្នុងខែឧសភា ឆ្នាំ១៩៧១។

ខែមិថុនា ឆ្នាំ១៩៧១ ខៃ បានទៅសម្រាកនៅទីតាំងព្រៃធំ ដើម្បីត្រៀមខ្លួនចូលមកវាយនៅបន្ទាយឃ្លាំង។ នៅពេលនោះ ខៃបានទាក់ទងជាមួយឈ្មោះ ឃន មានតួនាទីជាប្រធានកងតូច និង ជីន ជាយុវជនក្នុងការលើកផែនការឱ្យទៅ ទាក់ទង ទាហាននៅបន្ទាយឃ្លាំងឈ្មោះ ចយ ឱ្យត្រៀមកម្លាំង ព្រោះកងទ័ពខ្មែរក្រហមជិតវាយចូលទៅហើយ។ នៅពេលនោះ កងទ័ពខ្មែរក្រហមបានវាយបំបែកបន្ទាយឃ្លាំងមិនបានសម្រេច និងធ្វើឱ្យមានកម្លាំងជាច្រើនរងរបួស និងស្លាប់ចំនួន៧ នាក់។ ក្រោយមកទៀត ខៃ បានកសាងកម្លាំងបន្ថែមម្នាក់ឈ្មោះ កង មានតួនាទីជាប្រធានកងតូច១០៨។ ខែតុលា ឆ្នាំ១៩៧១ អង្គការក៏ដក ខៃឱ្យមកនៅជាមួយ ហម វិញ ហើយ ហម ក៏ត្រូវទៅរស់នៅ ខាងខេត្តសៀមរាប។ បន្តមក ខៃ និង ហម រួមកម្លាំងជាមួយឈ្មោះ រុន បន្តកសាងកម្លាំងបានចំនួនបីនាក់ទៀតដូចជា៖ វឿន យុទ្ធនារីពេទ្យតំបន់៥, ណាង យុទ្ធនារីពេទ្យតំបន់៥ និង និត យុទ្ធនារីពេទ្យតំបន់៥ ស្ថិតក្នុងភូមិភាគពាយ័ព្យ។

នៅឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមបានមកសម្រាកនៅស្រុកស្រីស្នំ ខេត្តសៀមរាប។ នៅពេលនោះ ខៃបានកសាងកម្លាំងម្នាក់ឈ្មោះ ហានជាយុវជនពេទ្យតំបន់៥ បច្ចុប្បន្នធ្វើពេទ្យនៅសហករណ៍ឃុំគយម៉ែង ស្រុកមង្គលបុរី និងបំផុសប្រជាជនក្នុងភូមិបត់ឱ្យរត់ទៅរស់នៅតំបន់៥ ដោយឃោសនាថា រស់នៅជាមួយអង្គការគឺមិនមានអង្ករឱ្យហូបទៀតទេ។

នៅខែមិថុនា ឆ្នាំ១៩៧៣ ហម បានចាត់តាំងកម្លាំងដែលបានកសាងកន្លងមក ឱ្យចុះមកនៅ ខាងបឹងកំព្រីង និងនៅមន្ទីរពេទ្យកងចល័តតំបន់៥។ នៅទីតាំងនោះ ខៃ បានទាក់ទងជាមួយឈ្មោះ ណៃ ជាលេខាតំបន់៥, ឈ្មោះថង ឃឿន ជាគណៈស្រុកព្រះនេត្រព្រះ ដើម្បីពិភាក្សាពីបញ្ហាទាក់ទងទាហាន លន់ នល់ ឱ្យចូលមកវាយនៅកំពង់ក្រសាំង (ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ)។ ខែសីហា ឆ្នាំ១៩៧៣ ណៃ និង ថង់ ឃឿនបានទៅ ទាក់ទងអាចារ្យម៉ែ នៅភូមិគោកទ្រាស ដើម្បីឱ្យយកអាវុធពីឈ្មោះ នៅ មានតួនាទីជាយកអង្ករ អំបិល ពីតំបន់ខ្លាំងផ្គត់ផ្គង់ឱ្យមកកងទ័ពខ្មែររំដោះ។ ជាកិច្ចការសម្ងាត់ឈ្មោះ នៅ តែងតែយកអាវុធពីទាហាន លន់ នល់ ខាងខេត្តបាត់ដំបង ចូលមកតំបន់រំដោះ។

នៅខែឧសភា ឆ្នាំ១៩៧៤ ខៃ ឡើងតួនាទីជាប្រធានកងចល័តតំបន់៥។ ចំណែក ណៃ ត្រូវទៅរៀននៅសាលាបក្សខាងភូមិភាគបូព៌ា និងបានធ្វើសកម្មភាពទាក់ទងអ្នកនៅបូព៌ា តាមរយៈឈ្មោះ ធួង មានតួនាទីជានីរសារ។ ខែសីហា ឆ្នាំ១៩៧៤ ណៃ បានត្រឡប់មកពាយ័ព្យវិញក៏ទទួលតួនាទីជាលេខាតំបន់៥។ ក្រោយពីទទួលបានមុខងារជាលេខាតំបន់៥ ណៃ បានលួចរៀបចំកងទ័ពសម្ងាត់មួយនៅគោកខ្ពស់ ដោយដាក់ឈ្មោះថា ទ័ពពិសេស។ ទ័ពពិសេសមានសមាជិកចំនួន១០០នាក់ បំពាក់អាវុធគ្រប់ដៃ និងបង្កប់នៅក្នុងព្រៃគោកខ្ពស់។ ខែវិច្ឆិកា ឆ្នាំ១៩៧៤ ណៃបាននាំទ័ពទៅវាយនៅទីតាំងស្វាយត្រាណ ក្រោមស្ពានកាប៉ុននៅភូមិសំរោង។ នៅពេលនោះ ណៃ បាននាំកងទ័ពលេខ១៥០ និង ១០៩ ចូលទៅវាយមុនបន្ទាប់មកបានឱ្យកងទ័ពសម្ងាត់មកវាយពីក្រោយខ្នង បង្កឱ្យមានរបួសចំនួន១០នាក់ និង ស្លាប់ចំនួន៨នាក់។ បន្តមកទៀត ណៃ បានចាត់តាំងនីរសារឈ្មោះ គី ឱ្យទៅ ទាក់ទងកងទ័ពនៅសៀមរាប ប៉ុន្តែអង្គការបានចាប់ខ្លួន គី។ ហេតុនេះផែនការ ទាំងប៉ុន្មានក៏ត្រូវបែកការណ៍។ ដល់ខែធ្នូ ឆ្នាំ១៩៧៤ អង្គការក៏ចាប់ខ្លួនឈ្មោះ ណៃ, ឃឿន, នៅ, ដុស, ទី, ពិច(នារី) និង បក្ខពួកមួយចំនួនទៀត។ ឈ្មោះ ហ៊ីង ត្រូវឡើងតួនាទីលេខាតំបន់៥ ជំនួស ណៃ។ ចំណែកឈ្មោះ ធន ទទួលខុសត្រូវយោធាតំបន់ និង យោធាភូមិភាគលេខ៤១៥ រីឯ ហម ទទួលតួនាទីវរសេនា៤២៥។

នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ខៃ ចូលរួមវាយនៅសមរភូមិថ្មពួក ខេត្តបាត់ដំបង នៅពេលនោះក៏បែកការណ៍ធ្វើឱ្យទាហាន លន់ នល់ បាញ់កងទ័ពខ្មែរក្រហមស្លាប់ និងរបួសប្រហែលជា៣០នាក់។ ក្នុងពេលមានកងទ័ពរបួស ខៃ មិនបានយកចិត្តទុកដាក់ទេ ថែមទាំងដើរធ្វើសកម្មភាពបំផុសយុវជនឱ្យរត់ទៅផ្ទះវិញ ព្រោះខ្មាំងមានកម្លាំងខ្លាំងជាងកងទ័ពបដិវត្តន៍។ ខែមីនា ឆ្នាំ១៩៧៥ ខៃ បានចេញទៅ ទាក់ទងឈ្មោះ ដំ, សែន, វេ និងទំ ជាខ្សែចាស់ដើម្បីកសាងកម្លាំងឱ្យបានច្រើនជាងមុន។ បន្ទាប់ពីនោះ ធនបានណែនាំ ហ៊ីង ឱ្យលើកកងទ័ពទៅវាយ សមរភូមិស្វាយចេក។ នៅសមរភូមិស្វាយចេក ខៃ បានធ្វើសកម្មភាពមិនយកចិត្តទុកដាក់មើលអ្នករបួស ព្រោះគោលបំណងចង់ឱ្យយុវជនអស់ជំនឿលើការដឹកនាំរបស់អង្គការខ្មែរក្រហម។ បន្តមកទៀត ពេលចូលដឹកជញ្ជូនអាវុធនៅបន្ទាយថ្មពួក ធ្វើសកម្មភាពខ្ជះខ្ជាយ យកអាវុធ និងគ្រាប់បោលនៅតាមព្រៃ។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហ៊ីងបានចាត់តាំង ភឿនឱ្យធ្វើជាជំនួយការតំបន់៥ឱ្យដើរប្រមូលក្រុមនិស្សិត សាស្ត្រាចារ្យចំនួន៣០០នាក់ យកទៅទុកនៅផ្សារស្វាយ ស្រុកសេរីសោភ័ណ ខេត្តបាត់ដំបង។ គោលបំណងប្រមូលក្រុមនិស្សិត សាស្ត្រាចារ្យ គឺដើម្បីទុកបញ្ចូលឱ្យធ្វើជាអ្នកដឹកនាំ និងកាន់បញ្ជាកងទ័ព។ បន្ទាប់ពីនោះ ហ៊ីង បានយកនិស្សិតនិងសាស្ត្រាចារ្យទាំងនោះឱ្យទៅដឹកនាំតាមមូលដ្ឋាន និងក្រសួងផ្សេងៗ ប៉ុន្តែនិស្សិតនិងសាស្ត្រាចារ្យទាំងនោះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ ភឿន។ ពាក់កណ្តាលឆ្នាំ១៩៧៥ ហ៊ីង បានរៀបចំផែនការស្ទាក់វាយប្រហារ ឡាននៅតាមផ្លូវជាតិលេខ៦។ សកម្មភាពនៅពេលនោះគឺបាញ់ឡានដឹកជញ្ជូនរបស់អង្គការខូចអស់២គ្រឿង ហើយថែមទាំងចាត់តាំងខ្សែបក្ខពួកមួយចំនួនឱ្យទៅរៀននៅពេទ្យ១៧មេសា នាទីក្រុងភ្នំពេញ។ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ខៃ ត្រូវត្រឡប់មកនៅមន្ទីរពេទ្យស្វាយវិញ។ បន្ទាប់មក អង្គការចាត់តាំងឱ្យ ខៃ មកនៅជាមួយ ហ៊ីង និងទទួលតួនាទីជាអនុប្រធានបច្ចេកទេសពេទ្យតំបន់៥ ភូមិភាគពាយ័ព្យ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ហ៊ីងបានរៀបចំកម្លាំងវាយបក្ស និង បដិវត្តន៍ដោយមានកងទ័ព អ៊ិន តាំ មកចូលរួមជួយ។ ប៉ុន្តែផែនការនេះមិនបានសម្រេចទេ។ ហេតុនេះ ហ៊ីងបានចាត់តាំងកម្លាំងកងទ័ពវរលេខ ៤២៥ ឱ្យត្រៀមឃ្លាំងអាវុធ ឃ្លាំងអង្ករ នៅថ្មពួកជាប់ព្រំដែនថៃ។ ខែកក្កដា ឆ្នាំ១៩៧៦ ហ៊ីង បានចាត់តាំងឈ្មោះ ម៉ន, ម៉េត និងយុវជនមួយទៀត ឱ្យយកអាវុធទៅឱ្យ អ៊ិន តាំ នៅភ្នំម៉ាឡៃ ដោយមាននីរសារឈ្មោះ អែម ជាអ្នកនាំផ្លូវ។ ក្រោពីនោះ ហ៊ីង បានចាត់តាំងឈ្មោះ ង៉ាល ជាជំនួយការផ្នែកពាណិជ្ជកម្មតំបន់៥ ឱ្យទៅ ទាក់ទងជនជាតិថៃនៅ ខាងអូរជ្រៅ

ដើម្បីឱ្យ ទា ហាន អ៊ិន តាំ មកកៀរប្រជាជននៅភូមិកូនត្រី និង ភូមិអូរជ្រៅយកទៅទឹកដីថៃ។ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហ៊ុង បានប្រមូលបក្ខពួកមកប្រជុំនៅភូមិស្វាយ ដើម្បីរៀបចំផែនការដូចជា៖ ១) កម្ទេចអង្គការពេលកំពុងធ្វើដំណើរទៅតាមតំបន់។ ២) ដើរប្រមូលស្រូវនៅតាមភូមិ និង ៣) ជំរុញប្រជាជនឱ្យធ្វើការ ទាំងថ្ងៃ ទាំងយប់ និងទាំងឈឺ។ ខែធ្នូ ឆ្នាំ១៩៧៦ ហ៊ុងបានចាត់តាំងឈ្មោះ គឿនឱ្យសរសេរសំបុត្រហៅបក្ខពួកមកប្រជុំនៅមន្ទីរតំបន់៥ គោលបំណងដើម្បីរៀបចំផែនការប្រចាំឆ្នាំ១៩៧៧ គឺត្រូវកសាងកម្លាំងបន្ថែម និង ផែនការវាយបក្សនៅខែមករា ឆ្នាំ១៩៧៧។

នៅខែមីនា ឆ្នាំ១៩៧៧ ហ៊ុង បានឡើងទៅទាក់ទងប៉ូលីសថៃឈ្មោះ ឆៃ យ៉ាវ៉ា ពាក់ស័ក្តិ១ និង ឈ្មោះ ប៊ុនយ៉ារ៉ា ពាក់ស័ក្តិ៥ ដើម្បីឱ្យយកទ័ពថៃមកវាយបក្សខ្មែរក្រហមនៅខែកក្កដា ឆ្នាំ១៩៧៧។ គោលដៅក្នុងការចូលមកវាយ គឺត្រូវយកស្រុកថ្មពួក ស្រុកស្វាយស៊ីសុផុន ព្រោះជាកន្លែងសេដ្ឋកិច្ចរួចបន្តវាយយកតំបន់៥ ទាំងមូលធ្វើជាទីតាំង និងចុងបញ្ចប់គឺវាយបក្សទូទាំងប្រទេស។

ស្ថិតក្នុងទំព័រចុងក្រោយផ្នែកខាងស្តាំនៃចម្លើយសារភាពរបស់ ឈឺ ហួយ ហៅ ខៃ គឺត្រូវបញ្ចប់ការសាកសួរក្នុងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៧ ព្រមទាំងមានហត្ថលេខា និងផ្តិតមេដៃ។ ចំណែកផ្នែកខាងឆ្វេងមានសម្គាល់ក្រុមអ្នកសួរចម្លើយ ពួកទី១ មានមិត្តខន និង តេង ជាអ្នកសួរ។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខJ00៦១៥ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ឈឺ ហួយ ហៅ ខៃ ពិតប្រាកដប្រយ៉ាងណានោះទេ។***



ពេទ្យបុរាណក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សោម យន៖ ប្រែក្លាយបដិវត្តន៍ឱ្យទៅជាសេរីនិយម

**លី សុខឃាង**



កងចិញ្ចឹមជ្រូកនៅក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កងភ្ជួរនៅក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សោម យន ត្រូវបានចាប់ខ្លួននិងសួរចម្លើយរយៈពេលជាងមួយម៉ោង នៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦ ពីបទពាក់ព័ន្ធនឹងចលនាក្បត់ ដែលចលនានេះមានគោលដៅប្រែក្លាយការគ្រប់គ្រងរបស់បដិវត្តន៍ខ្មែរក្រហមឱ្យទៅជាសេរីនិយមវិញ។ ចលនាក្បត់នេះបានទទួលការគាំទ្រពីប្រទេសវៀតណាម និងសូវៀត។ បញ្ចប់ពីការសួរចម្លើយ សោម យន បានផ្តិតមេដៃ ដោយភ្ជាប់នឹងក្រុមអ្នកសួរចម្លើយ រួមមាន៖ សមមិត្ត ភី ដែលជាប្រធានក្នុងពេលសួរចម្លើយ សមមិត្ត ឡេត និងសាវ៉ាន ដែលជាអនុប្រធាន សមមិត្តចំរើន ដែលជាអ្នកកត់ត្រា និងសមមិត្តញ៉ ដែលជាកងការពារ។ ខាងក្រោមនេះគឺជាចម្លើយសារភាពរបស់ សោម យន។

សោម យន មានវណ្ណៈភាពកសិករកណ្តាលថ្នាក់ក្រោម នៅភូមិបឹងដោល ឃុំបឹងដោល ស្រុកកោះជ័យ ខេត្តព្រៃវែង។ យន មានឪពុកឈ្មោះ សោម ចាប និងម្តាយឈ្មោះ ម៉ែន សេង និងបងប្អូនបង្កើតចំនួន៥នាក់ (ប្រុស១នាក់ និងស្រី៤នាក់) រួមមាន សោម ឡាត់ (ប្តីឈ្មោះ សុខ អៀង) សោម ឡៃ (ប្តីឈ្មោះ ធន់) សោម ម៉ុត (ប្តីឈ្មោះ ម៉ែន ហ៊ុយ) និង សោម វ៉ាន់នី (នៅលីវ)។

យន បានបួសជានេន និងបានរៀនសូត្រនៅសាលាបាលីនៅវត្តបឹងដោល និងវត្តស៊ឹងស្ទូត ក្នុងវ័យ១៧ឆ្នាំ នៅក្នុងឆ្នាំ១៩៦០។ ពីឆ្នាំក្រោយមកយន បានផ្លាស់ប្តូរមករៀនភាសាបាលី នៅវត្តប្រជុំវង់ នៅក្នុងឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្រោមការណែនាំរបស់អាចារ្យមឿន, អាចារ្យ ចាន់ណារ៉ែន និងអាចារ្យឆាន។ អាចារ្យមឿន និងណារ៉ែន

បានអប់រំបដិវត្តន៍និងណែនាំឱ្យធ្វើបាតុកម្មប្រឆាំងការសែតខ្មែរឯករាជ្យ នៅក្បែរវត្តសារ៉ាវ៉ាន និងប្រឆាំងលន់ នល់, ញឹក ជូ ឡុង និងម៉ៅ សាយ។ នៅក្នុងឆ្នាំដដែល យន បានរៀនភាសាបារាំង និងអង់គ្លេស នៅវត្តលង្កា ដែលនៅទីនោះខ្លួនបានធ្វើសកម្មភាពបោះត្រាក់ប្រឆាំងនឹងប្រធានាធិបតីប្រទេសយូហ្គោស្លាវី ទីតូ។ ចាប់ពីឆ្នាំ១៩៦៥ រហូតដល់រដ្ឋប្រហារលន់ នល់នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ យន បានចាកចេញពីវត្តលង្កា និងលាចាកសិក្ខាបទនៅឯវត្តបឹងដោលវិញ ព្រមទាំងត្រឡប់មកធ្វើស្រែចម្ការនៅផ្ទះ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៤ យន ត្រូវបានអង្គការចោទថាក្បត់ ដោយមានការចាត់តាំងពី ឈូក ហៅ ម៉ែន ដែលជាលេខាតំបន់២៤ នៅមន្ទីរស្រុកកោះជ័យ។ អ្នករួមសកម្មក្បត់ផ្សេងទៀតគឺ សមមិត្តក្រូច ដែលជាលេខាស្រុកកោះជ័យ និងសមមិត្តសឺលា ដែលជាគណៈយោធាតំបន់២៤។ តាមការណែនាំរបស់ឈូក, យន បានអនុវត្តសកម្មភាពក្បត់ទាំងឡាយ មានដូចជា ការធ្វើឱ្យរាំងស្ទះដល់មាគ៌ាបក្ស, ការឃោសនាអំពីការមិនអាចធ្វើទៅបាននូវផែនការកសាងប្រទេសក្នុងរយៈពេលពី១០ឆ្នាំទៅ១៥ឆ្នាំ, ការបង្ហាញពីភាពខ្វះខាតរបស់កម្ពុជាបើប្រៀបធៀបរបៀបនៃការកសាងប្រទេសរបស់វៀតណាម ដែលផ្ដោតជាចម្បងលើវិស័យឧស្សាហកម្ម, ការបង្ហាញពីស្ថានភាពប្រសើរឡើង បើ សីហនុ ត្រឡប់មកប្រទេសវិញ និង ការកើតឡើងនូវគ្រោះអត់ឃ្លាននៅតាមសហករណ៍ជាដើម។

យន បានទទួលផែនការពីឈូកបន្តទៀតឱ្យប្រមូលគោ ក្របី ជ្រូក មាន់ នៅតាមមូលដ្ឋាន ដើម្បីបញ្ជូនទៅវៀតណាម និងប្រមូលស្រូវពីប្រជាជនដើម្បីត្រៀមពេលមានអាសន្ន។ នៅក្នុងឆ្នាំ១៩៧៤ យន ស្ថិតក្នុងចំណោមមនុស្សប្រាំមួយនាក់នៅមន្ទីរសាលាស្វាយ ដែលទទួលការចាត់តាំងឱ្យធ្វើសកម្មភាព។ អ្នកទាំងនោះរួមមាន ឈូក ដែលជាមេចាត់តាំង, ឆោម ដែលជាប្រធានឃុំបន្ទាយចក្រី, សន ដែលជាប្រធានឃុំពញាលៀង២, ថេន ដែលបម្រើការជាក្រុមចលនាសហករណ៍របស់តំបន់២៤, និង ថោង ឈឺន ដែលជាប្រធានសន្តិសុខស្រុកកោះជ័យ។

យន ដែលធ្លាប់ទទួលបានភារកិច្ចខាងយោធា និងជាប្រធាន«យ» បានឆ្លើយទៀតថា ចលនាក្បត់នេះមានចរិតជាចលនាសេរីនិយម ដែលប្រឆាំងនឹងរបបកុម្មុយនីស្ត។ យន បានបកស្រាយថា ក្បាលម៉ាស៊ីនក្បត់នេះ ដែលដឹកនាំដោយចក្រី, សុជាន, សុជាតិ, និងឈូក (ផ្ទាល់) ទទួលបានការគាំទ្រពីប្រទេសវៀតណាម និងសូវៀត ហើយបានដឹងទៀតថា កម្លាំងមួយចំនួនបានចូលទៅបង្កប់ខ្លួននៅក្នុងទឹកដីយួនខាងត្បូង។ ចំណែកឯគ្រាប់រំសេវ យន បានរៀបរាប់ថា គ្រាប់កាំភ្លើងគ្រប់ធុនចំនួន៤តោន និងកាំភ្លើងចំនួនពីររទេះសេះ បានបញ្ជូនពីស្រុកកោះជ័យ ទៅកាន់ឃ្លាំងរបស់តំបន់ នៅឯឈើកាច់។ យន បានបញ្ជាក់ថា ប៉ៃម៉ាប់ គឺជាខ្សែរយៈទាក់ទងជាមួយវៀតណាម នៅតាមច្រកកាដូង និងបន្ទាយចក្រី។ នៅក្នុងឱកាសបុណ្យចូលឆ្នាំវៀតណាម កាលពីខែកុម្ភៈ ឆ្នាំ១៩៧៦ ដែរ យន ក៏ធ្លាប់ចូលទៅក្នុងទឹកដីវៀតណាមជាមួយ សមមិត្តក្រូចដែលជាលេខាស្រុកកោះជ័យ និងជាប្រធានគណៈប្រតិភូ, សមមិត្ត ណាន ដែលជាអនុលេខាស្រុកពាមជរ និងជាអនុប្រធានគណៈប្រតិភូ, សមមិត្ត ហ៊ិន ដែលជាប្រធានសន្តិសុខស្រុកពាមជរ និងសមាជិកគណៈប្រតិភូ, និងម្នាក់ទៀត ដែលកងការពារនៃអង្គភាពពាណិជ្ជកម្មតំបន់២៤ ប្រចាំការនៅព្រំដែនព្រែកឆ្ដោរ។ ភាគីវៀតណាម ដែលទទួលភាគីកម្ពុជារួមមាន៖ ចៅហ្វាយខេត្តផ្សារដែក, ចៅហ្វាយស្រុកហុកងឺ, ប៉ៃម៉ាប់ដែលជាគណៈទាក់ទងវៀតណាមកម្ពុជាតំបន់២៤ និងបញ្ជាការកងការពារព្រំដែន វៀតណាមចំនួនបីនាក់ទៀត។

យន បានបញ្ជាក់ចុងក្រោយថា៖ «ចលនាក្បត់នេះគឺមានទិសដៅវាយដណ្ដើមរដ្ឋអំណាចពីបដិវត្តន៍មក គ្រប់គ្រងឱ្យទៅជាសេរីនិយម..»។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខJ00២៧០រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់សោម យន ពិតប្រាកដឬយ៉ាងណានោះទេ។**

# សាខាកាកបាទក្រហមកម្ពុជា ខេត្តស្ទឹងត្រែង និងរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ

## ចុះសួរសុខទុក្ខ និងផ្តល់ជំនួយសង្គ្រោះបន្ទាន់ជូនដល់ប្រជាពលរដ្ឋ រងគ្រោះដោយជំនន់ទឹកភ្លៀង

ស្រេង លីដា



ក្រុមការងារសាខាកាកបាទក្រហម ខេត្តស្ទឹងត្រែង ចុះជួបសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាជនក្នុងឃុំអូរស្វាយដែលរងគ្រោះដោយសារទឹកជំនន់ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តស្ទឹងត្រែង ស្ថិតនៅក្នុងបណ្តាខេត្ត ដែលទទួលរងផលប៉ះពាល់ដោយជំនន់ទឹកភ្លៀង និងត្រូវមានការបង្កើនការប្រុងប្រយ័ត្នខ្ពស់ៗ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥ ក្រោមការណែនាំ និងការចង្អុលបង្ហាញរបស់ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា ខេត្តស្ទឹងត្រែង, លោក ម៉ែន គុង គឺជាប្រធានលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការសម្របសម្រួលផ្ទាល់របស់លោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ ចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌របស់សាខាកាកបាទក្រហមកម្ពុជា ខេត្ត ចែកជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយសារជំនន់ទឹកភ្លៀង ចំនួន៦គ្រួសារ ដែលរស់នៅកោះគគីរ និងកោះពេត្តាៗ កោះគគីរ និងកោះពេត្តា គឺជាកោះនៃស្រុកបុរីអូរស្វាយសែនជ័យ និងមានប្រជាជន

រស់នៅប្រកបរបរកសិកម្ម និងនេសាទ។ ដោយហេតុថា កោះទាំងពីរ មានភូមិសាស្ត្រហ៊ុំព័ទ្ធទៅដោយទន្លេមេគង្គ ដែលកម្ពស់ទឹកទន្លេកំពុងតែបន្តកើនឡើង មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង បានចូលរួមចំណែកជួយសម្រួលចំពោះការធ្វើដំណើរតាមរយៈទូកចម្លងសហគមន៍ សម្រាប់ការដឹកជញ្ជូនក្រុមការងារមនុស្សធម៌របស់សាខាកាកបាទក្រហមកម្ពុជាខេត្តស្ទឹងត្រែង និងសម្ភារសម្រាប់ចែកជូនជនរងគ្រោះ។

លោក ម៉ែន គុង តំណាងឱ្យឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តស្ទឹងត្រែង និងលោក លី មីណា អភិបាលនៃគណៈអភិបាលស្រុក បានចែកអំណោយដល់ជនរងគ្រោះរួមមាន៖ អង្ករ, ត្រីខកំប៉ុង, ទឹកស៊ីអ៊ីវ, មី, ក្រមា, សារ៉ុង និងភួយ ដើម្បីជួយសម្រាលជីវភាពរបស់ប្រជាពលរដ្ឋនាគ្រាដ៏លំបាកនេះ។

បន្ថែមលើនេះទៀត ដោយមើលឃើញអំពីហានិភ័យខ្ពស់ដែលនៅតែអាចកើតមានឡើង បណ្តាលមកពីការបន្តកើនឡើងកម្ពស់ទឹកទន្លេមេគង្គ ក្រុមការងារសាខាកាកបាទក្រហមកម្ពុជាខេត្តស្ទឹងត្រែង, រដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ និងមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង បានជួយរុះរើ និងដឹកជញ្ជូនលំនៅដ្ឋាន និងប្រជាពលរដ្ឋចេញផុតពីតំបន់ហានិភ័យ ទៅទីទួលមានសុវត្ថិភាព។

ស្របពេលដែលស្ថានភាពទឹកជំនន់នៅតែបន្តកើតមានឡើង មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង ត្រៀមលក្ខណៈរួចជាស្រេចដើម្បីផ្តល់កិច្ចសហការណ៍ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ ក្នុងសកម្មភាពមនុស្សធម៌នានា សម្រាប់ប្រជាជនដែលងាយរងគ្រោះ។









ក្រុមការងារសាខាកាកបាទក្រហម ខេត្តស្ទឹងត្រែង ចុះជួបសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាជនក្នុងឃុំអូរស្វាយដែលរងគ្រោះដោយសារទឹកជំនន់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ និងអង្គការ សកម្មភាពកំចាត់មីនជប៉ុន ដោយមានការ

## សម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជាអនុវត្តគម្រោងការផ្លាស់ប្តូរ ដីដែលមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទៅជាដីដែលអាចប្រើប្រាស់បាន

*ស្រេង លីជា*



ក្រុមការងារមកពីអង្គការសកម្មភាពកំចាត់មីនជប៉ុនថតនៅលើបណ្ណាល័យបណ្តែតទឹកនៃមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ អង្គការសកម្មភាពកំចាត់មីនជប៉ុន (Japan Mine Action Service-JMAS) ក្រោមកិច្ចសម្របសម្រួលរបស់រដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ ចាប់ផ្តើមប្រតិបត្តិការរាវរក ប្រមូល និងកម្ទេចគ្រាប់មីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅទីតាំងកោះញៀ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ ដើម្បីអនុវត្តប្រតិបត្តិការខាងលើ អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS) ស្នើសុំកិច្ចសហការបន្ថែមពីមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់ទូកចម្លងសហគមន៍សម្រាប់ដឹកជញ្ជូនក្រុមការងារជំនាញ និងឧបករណ៍ផ្សេងៗ ដោយហេតុទីតាំងកោះញៀ គឺជាកោះដាច់ស្រយាល និងហ៊ុមព័ទ្ធទៅដោយទឹកទន្លេមេគង្គ។ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ការសហការភ្លាមៗ ដោយបានផ្តល់ទូកសម្រាប់ដឹកជញ្ជូនដល់ក្រុមការងារជំនាញ និងឧបករណ៍របស់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS) ដើម្បីបង្ហាញអំពីស្មារតីចូលរួមក្នុងកិច្ចការងារមនុស្សធម៌ និងការផ្លាស់ប្តូរដីដែលមានមីន-យុទ្ធ

ភ័ណ្ឌមិនទាន់ផ្ទុះឱ្យទៅជាដីដែលមានការអភិវឌ្ឍន៍សម្រាប់សហគមន៍នាថ្ងៃអនាគត។

កោះញ៉ោ គឺជាភូមិមួយនៃឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ដែលមានប្រជាជនសរុបចំនួន ៤៨៨ នាក់។ ប្រជាជនភាគច្រើនគឺជាប្រជាកសិករ និងអ្នកនេសាទ ខណៈមួយចំនួនផ្សេងទៀតបានធ្វើការចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅក្នុងប្រទេស និងក្រៅប្រទេស។ រដូវវស្សាក្នុងឆ្នាំនេះ កោះញ៉ោមានភ្លៀងធ្លាក់ជាញឹកញាប់ និងមានដើមឈើរុក្ខជាតិដុះរីកលូតលាស់ត្រួយស្លឹកបៃតងខៀវខ្ចី ស្របពេលដែលប្រជាកសិករចាប់ផ្ដើមភ្ជួររាស់ដី និងប្រជានេសាទធ្វើការនេសាទត្រីបានល្អប្រសើរ។ បើទោះបីជាមានទេសភាពស្រស់ស្អាត និងលក្ខណៈអំណោយផលសម្រាប់ប្រជាជនក្នុងការប្រកបរបរធ្វើស្រែចម្ការ និងនេសាទ កោះញ៉ោក៏ស្ថិតនៅក្នុងភូមិសាស្ត្រមានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជន និងសត្វពាហនៈផ្សេងៗ។

នៅក្នុងអំឡុងប្រទេសមានសង្គ្រាម ចន្លោះពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ កោះញ៉ោគឺជាតំបន់យុទ្ធសាស្ត្រកងទ័ពខ្មែរក្រហម ហើយប្រែក្លាយទៅជាសមរភូមិក្ដៅ។ កោះញ៉ោ ត្រូវទទួលរងការទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ និងទាហានអាមេរិក។ គ្រាប់បែកដែលត្រូវបានទម្លាក់ក្នុងអំឡុងសង្គ្រាម នៅតែបន្តការគំរាមកំហែងដល់អាយុជីវិតប្រជាជនរស់នៅកោះញ៉ោ ពីព្រោះកោះញ៉ោ និងតំបន់ជាប់ពាក់ព័ន្ធទាំងអស់ត្រូវបានកំណត់ជា «តំបន់មានហានិភ័យខ្ពស់ ដែលត្រូវបានជ្រើសរើសសម្រាប់ផ្លាស់ប្ដូរដីដែលមានមីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះឱ្យទៅជាដីដែលមានការអភិវឌ្ឍន៍»។

លោក Fuku Eshige តំណាងអង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS) បានលើកឡើងថា៖ «នៅថ្ងៃនេះ ក្រុមការងារជំនាញរបស់អង្គការសកម្មភាពកំចាត់មីនជប៉ុនយើង បានរាវរកឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គ្រាប់ B-40 ចំនួន១គ្រាប់។ ការរាវរកឃើញនេះ កំណត់អំពីភាពចាំបាច់ និងភាពបន្ទាន់ក្នុងការធ្វើឱ្យសម្រេចបាននូវការសម្អាតគ្រាប់មីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងភូមិសាស្ត្រកោះញ៉ោ ដើម្បីធានាឱ្យបាននូវសុវត្ថិភាពប្រជាជនរស់នៅសហគមន៍នេះ»។

ជាចុងក្រោយលោក Fuku Eshige បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការពីសំណាក់រដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានគាំទ្រដល់ការដឹកជញ្ជូនក្រុមការងារជំនាញ និងឧបករណ៍ផ្សេងៗដោយសុវត្ថិភាព។ ការចូលរួមសហការនាពេលនេះ គឺជាការចូលរួមចំណែកកិច្ចការងារមនុស្សធម៌ដ៏មានតម្លៃបំផុត។ បន្ថែមលើប្រតិបត្តិការរាវរក ប្រមូល និងកម្ទេចគ្រាប់មីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS) នឹងបន្តស្នើសុំកិច្ចសហការគាំទ្រពីមជ្ឈមណ្ឌលឯកសារកម្ពុជាដល់ការដឹកជញ្ជូនមន្ត្រីជំនាញតាមផ្លូវទឹក ទៅកាន់បណ្ដាកោះនានាក្នុងភូមិសាស្ត្រស្រុកបុរីអូរស្វាយ-សែនជ័យ ដើម្បីធ្វើការផ្សព្វផ្សាយអំពីហានិភ័យនៃគ្រាប់មីន-យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅក្នុងសហគមន៍។





ក្រុមការងារមកពីអង្គការសកម្មភាពកំចាត់មីនជប៉ុនបង្ហាញអំពីសកម្មភាពដោះមីនដល់សិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការផ្សារភ្ជាប់រវាងសត្វដំរី និងជនជាតិដើមភាគតិចព្នងនៅភូមិពូតាំង

សូ ហ្វារីណា



សិស្សមកពីសាលាបឋមសិក្សាពូតាំងចូលរួមស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ផ្សារភ្ជាប់សាច់រឿងរបស់មនុស្ស និងសាច់រឿងរបស់ដំរីៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលចងចាំជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី បានរៀបចំកម្មវិធី «ស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ផ្សារភ្ជាប់សាច់រឿងរបស់មនុស្ស និងសាច់រឿងរបស់សត្វដំរីដែលមិនអាចកាត់ផ្តាច់ពីគ្នាបាន» ដោយមានការចូលរួមពីសិស្សចំនួន១២នាក់ៗ មជ្ឈមណ្ឌលចងចាំជនជាតិដើមភាគតិចបានអញ្ជើញវាគ្មិនឈ្មោះ ព្យោយ ទើវ អាយុ៨៥ឆ្នាំ គឺជាជនជាតិព្នង កើតនៅភូមិដាក់ដាំ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ហើយបច្ចុប្បន្នរស់នៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មកធ្វើបទបង្ហាញៗ

ព្យោយ ទើវ បានរៀបរាប់អំពីប្រវត្តិដំរី និងសារប្រយោជន៍ដំរីចំពោះគាត់និងក្រុមគ្រួសារ ព្រមទាំងសាច់រឿងគ្រួសៗនៅមុនសម័យខ្មែរក្រហម ក្នុងសម័យខ្មែរក្រហម និងក្រោយសម័យខ្មែរក្រហម ដូចខាងក្រោម៖

ខ្ញុំឈ្មោះ ព្យោយ ទើវ អាយុ៨៥ឆ្នាំ ជាជនជាតិព្នង កើតនៅភូមិដាក់ដាំ ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរីៗ សព្វថ្ងៃខ្ញុំផ្លាស់មករស់នៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរីៗ ខ្ញុំបានរៀបការរួចនិងមានកូនចំនួន៥នាក់ ក្នុងនោះមានកូនស្រី២នាក់ៗ នៅឆ្នាំ១៩៧៩ កូនស្រីរបស់ខ្ញុំ

ម្នាក់ស្លាប់ ហើយកូនប្រុសម្នាក់ទៀតបានស្លាប់ក្នុងឆ្នាំ១៩៨០។ បច្ចុប្បន្នខ្ញុំនៅសល់កូនតែ៣នាក់ ក៏បានរៀបការរួចហើយដែរ។ ខ្ញុំរស់នៅជាមួយកូនស្រីបន្ទាប់ពីប្តីរបស់ខ្ញុំស្លាប់នៅឆ្នាំ២០០៥។ ទ្រព្យសម្បត្តិដែលឪពុក ម្តាយខ្ញុំបន្សល់ទុកឱ្យគឺដំរីឈ្មោលមួយក្បាល ដែលមានឈ្មោះថា អាពុន អាយុ៤៥ឆ្នាំ ព្រមទាំងមានសុខភាពល្អ។ ចៅប្រុសខ្ញុំឈ្មោះ ណារ៉ូ អាប៉ូ អាយុ២៦ឆ្នាំ ជាអ្នកមើលថែដំរីបន្ត។ អាប៉ូបានរៀបការ ហើយមានកូនប្រុសស្រីចំនួន២នាក់។

ដំរីដែលខ្ញុំមានសព្វថ្ងៃនេះគឺជាថ្នូរនឹងការពលីជីវិតរបស់លោកតាខ្ញុំ។ កាលពីដើមមានក្រុមគ្រួសារអ្នកភូមិមកស្នាក់នៅ និងបានសម្រាលកូននៅលើផ្ទះរបស់តាខ្ញុំ។ បន្ទាប់ពីសម្រាលកូនរួច ជីតារបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺ បន្ទាប់មកក៏ស្លាប់។ ក្រោយពីគាត់ស្លាប់បានមួយរយៈ ទើបយើងដឹងពីមូលហេតុនៃការស្លាប់របស់គាត់ «តាមពិតគាត់ស្លាប់ដោយសារខុសត្រណម»។ អ្នកភូមិបានដាស់តឿនឱ្យគាត់ទៅស្វែងរកអ្នកដែលបានសម្រាលកូននោះ ហើយធ្វើពិធីលៀងលោម។ ក្រោយមកក្រុមគ្រួសារខ្ញុំក៏បានទៅទាមទារសំណងពីក្រុមគ្រួសារដែលបានធ្វើឱ្យជីតាខ្ញុំស្លាប់។ សំណងដែលបានមកវិញគឺសងដំរីមួយក្បាលឱ្យមកគ្រួសារខ្ញុំ ដើម្បីរៀបចំពិធីលៀងលោមនិងបួងសួងអ្នកស្លាប់។ នៅពេលយកដំរីចូលផ្ទះ យើងបានធ្វើពិធីសែនព្រេនដែលរៀបចំដោយគ្រូគង្វាលដំរី ដោយកាប់ជ្រូកមួយក្បាលសែន ហើយបន្ទាប់មកធ្វើពិធីសង្កត់ក្បាលដំរី ដើម្បីឱ្យដំរីស្លូត។ យើងបានចិញ្ចឹមដំរីនោះរហូតមកដល់សព្វថ្ងៃ។

ការចិញ្ចឹមដំរីរបស់បងប្អូនជនជាតិដើមភាគតិចមានត្រណមខ្លាំងណាស់ គឺយើងជឿលើការសែនព្រេន។ នៅពេលដែលដំរីមិនស៊ីចំណីឬមានដំបៅពេញខ្លួន យើងត្រូវពិភាក្សាគ្នាជាមួយក្រុមគ្រួសារឬសមាជិកសហគមន៍ក្នុងមូលដ្ឋានឬចាស់ទុំព្រឹទ្ធាចារ្យ ដើម្បីស្វែងរកគ្រួសារណាមួយដែលធ្វើខុសត្រណម ដូចជា៖ រៀបការកូនមិនបានត្រឹមត្រូវ, សម្រាលកូនគ្មានប្តីទទួលខុសត្រូវ, កូនស្រីមានផ្ទៃពោះដោយគ្មានអ្នកទទួលខុសត្រូវ, រលូតកូននៅផ្ទះឬនៅតាមផ្លូវ។ ទាំងនេះសុទ្ធតែត្រូវយកមកពិន័យ និងធ្វើការសែនព្រេនដំរី។ ការសែនព្រេននេះទៀតសោត ត្រូវមានស្រា១កា ទិនមាន់១ក្បាល និងជ្រូក១ក្បាល ដើម្បីសែនលាបំណន់។ ក្រោយពីដំរីជាសះស្បើយ ដំរីអាចធ្វើការងារបម្រើមនុស្សដូចធម្មតា។

គួបផ្សំជាមួយតួនាទីរបស់ខ្ញុំជាឆ្មបបុរាណ ខ្ញុំកាន់តែមានត្រណមច្រើន។ នៅពេលមានការអញ្ជើញឱ្យចូលរួមក្នុងពិធីមង្គលការរបស់អ្នកភូមិ ខ្ញុំមិនអាចចូលរួមបានទេ លុះត្រាតែក្រុមគ្រួសារកូនកម្លោះកូនក្រមុំឱ្យជ្រូកមួយក្បាល ដំរីមួយក្បាលឱ្យគ្រួសារខ្ញុំទើបខ្ញុំអាចចូលរួមបាន។ ដំរីមានអត្ថប្រយោជន៍ច្រើនណាស់ចំពោះមនុស្សយើង។ កាលពីសម័យមុន សូម្បីនៅក្នុងសម័យ ប៉ុល ពត ដំរីត្រូវបានប្រើឱ្យដឹកជញ្ជូនសព្វាវុធនិងស្បៀង ដើម្បីវាយប្រយុទ្ធគ្នាជាមួយវៀតណាម និងជាមធ្យោបាយធ្វើដំណើរ។ កាលពីមុនយើងគ្មានម៉ូតូ ឡាន ឬកង់ជិះទេ។ ដំរីអាចលីសែងដឹកអីវ៉ាន់ ស្រូវអង្ករ ដឹកឈើដើម្បីសង់ផ្ទះ ដឹកស្បូវសម្រាប់ប្រក់ផ្ទះ ជួយដឹកមនុស្សឆ្លងអូរ ឬទៅមន្ទីរពេទ្យជាដើម។ សម័យឥឡូវ យើងមានយានជំនិះច្រើនប្រភេទ យើងមានប្រាក់ ដូច្នេះយើងមិនសូវពឹងពាក់លើដំរីខ្លាំងដូចកាលពីមុនទេ។ ប៉ុន្តែដំរីនៅតែមានប្រយោជន៍សម្រាប់គ្រួសារខ្ញុំ។ សព្វថ្ងៃនៅក្នុងភូមិពូតាំងមានដំរីស្រុកតែ៤ក្បាលប៉ុណ្ណោះ។

នៅពេលមានសង្គ្រាមរវាង លន់ នល់ និងសម្តេចព្រះ នរោត្តម សីហនុ ខ្ញុំមានអាយុ១៦ឆ្នាំ។ ខ្ញុំក៏មិនដឹងរឿងរ៉ាវលម្អិតដែរព្រោះមិនបានរៀនសូត្រ ហើយរវល់តែជួយឪពុកម្តាយធ្វើស្រែចម្ការ។ ម៉្យាងកាលជំនាន់នោះមិនទាន់មានការផ្សព្វផ្សាយព័ត៌មានទូលំទូលាយ ដូចជា បណ្តាញសង្គមបច្ចុប្បន្នទេ។ នៅពេល ប៉ុល ពត ចូលមក ខ្ញុំត្រូវបានជម្លៀសចេញពីភូមិកំណើតទៅរស់នៅស្រុកកោះញែក នៅឆ្នាំ១៩៧៣។ ខ្មែរក្រហមឱ្យខ្ញុំធ្វើស្រែ ជីកប្រឡាយលើកទំនប់ទាំងយប់ទាំងថ្ងៃ មិនបានសម្រាកឡើយ។ ចំណែកការហូបចុកមិនបានគ្រប់គ្រាន់ទេ។ ភាគច្រើន

ខ្ញុំហូបបបរលាយក្តួចៗ ប្រសិនបើយើងឈឺមិនបានទៅធ្វើការ ខ្មែរក្រហមចាប់យើងទៅកសាង និងរៀនសូត្រៗ ខ្ញុំចាំថា ពេលដែលខ្មែរក្រហមហៅទៅរៀនសូត្រហើយ មិនដែលឃើញមានអ្នកណាត្រឡប់មកវិញទេៗ មិនដឹងអង្គការយកទៅណា ហើយមិនដឹងថាយកទៅសម្លាប់ប៉ុណ្ណាណាទេៗ នៅឆ្នាំ១៩៧៩ បន្ទាប់ពី ប៉ុល ពត ចាញ់សង្គ្រាមវៀតណាម, វៀតណាមបានប្រមូលផ្តុំប្រជាជន ហើយធ្វើការជម្លៀសប្រជាជនចេញពីស្រុកកោះញែក ឱ្យត្រឡប់មករស់នៅតាមភូមិឋានវិញៗ ខ្ញុំបានត្រឡប់មកខេត្តមណ្ឌលគិរីវិញនៅឆ្នាំ១៩៨១ ហើយឆ្នាំ១៩៨២ ទើបខ្ញុំមករស់នៅក្នុងភូមិពូតាំងៗ

ដំរីត្រូវបានប្រើប្រាស់និងរំលេចឡើងខ្លាំងតាំងពីសម័យអង្គរ ដែលត្រូវបានពិព័ណ៌នានៅលើជញ្ជាំងប្រាសាទនានា ដែលក្នុងនោះត្រូវបានប្រើនៅក្នុងកិច្ចការរាជការ ចម្បាំង និងការសាងសង់ប្រាសាទ ហើយនៅក្នុងសម័យអាណានិគមនិយមបារាំង, សម័យសង្គ្រាមទសវត្សរ៍ឆ្នាំ១៩៧០ ក៏មានការប្រើប្រាស់សត្វដំរីដើម្បីដឹកជញ្ជូនសម្ភារសឹក និងស្បៀងៗ ប៉ុន្តែក្រោយមកដោយសារការរងផលប៉ះពាល់ពីការទម្លាក់គ្រាប់បែក, របបខ្មែរក្រហម និងសង្គ្រាមដែលអូសបន្លាយធ្វើឱ្យចំនួនសត្វដំរីស្រុកមានការថយចុះជាបន្តបន្ទាប់ៗ នៅពេលបច្ចុប្បន្ន ដំរីព្រៃពូជអាស៊ីត្រូវបានប្រទះឃើញមានចំនួនប្រមាណ ៥០ក្បាល នៅក្នុងខេត្តមណ្ឌលគិរីៗ

សាច់រឿងរបស់ ព្យោយ ទើវ ជារឿងរ៉ាវមួយក្នុងចំណោមរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥លាននាក់ទៀត ដែលជួយឱ្យក្មេងជំនាន់ក្រោយយល់ដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររួមទាំងរឿងរ៉ាវរបស់សត្វដំរីរបស់ជនជាតិដើមភាគតិចពួង នៅក្នុងភូមិពូតាំង ខេត្តមណ្ឌលគិរីៗ









សិស្សមកពីសាលាបឋមសិក្សាពូតាំងចូលរួមស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ផ្សាភ្ជាប់សាច់រឿងរបស់មនុស្ស និងសាច់រឿងរបស់ដំរីៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះសួរសុខទុក្ខ និងផ្តល់អំណោយដល់

## ជនភៀសសឹកកម្ពុជាពីការឈ្លានពានរបស់ថៃនៅឃុំប្រម៉ោយ ស្រុកវាលវែង

ធ្លុង ជានី



ប្រជាជនភៀសសឹកមកពីឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ មករស់នៅជំរំសុវត្ថិភាពស្ថិតនៅក្នុងវិទ្យាល័យប្រម៉ោយ បណ្តោះអាសន្ន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានបង្រៀនយុវជនមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ នៅក្នុងអំឡុងពេលបង្រៀន ក្រុមការងារក៏បានលើកទឹកចិត្តដល់យុវជនឱ្យចុះសួរសុខទុក្ខ និងផ្តល់អំណោយដល់ជនភៀសសឹកពីការឈ្លានពានរបស់កងទ័ពថៃមកលើទឹកដីកម្ពុជា ហើយជនភៀសសឹកភាគច្រើនគឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាកូនចៅ។

នៅវេលារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ដដែល ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចុះទៅសួរសុខទុក្ខ និងបានផ្តល់អំណោយមួយចំនួន ដូចជា អង្ករ និងសម្ភារប្រើប្រាស់ដល់ជន

ភៀសខ្លួនដែលភាគច្រើនគឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងកូនចៅ នៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ជនភៀសសឹកទាំងនោះមានទីលំនៅឃុំថ្មដា ស្រុកវាលវែង ដែលជាតំបន់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ។ ប្រជាជនភៀសសឹកទាំងនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាជម្លៀសឱ្យមកស្នាក់នៅទីកន្លែងមានសុវត្ថិភាពនៅក្នុងនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ព្រោះកាលពីព្រឹកព្រលឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ទាហានថៃបានបាញ់មកលើទាហានកម្ពុជានៅតំបន់ប្រាសាទតាមាន់ធំមុនៗ បន្ទាប់មកការប៉ះទង្គិចប្រដាប់អាវុធបានរាលដាលបន្តមកតំបន់ប្រាសាទតាមាន់តូច ប្រាសាទតាក្របី អូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យ, ភ្នំទ្រព្យ, តាថាវ, វាលតន្ទ្រើយ, ជាំតែ, អានសេះ, តំបន់មុំបី និងតំបន់ព្រំដែនថ្មដា ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ខាងក្រោមគឺជាចំនួនប្រជាជនជម្លៀសចេញពីឃុំថ្មដា មកស្នាក់នៅក្នុងវត្តប្រម៉ោយ វិទ្យាល័យប្រម៉ោយ និងនៅទីតាំងក្នុងឃុំប្រម៉ោយ នៃស្រុកវាលវែង ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥៖

### ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២៥

- ចំនួន ១១៤ គ្រួសារ សរុប ៣៥៤ នាក់ ស្រី ១១៩ នាក់
- កុមារ ១៦៤ នាក់ ស្រី ៨៨ នាក់
- ចំនួនគ្រួសារកងទ័ព ១៨ គ្រួសារ

### ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០២៥

- ចំនួន ១០០ គ្រួសារ សរុបស្មើនឹង ២៧៣ នាក់ ស្រី ១៥២ នាក់ ក្នុងនោះ
- កុមារ ១២៤ នាក់ ស្រី ៥៤ នាក់
- ចំនួនគ្រួសារកងទ័ព ១៤ គ្រួសារ
- គ្រួសារនគរបាល ២ គ្រួសារ

### ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០២៥

- ចំនួន ៥២២ គ្រួសារ សរុបស្មើនឹង ១៣៦៤ នាក់ ស្រី ៧០០ នាក់ ក្នុងនោះ
- កុមារ ៣៨៨ នាក់ ស្រី១៩០ នាក់
- ចំនួនគ្រួសារកងទ័ព ៣៦ គ្រួសារ

បន្ទាប់ពីបានផ្ដល់អំណោយអង្ករ និងសម្ភារប្រើប្រាស់ជូនដល់ជនភៀសសឹកដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងកូនចៅរួចមក ក្រុមការងារក៏បានសួរនាំអំពីរឿងរ៉ាវលំបាកវេទនាដែលប្រជាជនទាំងនេះបានឆ្លងកាត់ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត (១៩៧៥-១៩៧៩) និងសង្គ្រាមស៊ីវិលអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៩០ ជាពិសេសការប៉ះទង្គិចប្រដាប់អាវុធដែលបង្កឡើងដោយកងទ័ពថៃដែលបានឈ្លានពានទឹកដីកម្ពុជា។

**សៀក ស៊ីម** គឺជាជនភៀសសឹកពីការឈ្លានពានរបស់ថៃ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរៀបរាប់ដូចខាងក្រោម៖

សព្វថ្ងៃ ខ្ញុំមានអាយុ៦២ឆ្នាំ មានមុខរបរដាំដំណាំ និងធ្វើអំបោសលក់។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិចិនគាយ ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សៀក សុត (ស្លាប់) និងម្ដាយឈ្មោះ សូ គាប់ (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់ ហើយខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ ខ្ញុំមានប្ដីឈ្មោះ ញ៉ិល ធំ មានអាយុ៦៣ឆ្នាំ និងជាទាហានចូលនិវត្តន៍។ ខ្ញុំមានកូន២នាក់ ក្នុងនោះមានម្នាក់គឺជាទាហានជួរមុខប្រចាំនៅព្រំដែនថ្មដា។

ខ្ញុំ និងកូនៗពីរនាក់បានប្ដូរទីលំនៅចេញពីស្រុកបាកាន មកនៅរស់នៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់រយៈពេល២៥ឆ្នាំហើយ ព្រោះប្ដីរបស់ខ្ញុំត្រូវបានរាជរដ្ឋាភិបាលប្ដូរឱ្យមកប្រចាំការនៅព្រំប្រទល់កម្ពុជា-ថៃ។

កាលពីកុមារ ខ្ញុំមិនបានចូលរៀនទេ ដោយសារប្រទេសមានសង្គ្រាមៗ នៅក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានបំបែកខ្ញុំចេញពីឪពុកម្តាយ និងបងប្អូនៗ ខ្ញុំរស់នៅក្នុងកងកុមារៗ ចំណែកឪពុករបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យចូលក្នុងកងនេសាទតំបន់២ ភូមិភាគពាយ័ព្យ ហើយម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើជាចុងភៅនៅក្នុងភូមិចិនតាយៗ ខ្មែរក្រហមបានបញ្ជូនកងកុមាររបស់ខ្ញុំចេញពីភូមិចិនតាយ ទៅកាន់ភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ៗ នៅមន្ទីរកុមារក្នុងភូមិអូរតាប៉ោងគឺមានកុមារប្រមាណ១០០នាក់ៗ ខ្មែរក្រហមបានចាត់ខ្ញុំ និងកុមារដទៃទៀតឱ្យកាប់ទន្ទ្រានខែត្រ កាប់ដើមស្ពៅ កាប់ដីដបូក កើបលាមកមនុស្ស និងរើសអាចម៍គោយកមកលាយធ្វើជី និងរែកជីយកទៅចាក់ក្នុងស្រែៗ បន្ទាប់មកទៀត ខ្ញុំត្រូវបានបង្ខំឱ្យធ្វើការងារជាច្រើនទៀតដូចជា លើកភ្លឺស្រែ លើកទំនប់ ជីកប្រឡាយ និងត្រូវចល័តធ្វើការទៅវិញទៅមកក្នុងភូមិអូរតាប៉ោងៗ ចំណែករបបអាហារ ខ្ញុំហូបមិនបានគ្រប់គ្រាន់ឡើយ គឺខ្មែរក្រហមឱ្យខ្ញុំហូបតែបបររាវៗស្ទើររៀងរាល់ថ្ងៃៗ រឿងរ៉ាវដែលខ្ញុំចងចាំ និងមិនអាចបំភ្លេចបានក្នុងរបបខ្មែរក្រហម គឺការរស់នៅបែកពីឪពុកម្តាយជាទីស្រឡាញ់ ការបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរ និងការបរិភោគអាហារមិនបានគ្រប់គ្រាន់ៗ

រហូតដល់ពេលនេះ មានការផ្ទុះឡើងនូវសង្គ្រាមដែលបង្កឡើងដោយប្រទេសថៃ បានធ្វើឱ្យខ្ញុំត្រូវឃ្លាតឆ្ងាយពីផ្ទះសម្បែងម្តងទៀត និងត្រូវបានរាជរដ្ឋាភិបាលជម្លៀសខ្ញុំភ្លាមៗពីតំបន់ព្រំដែនដើម្បីរកទីតាំងសុវត្ថិភាពៗ ទោះបីខ្ញុំមកដល់កន្លែងដែលមានសុវត្ថិភាពហើយក្តី ប៉ុន្តែខ្ញុំនៅតែមានភាពភ័យខ្លាចខ្លាំងណាស់ និងព្រួយបារម្ភពីប្តី និងកូនប្រុសដែលកំពុងប្រចាំការនៅជួរមុខនៅតំបន់ព្រំដែនថ្មដាៗ ប្តីរបស់ខ្ញុំបានផ្តាំខ្ញុំឱ្យចាកចេញពីផ្ទះៗ ចំណែកគាត់មិនចាកចេញពីផ្ទះដាច់ខាត បើរាជរដ្ឋាភិបាលកម្ពុជាត្រូវការកងកម្លាំងបន្ថែម គាត់នឹងស្ម័គ្រចិត្តចូលរួមប្រយុទ្ធក្នុងសមរភូមិតទល់នឹងកងទ័ពថៃភ្លាមៗ







ប្រជាជនភៀសសឹកមកពីឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ មករស់នៅជំរំសុវត្ថិភាពស្ថិតនៅក្នុងវត្តប្រម៉ោយ បណ្តោះអាសន្នៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជនជាតិចាមនៅភូមិស្វាភ្នំក្នុងរបបខ្មែរក្រហម

ឈុំ រ៉ា



សិស្សបឋមសិក្សាខ្មែរអ៊ិស្លាមនៅភូមិស្វាភ្នំ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចុះសួរសុខទុក្ខ និងស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៨នាក់ រស់នៅភូមិស្វាភ្នំ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ គោលបំណងដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចុះមកភូមិស្វាភ្នំមានដូចខាងក្រោម៖

ទី១) សួរសុខទុក្ខ និងស្វែងយល់អំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិចាមនៅភូមិស្វាភ្នំ

ទី២) ស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិចាមនៅភូមិស្វាភ្នំ

ទី៣) ចងក្រងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិចាមនៅភូមិស្វាភ្នំទុកជាឯកសារសម្រាប់ផ្សព្វផ្សាយ និងសម្រាប់យុវជនជំនាន់ក្រោយសិក្សារៀនសូត្រ។

ភូមិស្វាភ្នំមានប្រជាជនសរុបចំនួន៨៧៦នាក់ ក្នុងនោះមានស្រី៤៥៧ នាក់ ដែលស្មើនឹង១៩២ គ្រួសារ។ ក្នុងចំណោមប្រជាជនក្នុងភូមិសរុប គឺមាន៩៥ភាគរយជាជនជាតិចាម និង៥ភាគរយគឺជាជនជាតិខ្មែរដែលមានប្តីឬប្រពន្ធជនជាតិចាម។ ភូមិស្វាភ្នំមានព្រំប្រទល់ខាងលិចជាប់ភូមិស្វាគី ឡូ និងជាប់ផ្លូវជាតិលេខ៧, ខាងកើតជាប់ភូមិត្រាង (ភូមិត្រាងចំណុះភូមិចង្កឹកណ្ដាល), ខាងជើងជាប់ភូមិគ្គុលលើ និង

ខាងត្បូងជាប់ភូមិម្កោរ នៃឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ភូមិស្វាភ្នំ ក៏ដូចភូមិមួយចំនួនទៀតក្នុងឃុំទន្លូងបានរងឥទ្ធិពលពីសង្គ្រាមវៀតណាម ដោយមានកងទ័ពវៀតកុង, ទាហានធីវគី, ទាហានសហរដ្ឋអាមេរិក និងខ្មែរក្រហមបានចូលមកដល់ភូមិស្វាភ្នំ និងតំបន់ផ្សេងទៀតនៅក្នុងស្រុកមេមត់។ នៅអំឡុងពេលនោះ ភូមិស្វាភ្នំត្រូវរងការទម្លាក់គ្រាប់បែក ហើយប្រជាជនត្រូវលាក់ខ្លួនក្នុងលេណដ្ឋាន និងភៀសខ្លួនចេញពីភូមិទៅរស់នៅតំបន់ផ្សេងទៀតនៃស្រុកមេមត់។

បន្ទាប់ពីរបបខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាតិចាមនៅភូមិស្វាភ្នំ និងប្រជាជនខ្មែរនៅភូមិផ្សេងៗទៀត ត្រូវបានខ្មែរក្រហមបង្ខំឱ្យរស់នៅក្នុងសហករណ៍ និងបានប្រមូលទ្រព្យសម្បត្តិទាំងអស់មកដាក់រួម ធ្វើការងារពលកម្មចៀរជ័រកៅស៊ូរួម ធ្វើស្រែរួម ហូបរួមនៅតាមរោងបាយក្នុងភូមិ។ នៅពេលនោះ ជនជាតិចាមនៅភូមិស្វាភ្នំហូបបបរមិនបានគ្រប់គ្រាន់ឡើយ។

នៅឆ្នាំ១៩៧៦ ជនជាតិចាមនៅភូមិស្វាភ្នំ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិឱ្យទៅរស់នៅតាមស្រុកមួយចំនួន ដូចជា ស្រុកក្រូចឆ្មារ ស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំ។ នៅទីនោះ ខ្មែរក្រហមបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូក និងមិនឱ្យនិយាយភាសាចាម ឬថ្វាយបង្គំឡើយ។ ខ្មែរក្រហមថែមទាំងមិនឱ្យជនជាតិចាមរស់នៅជុំគ្នា។ ខ្មែរក្រហមបំបែកជនជាតិចាមចំនួនពីរទៅបីគ្រួសារឱ្យទៅរស់នៅលាយឡំជាមួយប្រជាជនខ្មែរ នៅក្នុងសហករណ៍ ឬក្នុងឃុំ ហើយធ្វើការងាររួម ហូបរួម ដេករួមគ្នា។ ដូច្នេះ ជនជាតិចាមភាគច្រើនមិនបានរស់នៅជួបជុំគ្រួសារ ឬរស់នៅជាមួយជនជាតិចាមដូចគ្នាទេ។

ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមបានបែងចែកជនជាតិចាមទៅតាមវ័យ ដើម្បីបង្កបង្កើនផល។ ខ្មែរក្រហមបែងចែកការងារដល់ជនជាតិចាម ដូចជា កងកុមារ ត្រូវដើររើសអាចម៍គោ-ក្របីធ្វើជី, បោចស្មៅនៅតាមវាលស្រែ, ឃ្វាលគោ-ក្របី, យុវជនមានកម្លាំងពេញ ត្រូវចូលបម្រើកងទ័ព និងចូលធ្វើការនៅកងចល័ត, លើកប្រព័ន្ធភ្លឺស្រែ, លើកទំនប់, ជីកប្រឡាយ ហើយកងកម្លាំងវ័យចំណាស់ ត្រូវមើលថែទាំក្មេងៗ ដេញចាបកុំឱ្យស៊ីស្រូវ រកបន្លែ និងដាំស្ល។ នៅក្នុងរបបខ្មែរក្រហមមានក្រុមគ្រួសារជនជាតិចាមក្នុងភូមិស្វាភ្នំមួយចំនួន ត្រូវបានខ្មែរក្រហមសម្លាប់ ដោយចោទថាក្បត់ជាមួយអង្គការ និងចាត់ទុកជនជាតិចាមថាជាក្រុមបះបោរប្រឆាំងជាមួយខ្មែរក្រហម។ ប្រជាជនចាមនៅភូមិស្វាភ្នំមួយចំនួនទៀតស្លាប់ដោយសារអត់អាហារ ជំងឺ និងបាត់ខ្លួនអំឡុងពេលខ្មែរក្រហមជម្លៀសចេញពីភូមិកំណើត។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនចាមនៅភូមិស្វាភ្នំមិនទាន់ចូលមករស់នៅក្នុងភូមិភ្លាមទេ គឺស្នាក់នៅភូមិឆ្ងាយបណ្ដោះអាសន្នព្រោះផ្ទះសម្បែងត្រូវខ្មែរក្រហមរុះរើគ្មានសល់ ម្យ៉ាងទៀតខ្លាចគ្រាប់បែកដែលនៅសេសសល់ពីសម័យសង្គ្រាម។ នៅពេលថ្ងៃជនជាតិចាមបានចូលមកធ្វើចម្ការនៅក្នុងភូមិស្វាភ្នំ ហើយពេលយប់ត្រូវត្រឡប់ទៅដេកនៅភូមិផ្សេង។ រយៈពេលមួយឆ្នាំក្រោយមក ទើបជនជាតិចាមចូលមករស់នៅក្នុងភូមិស្វាភ្នំជាបន្តបន្ទាប់។



ជនជាតិភាគតិចចាមនៅភូមិស្វាភ្នំ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ប្រកបមុខរបរវេចនំអន្សមចេក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អដ្ឋិធាតុជួបជុំជាមួយក្រុមគ្រួសារ

ស្រ៊ាង លីហ្វួរ




លោក សំរិត ចាន់ណារ័ត្ន មកទទួលអដ្ឋិធាតុប្រពន្ធឈ្មោះ ពៅ ចាន្នី ពីហោអដ្ឋិធាតុ ឬបណ្ណាល័យធាតុ នៅវត្តលង្កា យកទៅថែរក្សាទុក និងធ្វើបុណ្យតាមទំនៀមទម្លាប់ប្រពៃណីសាសនា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីជាងបីទសវត្សរ៍មុន ពៅ ចាន្នី ដែលជាស្ត្រីមេផ្ទះម្នាក់បានទទួលមរណភាពក្នុងជន្មាយុ ២៧ឆ្នាំ បន្ទាប់ពីចំណាយពេលប្រមាណ ២ឆ្នាំក្នុងការព្យាបាលជំងឺមហារីក។

សំរិត ចាន់ណារ័ត្ន ដែលត្រូវជាប្តីបាននិយាយថា៖ "យើងស្គាល់គ្នាតាំងពីនៅវ័យសិក្សា"។ សព្វថ្ងៃ ចាន់ណារ័ត្ន មានអាយុ ៦០ឆ្នាំ ជាមន្ត្រីចូលនិវត្តន៍ និងរស់នៅខេត្តពោធិ៍សាត់។ បើតាម ចាន់ណារ័ត្ន បានឱ្យដឹងថា ចាន្នី ជាកូនពៅក្នុងគ្រួសារដែលមានបងប្អូនចំនួន៦នាក់ និងមានស្រុកកំណើត នៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

ក្នុងរបបខ្មែរក្រហម ចាន់ណារ័ត្ន ធ្វើការនៅអង្គភាពកងកុមារក្នុងខេត្តក្រចេះ ចំណែក ចាន្នី រស់នៅឯស្រុកកំណើត។ ចាន់ណារ័ត្ន បាននិយាយថា ភរិយារបស់គាត់កម្រនិយាយអំពីបទពិសោធន៍ជីវិតផ្ទាល់ខ្លួនអំឡុងរបបខ្មែរក្រហមណាស់។

នៅទសវត្សរ៍ឆ្នាំ១៩៨០ ចាន្នី និង ចាន់ណារ័ត្ន បានរៀបការនៅទីក្រុងភ្នំពេញ និងមានកូនប្រុសទោលម្នាក់។ នៅឆ្នាំ១៩៩២ ចាន្នី បានទទួលអនិច្ចកម្ម។ ក្រោយពីពិធីបុណ្យសព ធាតុត្រូវបានតម្កល់នៅវត្តលង្កាព្រះកុសុមារាម។

ចាន់ណារ័ត្ន មានប្រសាសន៍ថា "កាលនោះនៅពេលគាត់ស្លាប់ យើងមិនទាន់មានផ្ទះផ្ទាល់ខ្លួន ដូច្នេះខ្ញុំសម្រេចចិត្តរក្សាទុកធាតុនៅវត្ត និងរង់ចាំ

ទាល់តែយើងមានកន្លែងសមរម្យសម្រាប់គាត់,” គាត់បន្តថា “ខ្ញុំក៏បានសរសេរឈ្មោះ, ថ្ងៃខែឆ្នាំ និងអាយុ នៅលើកោដ្ឋដងដែរ”។ ដូច្នេះនៅពេលក្រោយ ក្រុមគ្រួសារអាចនឹងទៅយកកោដ្ឋរបស់ភរិយាគាត់ត្រឡប់មកវិញ។

ជាអកុសល ជាងមួយទសវត្សរ៍មុន មានឧប្បត្តិហេតុអគ្គិភ័យបានឆាបឆេះនៅកន្លែងដែលតម្កល់កោដ្ឋរួមមានកោដ្ឋរបស់ ចាន្ទី។ ក្រោយពេលកើតហេតុ ក្រុមគ្រួសារបានព្យាយាមស្វែងរកទីតាំងដែលតម្កល់ថ្មី ប៉ុន្តែហាក់មិនមាននរណាម្នាក់ រួមទាំងព្រះសង្ឃបានដឹងអំពីទីតាំងពិតប្រាកដនោះទេ ហើយបន្ទាប់ពីឧប្បត្តិហេតុនោះ អ្នកដែលដឹងអំពីទីតាំងក៏បានទទួលអនិច្ចកម្មទៅដងដែរ។ ចាប់តាំងពីពេលនោះមក ទីតាំងកោដ្ឋរបស់ចាន្ទីមិនត្រូវបានដឹងខណៈក្រុមគ្រួសាររបស់ចាន្ទីបានបន្តព្យាយាមស្វែងរកអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។

សុមនោ បាននិយាយថា៖ «ខ្ញុំគ្រាន់តែដឹងថាម្ដាយខ្ញុំនៅកន្លែងណាមួយនៅក្នុងវត្តនេះ ប៉ុន្តែខ្ញុំមិនដឹងថានៅទីណាច្បាស់នោះទេ»។ សំរិត សុមនោ គឺជាបុគ្គលិកធនាគារ។ គាត់កើតនៅឆ្នាំ១៩៨៨ នៅបឹងកេងកង រាជធានីភ្នំពេញ បច្ចុប្បន្នគាត់រស់នៅសង្កាត់ព្រែកប្រា។

នៅពេលដែលម្ដាយរបស់គាត់បានទទួលមរណភាព សុមនោ មានអាយុប្រហែល ៥ឆ្នាំប៉ុណ្ណោះ។ ឪពុកនិងជីដូនរបស់សុមនោតែងតែនាំគាត់ទៅវត្តដើម្បីធ្វើបុណ្យឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធម្ដាយជារៀងរាល់ឆ្នាំ ហើយគាត់ក៏តែងតែនាំកូនៗមកទីនេះជាញឹកញាប់ដងដែរ។

សុមនោ និយាយថា “ខ្ញុំតែងតែមកវត្តនេះ ដើម្បីឧទ្ទិសកុសលផលបុណ្យដល់ដួងវិញ្ញាណក្ខន្ធម្ដាយខ្ញុំ”។ ថ្មីៗនេះ ជីដូនទើបតែទទួលមរណភាពកាលពីប៉ុន្មានឆ្នាំមុន។ សុមនោ សង្ឃឹម និងប្រាថ្នាថាគាត់អាចរកឃើញកោដ្ឋរបស់ម្ដាយគាត់ក្នុងថ្ងៃណាមួយ ជាក់ជាពុំខាន។

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំពិធីបង្សុកូល និងឧទ្ទិសកុសលផលបុណ្យដល់វិញ្ញាណក្ខន្ធ នៅហោអដ្ឋិធាតុក្នុងវត្តលង្កាព្រះកុសុមារាម រាជធានីភ្នំពេញ។ ក្នុងកិច្ចសម្ភាសន៍ជាមួយវិទ្យុបារាំងអន្តរជាតិ កាលពីពេលថ្មីៗនេះ លោក ឆាំង យុ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រាប់ដំណើររឿងដែលលោកបានរកឃើញកោដ្ឋជាច្រើន ក្នុងគ្រាដែលលោកបានបួសជាព្រះសង្ឃ និងការទុក្ខចំពោះបងស្រីរបស់លោកដែលបានទទួលមរណភាពដោយសារជំងឺមហារីកនៅវត្តលង្កាព្រះកុសុមារាម កាលពីឆ្នាំ២០១៥។

នៅថ្ងៃមួយ នាម៉ោង៤ទៀបភ្លឺ លោកបានរកឃើញបន្ទប់មួយក្រោមរូបសំណាកព្រះពុទ្ធបដិមា។ នៅក្នុងនោះ មានកោដ្ឋរាប់រយ ពោរពេញដោយធូលីដី។ កោដ្ឋរបស់ចាន្ទី គឺស្ថិតក្នុងចំណោមកោដ្ឋចំនួន៤៦៤ ដែលស្ថិតនៅក្នុងបន្ទប់នោះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា បានចងក្រងឯកសារអំពីព័ត៌មានស្ដីពីកោដ្ឋទាំងនោះសម្រាប់ឱ្យក្រុមគ្រួសារងាយស្រួលក្នុងការស្វែងរក។ តាំងពីឆ្នាំ២០១៥មក មានតែ៩ គ្រួសារប៉ុណ្ណោះបានដឹងដំណឹងអំពីសាច់ញាតិរបស់ខ្លួនដែលតម្កល់នៅទីនេះ។

នៅឆ្នាំ២០២៣ បណ្ណាល័យហោអដ្ឋិធាតុត្រូវបានបង្កើតឡើងដើម្បីតម្កល់កោដ្ឋទាំងនោះនៅកន្លែងមួយដែលសមរម្យ និងប្រសើរជាងមុន។ គ្រួសាររបស់ ចាន្ទី គឺជាគ្រួសារដំបូងបង្អស់ដែលបានដង្ហែកោដ្ឋរបស់ ចាន្ទី ទៅស្រុកកំណើតរបស់ស្វាមីគាត់។

សុមនោ បាននិយាយថា៖ “នៅពេលខ្ញុំបានដឹងព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ ខ្ញុំបានព្យាយាមទាក់ទងទៅមជ្ឈមណ្ឌលឯកសារកម្ពុជា”។

ដំបូងឡើយ សុមនោ បានមកពិនិត្យកោដ្ឋនៅបណ្ណាល័យហោអដ្ឋិធាតុ។ ក្នុងបញ្ជីឈ្មោះដែលរៀបចំដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានកោដ្ឋលេខរៀងទី៤០៥ ឈ្មោះ ពៅ ចាន្ទី បានទទួលមរណភាពនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩២ ក្នុងជន្មាយុ ២៧ឆ្នាំ ដែលបញ្ជាក់ថាជាកោដ្ឋម្ដាយរបស់លោក ដូច្នេះក្រុមគ្រួសារបានរៀបចំធ្វើពិធីបង្សុកូលដើម្បីឧទ្ទិសកុសល នៅពេលជួបជុំគ្នាសារជាថ្មី។





ក្រុមគ្រួសារលោក សំរិត សុមនោ ដែលត្រូវជាកូនរបស់ឈ្មោះ ពៅ ចាន្ទី សូត្រមន្តបង្សុកូលក្នុងថ្ងៃទទួលអដ្ឋិធាតុម្តាយពីហោអដ្ឋិធាតុ បុបណ្ណាល័យធាតុ នៅវត្តលង្កា យកទៅថែរក្សាទុក និងធ្វើបុណ្យតាមទំនៀមទម្លាប់ប្រពៃណីសាសនា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥ វេលាម៉ោង ៧ព្រឹក ក្រុមគ្រួសាររបស់ចាន្ទីរួមទាំងចៅៗបានមកដង្ហែកោដ្ឋរបស់ចាន្ទី ទៅតម្កល់នៅវត្តកណ្តាលកោះ ឃុំកោះអន្ទង់ចិន ខេត្តកណ្តាល ដែលជាស្រុកកំណើតរបស់ស្វាមីគាត់។

សុមនោ បាននិយាយទាំងទឹកភ្នែក និងរំភើបខណៈដែលបំណងប្រាថ្នារបស់គាត់ក្លាយជាការពិត។ គាត់បានភ្ជាប់មកជាមួយ នឹងផ្លែឈើដែលបានរៀបចំសម្រាប់ពិធីបង្សុកូល។ គាត់និយាយ "វាជាសំណាងដែលយើងបានរកឃើញធាតុរបស់គាត់"។

ចាន់ណារ័ត្ន ថា៖ “កូនខ្ញុំប្រាប់ខ្ញុំតាមទូរស័ព្ទថាគាត់បានរកឃើញកោដ្ឋនៅអង្គការមួយកន្លែង”។ ចាន់ណារ័ត្ន បានបន្តថា៖ “ខ្ញុំពិតជាសប្បាយចិត្តដែលបានជួបនាងម្តងទៀត”។

លោក ឆាំង យុ បានមានប្រសាសន៍ថា “ការផ្សះផ្សានៃប្រជាជាតិមួយ គឺផ្តើមចេញពីបុគ្គលម្នាក់នៅក្នុងខណៈពេលមួយ”។

ចាន់ណារ័ត្ន មានប្រសាសន៍ថា “ខ្ញុំពិតជាកោតសរសើរចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានយកចិត្តទុកដាក់កោដ្ឋទាំងនេះ និងបានតម្កល់នៅទីនេះ” ខណៈដែលមជ្ឈមណ្ឌលនេះក៏បានយកចិត្តទុកដាក់ និងគោរពចំពោះអ្នកដែលបានទទួលមរណភាពផងដែរ។ លោក ឆាំង យុ បាននិយាយថាអ្នកទាំងនោះ គឺជាព្រលឹងជនរងគ្រោះនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍។

ចាន់ណារ័ត្ន មានប្រសាសន៍ថា “ប្រសិនបើនរណាម្នាក់រកមិនឃើញធាតុដែលបានបាត់ដំណឹងដូចរូបលោក សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជា និងហើយចូលទៅកាន់ហោអដ្ឋិធាតុ”។ “វាពិតជាមានន័យសម្រាប់ខ្ញុំ ក្នុងការជួបជុំជាមួយប្រពន្ធរបស់ខ្ញុំ”។

# និស្សិតសាកលវិទ្យាល័យ Wisconsin-Madison ចាប់អារម្មណ៍មកស្រាវជ្រាវ

## នៅព្រះរាជបណ្ណាល័យហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**សោម ប៊ុនថន**



និស្សិតមកពីសាកលវិទ្យាល័យ Wisconsin-Madison មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥ លោក Napakadol Kittisenee គឺបេក្ខជនបណ្ឌិត និងជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រ នៅសាកលវិទ្យាល័យ Wisconsin-Madison សហរដ្ឋអាមេរិក បានដឹកនាំនិស្សិតចំនួន១៥នាក់ មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈកម្មវិធី Junior Resident Fellow Program (JRFP) ដែលជាកម្មវិធីមួយក្នុងចំណោមកម្មវិធីផ្សេងទៀតរបស់មជ្ឈមណ្ឌលសម្រាប់ការសិក្សាខ្មែរ (CKS)។ កម្មវិធី Junior Resident Fellow Program មាននិស្សិតថ្នាក់បរិញ្ញាបត្រ និងនិស្សិតបញ្ចប់ការសិក្សា មកពីប្រទេសចំនួន៣ផ្សេងគ្នា រួមមានបារាំង កម្ពុជា និងសហរដ្ឋអាមេរិក។ និស្សិតទាំងនេះនឹងចូលរួមកម្មវិធីសិក្សាអំពីរបៀបធ្វើការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលវិស្សមកាលរយៈពេល៦សប្តាហ៍។

និស្សិតទាំងនេះបានជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារ

របស់លោកដើម្បីពិភាក្សាអំពីកេរដំណែលនៃការចងចាំ និងការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ឆាំង យុ បានលើកឡើងអំពីដំណើរការនៃការប្រមូលទិន្នន័យរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺធ្វើឡើងតាមរយៈសិស្ស និងនិស្សិតស្ម័គ្រចិត្តកម្ពុជាចំនួន ៤,១៥៦នាក់ ដែលត្រូវបានជ្រើសរើសឱ្យចុះធ្វើការសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៦១,៦២៥នាក់ ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាលទូទាំងប្រទេសកម្ពុជា អំពីបញ្ហាប្រឈមផ្នែកសុខភាព និងបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម។ បន្ទាប់មក ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលទិន្នន័យ ទាំងនេះមកចងក្រង និងថែរក្សាទុកសម្រាប់សាធារណជន សិស្ស និងនិស្សិតអាន និងមកធ្វើការសិក្សាស្រាវជ្រាវ។ ក្នុងឱកាសនេះដែរ លោក ឆាំង យុ បានផ្តល់ឱកាស និងលើកទឹកចិត្តដល់និស្សិតទាំង១៥នាក់ទៅសិក្សាស្រាវជ្រាវនៅសាខាមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៩ទីតាំងទៀត ដែលស្ថិតនៅតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា ដូច្នេះនិស្សិតអាចផ្សារភ្ជាប់ខ្លួនទៅនឹងសហគមន៍ដោយផ្ទាល់ និងទទួលបានព័ត៌មានសម្បូរបែប និងពិតប្រាកដ។

បន្ទាប់ពីការពិភាក្សា លោក Napakadol Kittisenee និងនិស្សិតទាំងអស់បានសម្តែងសេចក្តីរីករាយដែលបានមកទស្សនកិច្ចព្រះរាជបណ្ណាល័យហ្វូនម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់ ព្រមទាំងបានយល់ដឹងកាន់តែស៊ីជម្រៅអំពីរបបខ្មែរក្រហម ជាពិសេសបានចាប់អារម្មណ៍មកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលខាងមុខ។










និស្សិតមកពីសាកលវិទ្យាល័យ Wisconsin-Madison មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យហ្វូនម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីបេះផ្លែក្រវាញរបស់ជនជាតិដើមភាគតិចព័រ នៅឃុំស្រែតាំងយ៉

ឡុង ដានី



ពិធីឡើងអ្នកតារបស់ជនជាតិភាគតិចព័រនៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅមុនសង្គ្រាមស៊ីវិលទសវត្សរ៍ឆ្នាំ១៩៧០ ជនជាតិដើមភាគតិចព័រ និងជនជាតិដទៃទៀតរស់នៅឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ តែងតែប្រារព្ធពិធីបេះផ្លែក្រវាញជារៀងរាល់ឆ្នាំក្នុងខែអាសាឍ (ខែកក្កដា)។ មុនពេលរៀបចំពិធីបេះផ្លែក្រវាញ ជនជាតិដើមភាគតិចព័របានចូលព្រៃក្រវាញអង្កេតមើល ថាតើក្រវាញបានទុំស្រុះហើយឬនៅ? បន្ទាប់មកទើបមេស្រុក បុងផ្ញើរ ក្រវាញបានប្រកូកប្រកាសហៅអ្នកភូមិដែលមានបំណងចង់ទៅបេះផ្លែក្រវាញ។ អ្នកចូលរួមពិធីបេះផ្លែក្រវាញភាគច្រើនគឺជាជនជាតិដើមភាគតិចព័រ ជនជាតិដើមភាគតិចជង (ជងខ្នងភ្នំ) និងជនជាតិខ្មែររស់នៅក្នុងភូមិទួលគ្រួស ភូមិស្រែពាំង ភូមិអន្លង់ក្រូច ភូមិមាត់ព្រះ ភូមិវាលវែង-អូរសោម និងភូមិមួយចំនួនទៀតក្នុងឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បើតាមលោក ហែម ហ៊ិន អាយុ៧២ឆ្នាំ គឺជនជាតិដើមភាគតិចព័រ បច្ចុប្បន្នរស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់បានរៀបរាប់ថា អ្នកភូមិដែលបានចូលរួមពិធីបេះផ្លែក្រវាញមានចន្លោះពី១០០ ទៅ៥០០នាក់ អាស្រ័យទៅលើរដូវកាលក្រវាញនីមួយៗដែលមានផ្លែក្រវាញទុំច្រើនឬតិច។



*លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងសម្ភាសន៍ជនជាតិដើមភាគតិចព័រនៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



ពេលចាប់ផ្តើមពិធីបេះផ្លែក្រវាញ មេស្នឹង (ដង្វៅក្រវាញ) និងអ្នកភូមិបានធ្វើដំណើរទៅភូមិអន្លង់ក្រូច ឃុំស្រែគាំងយ៉ ទាំងអស់គ្នា និងរៀបចំពិធីសែនព្រេន ដោយធ្វើរានមានដាក់មាន់ស្ងោរ នំចំណី អន្សម នៅលើរានៗ បន្ទាប់មកដុតធូប ទៀន បួងសួង ហើយនៅពេលយប់ក្រុមភ្លេងបានលេងភ្លេងឡើងអ្នកតាចំនួន៣បទៗ នៅពេលព្រឹកឡើង ដង្វៅក្រវាញបាននាំអ្នកភូមិដែលជាកូនចៅ ធ្វើដំណើរដោយថ្មើរជើងរួមជាមួយដំរីដឹកអីវ៉ាន់នំចំណីផងទៅភ្នំដំណាក់ក្បាលទ្វាគ្រាង។ បន្ទាប់មកទៀត ដង្វៅក្រវាញ និង កូនចៅបានធ្វើដំណើរទៅកាន់ភ្នំមួយទៀតមានឈ្មោះថា ភ្នំអន្ទង់រីម ស្ថិតក្នុងភូមិសាស្ត្រភូមិអន្លង់ក្រូច ដើម្បីរៀបចំពិធីសែនព្រេនម្តងទៀត ដោយមានដាក់ស្លាធម៌ មាន់ស្ងោរ ដុតធូប ទៀនបួងសួង ហើយនៅពេលយប់មានលេងភ្លេងឡើងអ្នកតាចំនួន៣បទ និងមានអ្នកបញ្ចូលរូបថែមទៀត។ ដង្វៅក្រវាញ និងកូនចៅត្រូវសម្រាកនៅភ្នំអន្ទង់រីមចំនួន១យប់ ឬ២យប់ ឬ៣យប់អាស្រ័យលើដង្វៅក្រវាញមើលពេលវេលា ថាតើត្រូវចេញដំណើរបន្តទៀត ឬត្រូវស្នាក់នៅបន្តទៀត។

ពេលដង្វៅក្រវាញ និងកូនចៅធ្វើដំណើរទៅដល់ភូមិមាត់ព្រះ ត្រូវដោះស្បែកជើងទាំងអស់ទុកនៅក្នុងភូមិ និងសម្រាកនៅក្នុងភូមិមាត់ព្រះមួយយប់ទៀត លុះដល់ព្រឹកឡើងធ្វើដំណើរដោយជើងទទេជាមួយដំរីឆ្ពោះទៅកាន់ព្រៃក្រវាញដែលស្ថិតនៅខាងលិចភូមិវាលវែង-អូរសោម ព្រៃគួយ ព្រៃជ្រៃ។ ដង្វៅក្រវាញ និងកូនចៅបានសម្រាកនៅព្រៃជ្រៃ និងចាប់ផ្តើមធ្វើស្នែងចំនួន៣ ដើម្បីសែងដង្វៅធំម្នាក់ និងដង្វៅសំណែនចំនួន២នាក់។ នៅព្រឹកថ្ងៃបន្ទាប់ ដង្វៅធំស្លៀកក្បិនពណ៌ស និងក្រវាត់កពណ៌ស ត្រូវ

បានអ្នកហែហមសែននៅមុខគេ បន្ទាប់មកក្រុមភ្លេងវាយស្គរទោន ផ្លុំខ្លុយ និងអ្នកច្រៀងដើរតាមក្រោយៗ អ្នកហែហមសែនដង្ហោ ធំពីព្រៃជ្រៃទៅព្រៃក្រវាញ ដែលមានចម្ងាយប្រហែល៥០០ម៉ែត្រ។

បន្ទាប់មកអ្នកភូមិដែលជាកូនចៅបានសង់រោង និងធ្វើរានដោយប្រក់ស្លឹកខ្ទង់ ស្លឹករណ្ដាស សម្រាប់ស្នាក់នៅ និងសែនព្រេននៅអំឡុងពេលបេះផ្លែក្រវាញ។

រោងរបស់ដង្ហោត្រូវសង់នៅខាងលើទឹក (ក្បាលទឹក)។ ចំណែកអ្នកភូមិដែលជាកូនចៅត្រូវសង់រោងស្នាក់នៅពីក្រោម និងព័ទ្ធជុំវិញទឹក ដូចជាអូរជំនាប់ទឹកចេញ។ កូនចៅដែលជាមនុស្សជំនិតដង្ហោធំបានធ្វើរានទុកសម្រាប់សែនអ្នកតា សម្អាតកន្លែងទុកឱ្យលេងភ្លេងនៅពេលរាត្រីជាដើម។ ព្រៃក្រវាញមានចំនួន ១៧ហុង ហើយក្នុងនោះមានព្រៃក្រវាញមួយហុងឈ្មោះព្រៃពងមាស ត្រូវទុកសម្រាប់តែដង្ហោធំ និងដង្ហោសំណែន២នាក់ទៀតប៉ុណ្ណោះ គឺមិនអនុញ្ញាតឱ្យអ្នកភូមិដែលជាកូនចៅចូលបេះឡើយ។ ចំណែកដង្ហោធំគឺត្រូវសាច់ញាតិឬកូនចៅជំនិតចូលបេះទុកឱ្យ ពីព្រោះដង្ហោធំត្រូវនៅអង្គុយឃុំគ្រងកូនចៅ អុជធូប ទៀន ពេញរយៈពេលនៃពិធីបេះផ្លែក្រវាញនេះ។

**ក្នុងរយៈពេលនៃការបេះផ្លែក្រវាញនេះមានត្រណមមួយចំនួនដូចខាងក្រោម៖**

ទី១) ពេលកូនចៅសង់រោង និងធ្វើរាន សម្រាប់ស្នាក់នៅ និងសែនព្រេនហាមមិនឱ្យអូសឈើវល្លិ ឬផ្តៅចូលមកកន្លែងសាងសង់ឡើយ។ កូនចៅត្រូវលីឬសែងឈើមកកន្លែងសាងសង់។ ចំណែកវល្លិ និងផ្ដៅត្រូវឆ្វាយជារង្វេលហើយស្ពាយចូលមកកន្លែងសាងសង់។

ទី២) ដង្ហោធំត្រូវប្រកាន់ត្រណមយ៉ាងតឹងរឹង និងមិនអាចងូតទឹកក្នុងរយៈពេល៣ថ្ងៃដំបូងនៃការបេះផ្លែក្រវាញឡើយ។

ទី៣) កូនចៅដែលចូលទៅបេះផ្លែក្រវាញត្រូវស្លៀកខោជើងខ្លី តែបើស្លៀកខោជើងវែងត្រូវមូរជើងខោឱ្យដល់ក្បាលជង្គង់។

ទី៤) ពេលបេះផ្លែក្រវាញត្រូវបេះតាមមុខគ្នារៀងៗខ្លួនដោយមិនត្រូវបេះកាត់មុខគ្នាឡើយ។ ពេលបេះពេញក្រមាឬកន្សែងឬកន្ត្រកធ្វើអំពីផ្ដៅ ត្រូវដាក់ផ្គាល់ដីតាមមុខរៀងៗខ្លួន។ បន្ទាប់មកត្រូវដើរទៅកើបដាក់ក្នុងកន្ត្រកធំរែកមកកន្លែងរោងស្នាក់នៅរៀងៗខ្លួន។

ពេលទទួលបានផលក្រវាញរៀងៗខ្លួនហើយអ្នកភូមិដែលជាកូនចៅត្រូវធ្វើរានសម្រាប់ឆ្អើរក្រវាញឱ្យស្ងួត។ រាននោះធ្វើអំពីឈើ និងត្បាញមែកសោមធ្វើរនាបគ្រែសម្រាប់ដាក់ផ្លែក្រវាញកុំឱ្យជ្រុះ និងភ្លើងឆេះជាដើម។

**នៅអំឡុងពេលឆ្អើរផ្លែក្រវាញក៏មានត្រណមចំនួនពីរទៀតដូចខាងក្រោម៖**

ទី១) អ្នកភូមិដែលជាកូនចៅម្នាក់ៗត្រូវឆ្អើរផ្លែក្រវាញមិនឱ្យខ្លោចឬឆេះរានឆ្អើរផ្លែក្រវាញឡើយ។ បើមានខ្លោចឬឆេះរានឆ្អើរផ្លែក្រវាញ អ្នកភូមិដែលជាកូនចៅត្រូវប្រាប់ទៅដង្ហោធំថា ខ្ញុំបានធ្វើឱ្យខ្លោចឬឆេះរានឆ្អើរផ្លែក្រវាញ។ បន្ទាប់មកដង្ហោក្រវាញបានយកដើមក្រវាញវាយអ្នកដែលធ្វើឱ្យខ្លោចឬឆេះរានឆ្អើរផ្លែក្រវាញចំនួនពាររំពាត់។



ជនជាតិដើមភាគតិចព័រនៅស្រុកវាលវែង កំពុងផ្លុំភ្លយនៅខាងមុខផ្ទះបង្កើតទៅសំឡេងយ៉ាងពិរោះ។ «ភ្លយ» គឺជាឧបករណ៍ភ្លេងធ្វើពីផ្លែឃ្លោក, សាយដៀវ, បំពង់ឫស្សី បិទដោយជ័ររម្រោមលាយក្រមួនឃ្មុំ និងចងដោយវល្លិផ្ដៅ ហើយភ្លយត្រូវបានប្រគុំឡើងនៅក្នុងពិធីបុណ្យផ្សេងៗរបស់ជនជាតិដើមភាគតិចព័រ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ជនជាតិដើមភាគតិចព័រនៅស្រុកវាលវែង វាយស្គរដើម្បីប្រគុំជាបទភ្លេងក្នុងពិធីបុណ្យឡើងអ្នកតា ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទី២) នៅក្នុងពេលយប់ក្រុមភ្លេងត្រូវលេងភ្លេងជាប្រចាំចាប់តាំងពីបេះ ឆ្អេរផ្លែក្រវាញរហូតដល់ចប់ ដោយមានអ្នកតាព្រៃគូយចូលរូបជាមួយស្ត្រីម្នាក់ដែលជាកូនចៅបេះផ្លែក្រវាញនេះ។ ការប្រគុំភ្លេងចាប់ផ្តើមពីម៉ោង៧ រហូតដល់ ៩ ឬ១០យប់ ទើបចប់។ ចំណែករានអ្នកតាមានមាន់ស្ងោរ១គូ ស្លាធម៌៤ ជម៨។ រីឯអ្នកភូមិដែលជាកូនចៅមានហូបស្រាសប្បាយក្នុងពេលរាត្រីដែរ។

បើតាមជំនឿរបស់ជនជាតិដើមភាគតិចព័រ ប្រសិនបើជង្ហេរក្រវាញ និងកូនចៅមិនបានអនុវត្តដូចត្រណមដូចខាងលើ ពួកគេនឹងជួបគ្រោះអាសន្នដូចជាត្រូវមុតបន្លា, ពស់ចឹក, ខ្លាស៊ី ឬក៏មានគ្រោះថ្នាក់ផ្សេងៗមិនខាន។

បន្ទាប់ពីបេះក្រវាញចប់សព្វគ្រប់ត្រឡប់មកផ្ទះវិញ ជង្ហេរក្រវាញបានសុំផ្លែក្រវាញពីកូនចៅក្នុងម្នាក់ពី១ទៅ២គីឡូក្រាម ដើម្បីទុកជូនមេស្រុក (មេឃុំស្រែតាំងយ៉) និងមួយចំណែកទៀតសម្រាប់យកមកថ្វាយព្រះមហាក្សត្រនៅទីក្រុងភ្នំពេញ។ នៅពេលនាំយកផ្លែក្រវាញទៅថ្វាយព្រះមហាក្សត្រនៅទីក្រុងភ្នំពេញ មេស្រុកបាននាំយកក្រុមភ្លេង និងជង្ហេរក្រវាញមកជាមួយដើម្បីលេងភ្លេងថ្វាយព្រះមហាក្សត្រចំនួន៣បទនៅក្នុងព្រះបរមរាជវាំង។ ចំណែកអ្នកភូមិដែលជាកូនចៅបានយកផ្លែក្រវាញទៅលក់នៅតាមទីផ្សារឬកន្លែងផ្សេងៗដូចជា អ្នកភូមិអូរសោម-វាលវែងភាគច្រើនបានយកផ្លែក្រវាញទៅលក់នៅផ្សារក្នុងប្រទេសថៃ។ ចំណែកអ្នកភូមិស្រែតាំងយ៉ និងអ្នកភូមិផ្សេងទៀតបានយកផ្លែក្រវាញទៅលក់នៅតាមផ្ទះចិនលក់អីវ៉ាន់ចាបហ៊ួយក្នុងភូមិរបស់ខ្លួន ឬលក់នៅផ្សារលាចក្នុងស្រុកភ្នំក្រវាញ។

ពិធីបេះផ្លែក្រវាញរបស់ជនជាតិដើមភាគតិចព័រនៅឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ត្រូវបានបោះបង់ចាប់តាំងពីប្រទេសកម្ពុជាមានសង្គ្រាមស៊ីវិលនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ និងរបបប្រល័យពូជសាសន៍ប៉ុល ពត (១៩៧៥-១៩៧៩)។ បច្ចុប្បន្ន ជនជាតិដើមភាគតិចព័រ និងប្រជាជនរស់នៅស្រុកភ្នំក្រវាញជាពិសេសក្មេងជំនាន់ក្រោយភាគច្រើនមិនបានដឹងអំពីពិធីបេះផ្លែក្រវាញរបស់ជនជាតិដើមភាគតិចព័រនេះឡើយ។

# មជ្ឈមណ្ឌលចងចាំសហគមន៍ ជនជាតិដើមភាគតិច

*សូ ហ្វារីណា*




*ជនជាតិដើមភាគតិចនៅភូមិពូតាំង ខេត្តមណ្ឌលគិរី ចូលរួមវេទិកាសហគមន៍ ស្តីពីការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

យោងតាមការស្រាវជ្រាវរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ខេត្តនេះមានជនជាតិភាគតិចចំនួន៨ក្រុម គឺជនជាតិព្នង ក្រោល គ្រឹង ស្ទៀង ទំពួន ចារ៉ាយ ថ្មូន កាវ៉ែត ប្រហែល៥០ភាគរយ នៃប្រជាជនសរុប ដែលភាគច្រើនរស់នៅឆ្ងាយពីទីប្រជុំជននិងនៅតាមជ្រលងភ្នំ។ ខេត្តមណ្ឌលគិរី ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦១ ដោយសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដោយកាត់ចេញពីខេត្តក្រចេះ និងមានចម្ងាយ ៣៨២ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ខេត្តមណ្ឌលគិរីមានប្រជាជនចំនួន៩០,៩៨៩ និងមានផ្ទៃដី១៤,២៨៨គីឡូម៉ែត្រការ៉េ។ ខេត្តមណ្ឌលគិរីមានផ្ទៃដីធំជាងគេក្នុងចំណោមខេត្តទាំង២៥របស់ប្រទេសកម្ពុជា ប៉ុន្តែមានដង់ស៊ីតេប្រជាជនតិចជាងគេដោយគិតជាមធ្យមតែ៨នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

ដោយឡែក «ជនជាតិដើមតំបន់ខ្ពង់រាប ឬខ្មែរលើ» ដែលរស់នៅក្នុងខេត្តមណ្ឌលគិរី និងនៅតាមបណ្តាខេត្តមួយចំនួនទៀត គឺជាឈ្មោះដែល សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ប្រទានឱ្យនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដើម្បីបង្រួបបង្រួមជនជាតិខ្មែរ ក្នុងគោលបំណងទទួលបានសុខដុមនីយកម្មជនជាតិក្នុងអំឡុងសង្គ្រាម។



ជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី ឬខ្មែរលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ជនជាតិដើមភាគតិចនៅភូមិពូតាំង ខេត្តមណ្ឌលគិរី ចូលរួមវេទិកាសហគមន៍ ស្តីពីការអប់រំអំពីប្រវត្តិសាស្រ្តខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅអំឡុងពេលសង្រ្គាម ខេត្តមណ្ឌលគិរីគឺជាមូលដ្ឋានឈរជើងរបស់កងកម្លាំងទាំងបីរណសិរ្ស គឺរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០, មូលដ្ឋានឈរជើងដំបូងរបស់ខ្មែរក្រហមនៅទសវត្សរ៍ឆ្នាំ១៩៦០ និងជាផ្នែកមួយនៃផ្លូវលំហូជីមិញ ដែលរងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក្នុងអំឡុងឆ្នាំ១៩៦៤។ ប្រជាជនដែលរស់នៅតំបន់មណ្ឌលគិរីបានទទួលរងនូវការធ្វើបន្សុទ្ធកម្មរបស់ខ្មែរក្រហមយ៉ាងខ្លាំងក្លា ជាពិសេសក្នុងអំឡុងពេលប៉ះទង្គិចគ្នាជាមួយវៀតណាម នៅរវាងពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។

ដោយសារខេត្តមណ្ឌលគិរីគឺជាតំបន់ភ្នំ មានជនជាតិដើមភាគតិចរស់នៅតាំងពីយូរលង់ណាស់មកហើយ និងជាទីតាំងយុទ្ធសាស្រ្តក្នុងការផ្សារភ្ជាប់តំបន់ប្រវត្តិសាស្រ្តសំខាន់ ធម្មជាតិ និងទេសចរណ៍នៅភាគឦសាន ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រេចចិត្តជ្រើសរើសខេត្តមណ្ឌលគិរីដើម្បីបង្កើតមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិចដែលជាសាខាទី១៩ ក្នុងគោលបំណងរក្សាការចងចាំ ស្វែងរកយុត្តិធម៌ ដើម្បីជំរុញឱ្យមានភាពធូរស្បើយសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រហែល៥លាននាក់ ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាល។ ការបង្កើតមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច គឺទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤។

មជ្ឈមណ្ឌលចងចាំសហគមន៍ជាតិដើមភាគតិចមានទីតាំងស្ថិតនៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ភូមិពូតាំងមានប្រជាជន ២៦៩គ្រួសារ ស្មើនឹង១,០៧៩នាក់ ក្នុងនោះមានស្រីចំនួន៥៥៥នាក់ និងប្រុសចំនួន ៥២៤នាក់ និងជាភូមិដែលមានហុងដិវិឆ្លងកាត់។ ជនជាតិពួងមានចំនួន៨០ភាគរយនៃប្រជាជនសរុបក្នុងភូមិ។ អ្នកភូមិពូតាំងមួយចំនួនបានឃើញការមកដល់របស់ខ្មែរក្រហមក្នុងខេត្តមណ្ឌលគិរីដំបូងបង្អស់ បន្ទាប់មកទទួលរងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និងកងទ័ពលន់នល់

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។ អ្នកភូមិមួយចំនួនធ្លាប់ដើរឆ្លងកាត់ផ្លូវលំហូជីមិញដើម្បីចូលរួមចលនាតស៊ូប្រឆាំងនឹងរបបលន់ នល់។ នៅឆ្នាំ១៩៧៦ អ្នកភូមិពូតាំងត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅស្រុកកោះញែក។ បច្ចុប្បន្នទោះបីភូមិពូតាំងស្ថិតនៅត្រឹមប្រាំបីគីឡូម៉ែត្រពីក្រុងសែនមនោរម្យ, មួយគីឡូម៉ែត្រពីភូមិចម្ការតែ ដែលមានជនជាតិភាគតិចចាមរស់នៅច្រើន និងពីរគីឡូម៉ែត្រពីវិហារសាសនាគ្រិស្ត ប៉ុន្តែភូមិនេះហាក់ដូចជានៅឆ្ងាយ ហើយប្រជាជនមានការលំបាកក្នុងការទទួលបានសេវាសង្គម។ ដោយសារហេតុផលនេះហើយ ទើបមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិចបានប្រើប្រាស់ការិយាល័យរបស់ខ្លួនជាទីតាំងសម្រាប់ការសិក្សាស្រាវជ្រាវ អំពីជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគិរី ប្រវត្តិសាស្ត្រខ្មែរក្រហម និងសិក្សាពីទំនាក់ទំនង និងទីតាំងសំខាន់ៗ។

នៅមុនការបង្កើតមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញបញ្ហាប្រឈមនៅក្នុងភូមិនេះ ព្រោះប្រជាជនមានការលំបាកក្នុងការទទួលបានការអប់រំ សុខាភិបាល និងទំនាក់ទំនង ដើម្បីជួយលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ សុខភាព និងការអភិវឌ្ឍន៍នៅក្នុងសហគមន៍របស់ខ្លួន។ នៅក្នុងខេត្តមណ្ឌលគិរីមានអង្គការ និងសមាគមដែលធ្វើការងារបម្រើសហគមន៍ជនជាតិដើមភាគតិចមានចំនួន៩ និងអង្គការអន្តរជាតិមានចំនួន៤។ ភាគច្រើនអង្គការ និងសមាគមទាំងនេះគឺផ្ដោតសំខាន់លើសិទ្ធិដីធ្លីបុរាណ ការអភិរក្សព្រៃឈើ ប្រពៃណី និងវប្បធម៌ អប់រំ សុខភាពយុវជន និងការអភិវឌ្ឍន៍សហគមន៍។ ទោះបីយ៉ាងណា ការងារដែលបម្រើដល់ការចងចាំ យុត្តិធម៌ និងការធូរស្បើយសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានភាពប្រទាក់ក្រឡាគ្នាទៅនឹងកិច្ចការខាងលើ គឺនៅមានកម្រិតនៅឡើយ។ ទំនាក់ទំនងរវាងប្រធានបទ និងការពិភាក្សាស៊ីជម្រៅអំពីទំនាក់ទំនងនេះ ជាពិសេសគឺជនជាតិភាគតិចនិងអំពើប្រល័យពូជសាសន៍ គឺជាចំណុចសំខាន់ដែលឈានទៅរកការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវចំពោះអតីតកាល និងកសាងអនាគតកាន់តែប្រសើរ គឺ «អនាគតកម្ពុជាដែលគ្មានអំពើប្រល័យពូជសាសន៍»។ មជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច ដែលផ្ដោតលើប្រវត្តិសាស្ត្រ ការចងក្រងឯកសារ និងការអប់រំស្រាវជ្រាវ នឹងធ្វើការពិភាក្សាអំពីទំនាក់ទំនងរវាងប្រធានបទសំខាន់ៗខាងលើ ព្រមទាំងផ្ដល់ជាទីកន្លែងសម្រាប់ការជួបជុំ និងទទួលបានព័ត៌មានដើម្បីជាប្រយោជន៍ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស្ត្រី យុវជន អ្នកសិក្សាស្រាវជ្រាវ និងដៃគូសហការ។

ដើម្បីសម្រេចគោលដៅខាងលើ មជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច បានដាក់ចេញនូវគោលបំណងសំខាន់មួយចំនួនខាងក្រោម ៖

- ជំរុញការសិក្សាស្រាវជ្រាវអំពីជនជាតិដើម និងជនជាតិភាគតិចនៅខេត្តមណ្ឌលគិរីនិងភូមិភាគឦសាន
- ស្វែងយល់ស៊ីជម្រៅអំពីមូលដ្ឋានឈរជើងរបស់ខ្មែរក្រហម និងទំនាក់ទំនងរវាងខ្មែរក្រហមនិងជនជាតិដើមនៅខេត្តមណ្ឌលគិរី និងខេត្តប៉ៃលិនឦសាន
- ចងក្រងឯកសារអំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តមណ្ឌលគិរី
- ជំរុញការយល់ដឹងអំពីសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនៅក្នុងសហគមន៍
- ផ្សារភ្ជាប់ទីតាំងប្រវត្តិសាស្ត្រ ទេសចរណ៍ និងអប់រំនៅក្នុងខេត្តមណ្ឌលគិរី និងមជ្ឈមណ្ឌលឯកសារកម្ពុជានៅទីតាំងផ្សេងទៀត
- ជំរុញឱ្យមានការអភិវឌ្ឍន៍ភូមិតាមរយៈការផ្ដល់ព័ត៌មានសង្គម និងសុខាភិបាលនិងការរៀបចំវេទិកាពិភាក្សាអំពីភូមិ

## ការងារស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តមណ្ឌលគិរី

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បានមកធ្វើទស្សនកិច្ចសិក្សានៅខេត្តមណ្ឌលគិរីដើម្បី

ពិនិត្យស្ថានភាព និងសិក្សាស្រាវជ្រាវអំពីតំបន់នេះ តាំងពីឆ្នាំ១៩៩៦ រួមមាន៖

- ការប្រមូលឯកសារ និងរូបថតប្រវត្តិសាស្ត្រនៅខេត្តមណ្ឌលគិរី។
- ការស្រាវជ្រាវនិងសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះញែកដើម្បីជួយដល់ការសិក្សាស្រាវជ្រាវអំពីរបបខ្មែរក្រហម។
- ការស្រាវជ្រាវអំពីអត្តសញ្ញាណជនជាតិព្នងនៅឃុំដាក់ដាំ ក្នុងឆ្នាំ២០០៦។
- ការបញ្ចាំងភាពយន្តឯកសារ ដែលជាផ្នែកមួយនៃការងារផ្សព្វផ្សាយអំពីតុលាការខ្មែរក្រហម និងយុត្តិធម៌ នៅវិទ្យាល័យ ហ៊ុនសែនមណ្ឌលគិរី នៅឆ្នាំ២០០៧។
- ការចាក់បញ្ចាំងសាលក្រម ឌុច ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសែនមនោរម្យ ទីរួមខេត្តមណ្ឌលគិរី ទស្សនា នៅឆ្នាំ២០១២។

## ការងារបន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖

ចាប់ពីឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជូនអ្នកស្ម័គ្រចិត្តកម្ពុជារាប់រយនាក់ឱ្យធ្វើការងារជាមួយជនជាតិដើមភាគតិចនៅតំបន់នានាទូទាំងខេត្តមណ្ឌលគិរី រួមមាន៖

- ការចងក្រងឯកសារ តាមរយៈការសម្ភាសន៍និងការថតរូបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងប្រជាជននៅក្នុងសហគមន៍
- ការចែកចាយឯកសារខ្មែរក្រហម ព័ត៌មានសុខភាព និងសង្គម
- ការសិក្សាស្រាវជ្រាវអំពីប្រធានបទតូចៗ ដើម្បីបង្កើនការយល់ដឹងនិងស្វែងរកដំណោះស្រាយចំពោះបញ្ហាក្នុងសហគមន៍
- ការរៀបចំវេទិកាពិភាក្សា និងការអប់រំអំពីប្រវត្តិ-សាស្ត្រ សុខភាព ឧក្រិដ្ឋកម្មឃោរឃៅដែលប្រព្រឹត្តលើជនជាតិដើមភាគតិច ប្រពៃណីវប្បធម៌ជនជាតិដើម យេនឌ័រ និងកសិកម្ម
- ការរៀបចំកម្មវិធីទស្សនកិច្ចទៅកាន់ស្រុកកោះញែក ឃុំដាក់ដាំ (ស្រុកអូររាំង) ផ្សារជនជាតិដើមភាគតិច វិហារសាសនាគ្រិស្ត វិហារសាសនាអ៊ិស្លាម រមណីយដ្ឋានទឹកធ្លាក់ សាលាបឋមសិក្សាពូតាំង មណ្ឌលសុខភាព ចម្ការកាហ្វេ និងចម្ការដំណាំកសិកម្ម និងទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម
- ការបណ្តុះបណ្តាលចំណេះដឹងនិងជំនាញតាមរយៈការអាន ការសរសេរ និងកម្មវិធីកសិកម្ម
- ការរៀបចំកម្មវិធីសម្តែងសិល្បៈ ការតាំងពិព័រណ៍និងការសិក្សាពីប្រវត្តិភូមិ
- កម្មវិធីរចនាប្លង់ស្ថាបត្យកម្ម និងការងាររោងជាង
- ការបោះពុម្ពផ្សាយព្រឹត្តិបត្រ ទស្សនាវដ្តី និងការផ្សព្វផ្សាយ
- ការរៀបចំក្រុមការងារសុខភាពរួមដំណើរដោយវេជ្ជបណ្ឌិត ដេមី វៃយ៍ ដើម្បីចុះទៅស្តាប់បញ្ហាសុខភាពរបស់ប្រជាជន និងបានរៀបចំវេទិកាអប់រំអំពីសុខភាពនៅឯសាលាឃុំដាក់ដាំ ស្រុកអូររាំង។ បន្ទាប់ពីវេទិកានេះ ក្រុមការងារបានចុះទៅពិនិត្យរណ្តៅដែលសេសសល់ពីការទម្លាក់គ្រាប់បែកក្នុងទសវត្សរ៍ ឆ្នាំ១៩៦០។
- ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេចកម្ពុជាបាត់បង់តន្ត្រីរ៉ុក» ជូនប្រជាជនទស្សនា ដើម្បីយល់ដឹងអំពីសិល្បៈ ចម្រៀង និងតន្ត្រី នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលសង្គ្រាម។
- ក្រុមការងារសុខភាព និងមជ្ឈមណ្ឌលសហគមន៍ចងចាំជនជាតិដើមភាគតិចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យខេរី ខេត្តត្បូងឃ្មុំ ចុះពិនិត្យសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលសម្ភាសន៍ដោយអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកកោះញែកចំនួន២០០នាក់។
- ក្រុមការងារមជ្ឈមណ្ឌលសហគមន៍ចងចាំជនជាតិដើមភាគតិចបានពិភាក្សាការងារស្រាវជ្រាវជាមួយចៅសង្កាត់រមនា និងប្រធានភូមិពូតាំង បន្ទាប់មកបានចុះសួរសុខទុក្ខប្រជាជនក្នុងភូមិ។

• ការរៀបចំដំណើរទស្សនកិច្ចសិក្សារបស់ប្រតិភូមកពីប្រទេសអូស្ត្រាលី និងកាណាដា ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដឹកនាំនិងសម្របសម្រួលដោយ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មកកាន់មជ្ឈមណ្ឌលសហគមន៍ចងចាំជនជាតិដើមភាគតិច។

• និស្សិតពីររូបបានគូរប្លង់មជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច នៅខេត្តមណ្ឌលគិរី គឺ ទី១) ឈ្មោះ យ៉ន គីមយ៉ុង និង២) ឈ្មោះ គីម សេង។ និស្សិតទាំងពីររូបបានធ្វើការស្រាវជ្រាវយ៉ាងលម្អិតអំពីប្លង់ស្ថាបត្យកម្ម ដោយធ្វើដំណើរមកកាន់ទីតាំងដើម្បីសិក្សាអំពីប្រពៃណីវប្បធម៌ជនជាតិព្នងរួមមានផ្ទះ, ប្រជាជន, ទម្លាប់រស់នៅ, ទិស, ទឹក, ដី, ភ្លើង, ខ្យល់ និងទេសភាព។ ក្រុមការងារមជ្ឈមណ្ឌលសហគមន៍ជនជាតិដើមភាគ បានរៀបចំកិច្ចការមួយចំនួនដូចជា៖ ការដំឡើងធ្នើរដាក់សៀវភៅ និងឯកសារ ដែលមានចំនួនប្រហែល៥០០សម្រាប់ការសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍។

**មជ្ឈមណ្ឌលសហគមន៍ជនជាតិដើមភាគតិច ចាប់ផ្តើមធ្វើកិច្ចការសំខាន់ៗនិងកំពុងស្វែងរកអ្នកស្ម័គ្រចិត្តដើម្បីបំពេញការងារដូចខាងក្រោម ៖**

- រៀបចំដាក់តម្កល់ឯកសារខ្មែរក្រហម ឌីជីថលប្រចាំភូមិភាគឦសានដើម្បីបម្រើការសិក្សាស្រាវជ្រាវ រៀបចំដំឡើងកំព្យូទ័រដើម្បីសម្រួលដល់ការស្វែងរកឯកសារឌីជីថល
- រៀបចំក្រុមស្ម័គ្រចិត្តចងក្រងឯកសារ និងស្រាវជ្រាវដោយបញ្ចូលក្រុមការងាររោងជាង
- ធ្វើបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងចងក្រងជាអត្ថបទនិងវីដេអូឯកសារអំពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសហគមន៍ជនជាតិដើមភាគតិច
- រៀបចំវេទិកាសហគមន៍ជាមួយសិស្សសាលាបឋមសិក្សាដែលដឹកនាំដោយលោកគ្រូអ្នកគ្រូ ស្តីពីចំណេះដឹងភូមិ នៅឯមជ្ឈមណ្ឌលសហគមន៍ជនជាតិដើមភាគតិច។
- អញ្ជើញអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាចាស់ព្រឹទ្ធាចារ្យ ដើម្បីចែករំលែកសាច់រឿងជាមួយសិស្ស។
- ផ្សព្វផ្សាយអំពីកិច្ចការមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិចឱ្យបានទូលំទូលាយ។
- រៀបចំសួន និងសិក្សាឈ្វេងយល់អំពីដំណាំកសិកម្ម។



ក្រុមការងារមជ្ឈមណ្ឌលចងចាំសហគមន៍ជនជាតិដើមភាគតិច នៅភូមិពូតាំង ខេត្តមណ្ឌលគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





សិស្សសាលានៅខេត្តមណ្ឌលគិរី ចូលរួមវេទិកាសហគមន៍ ស្តីពីការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហោអដ្ឋិធាតុវត្តលង្កា ប្រគល់អដ្ឋិធាតុជូនក្រុមគ្រួសារដើម្បីរៀបចំធ្វើបុណ្យនិងរក្សាទុក

*រស់ សំពៅ*





លោក សំរិត ចាន់ណារ័ត្ន ត្រូវជាប្តី និងលោក សំរិត សុមនោ ត្រូវជាកូន មកទទួលអដ្ឋិធាតុឈ្មោះ ពៅ ចាន្ទី ពីលោក រស់ សំពៅ ប្រធានហោអដ្ឋិធាតុ ឬបណ្ណាល័យធាតុ នៅវត្តលង្កា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៦:៤៥នាទីព្រឹក ថ្ងៃអាទិត្យទី៦ ខែកក្កដា ឆ្នាំ២០២៥ ហោអដ្ឋិធាតុ ឬ បណ្ណាល័យធាតុ នៅវត្តលង្កា ដែលផ្តួចផ្តើមសាងសង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងមានការគាំទ្រពីសម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចាន់ថុល្ល និងគណៈកម្មការគ្រប់គ្រងវត្តលង្កា បានប្រគល់អដ្ឋិធាតុឈ្មោះ ពៅ ចាន្ទី ជូនលោក សំរិត ចាន់ណារ័ត្ន ត្រូវជាស្វាមី និងលោក សំរិត សុមនោ ត្រូវជាកូនប្រុស ព្រមទាំងសមាជិកក្រុមគ្រួសារនិងចៅស្រីនៃអដ្ឋិធាតុមួយចំនួនទៀត ដើម្បីរៀបចំធ្វើបុណ្យ និងយកទៅតម្កល់ទុកក្នុងចេតិយ នៅវត្តស្រុកកំណើតរបស់ខ្លួន។

កោដ្ឋដាក់អដ្ឋិធាតុលេខ៨០៥ មានឈ្មោះ ពៅ ចាន្ទី ភេទស្រី បានស្លាប់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩២ ដោយជំងឺមហារីក។ លោកស្រី ពៅ ចាន្ទី (អដ្ឋិធាតុលេខ៨០៥ ក្នុងបញ្ជីអដ្ឋិធាតុ) មានស្រុកកំណើត ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

ស្វាមីរបស់អដ្ឋិធាតុលេខ៨០៥ មានឈ្មោះ សំរិត ចាន់ណារ័ត្ន អាយុ៦០ឆ្នាំ ស្រុកកំណើត ឃុំកោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។ ក្រោយបានរៀបអាពាហ៍ពិពាហ៍ជាមួយភរិយាឈ្មោះ ពៅ ចាន្ទី លោកសំរិត ចាន់ណារ័ត្ន ទទួលបានកូនប្រុសម្នាក់

ឈ្មោះ សំរិត សុមនោ ដែលជាកូនទោលក្នុងគ្រួសារ។ សព្វថ្ងៃនេះ សំរិត សុមនោ មានភរិយានិងមានកូនស្រីពីរនាក់ ហើយរស់នៅក្នុងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ថ្មីៗនេះ ក្រោយបានប្រកាសព័ត៌មានជាសាធារណៈតាមបណ្ដាញសារព័ត៌មានជាតិ និងអន្តរជាតិ នៅក្នុងថ្ងៃទិវាជាតិនៃការចងចាំ "អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្នុងរបបខ្មែរក្រហម" នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លោក សំរិត សុមនោ ដែលជាកូនប្រុសរបស់អដ្ឋិធាតុឈ្មោះ ពៅ ចាន្ទី បានស្នើសុំអនុញ្ញាតចូលមកស្វែងរកអដ្ឋិធាតុនៃមនុស្សជាទីស្រឡាញ់របស់ខ្លួន នៅក្នុងហោអដ្ឋិធាតុ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំបង្កើតឡើងនៅក្នុងវត្តលង្កា ព្រះកុសមារាម។

កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ លោក សំរិត សុមនោ ជាកូនប្រុសរបស់អដ្ឋិធាតុលេខ៨០៥ បានមកស្វែងរកអដ្ឋិធាតុរបស់ម្ដាយឈ្មោះ ពៅ ចាន្ទី តាមរយៈការផ្ទៀងផ្ទាត់ឈ្មោះក្នុងបញ្ជីលេខរៀង និងឈ្មោះនៃអដ្ឋិធាតុទាំង៨៦៨នាក់ នៅក្នុងហោអដ្ឋិធាតុ នៃវត្តលង្កា ព្រះកុសមារាម។

គួររំឭកផងដែរថា ក្នុងឆ្នាំ២០១៥ មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រមែប្រមូលរក្សាទុកនូវអដ្ឋិធាតុជនរងគ្រោះកម្ពុជាចំនួន៨៦៨នាក់ ដែលបានស្លាប់ក្នុងសង្គ្រាមនៃទសវត្សរ៍ឆ្នាំ១៩៧០, ១៩៨០, និង១៩៩០ដែលអដ្ឋិធាតុទាំងអស់នេះមិនឃើញមានសាច់ញាតិមកយកទៅថែរក្សាទុក ហើយស្ថិតនៅរាយប៉ាយក្នុងបរិវេណវត្តលង្កា ព្រះកុសមារាម នៃរាជធានីភ្នំពេញ។ អដ្ឋិធាតុជនរងគ្រោះកម្ពុជាទាំង៨៦៨នាក់នេះ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលមករក្សាទុកនៅក្នុងហោអដ្ឋិធាតុដែលមានទីតាំងស្ថិតក្នុងវត្តលង្កា ព្រះកុសមារាម សម្រាប់គោលបំណងពីរសំខាន់មួយ គឺជាកំបម្រើជូនដល់សាធារណជនទូទៅ ដើម្បីស្វែងរកមនុស្សជាទីស្រឡាញ់របស់ខ្លួន (ការស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន) និងដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃអដ្ឋិធាតុជនរងគ្រោះទាំងអស់ទៅតាមប្រពៃណីនៃព្រះពុទ្ធសាសនា។





ក្រុមគ្រួសារលោក សំរិត ចាន់ណារ័ត្ន និងលោក សំរិត សុមនោ ដែលត្រូវជាប្ដី និងត្រូវជាកូនរបស់ឈ្មោះ ពៅ ចាន្ទី សូត្រមន្តបង្សុកូលនៅហោអដ្ឋិធាតុ ឬបណ្ណាល័យធាតុ នៅវត្តលង្កា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សមកពីអង្គការដើម្បីភាពញញឹមនៃកុមារ មកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**សោម ប៊ុនថន**




*សិស្សមកពីអង្គការដើម្បីភាពញញឹមនៃកុមារចំនួន៤០នាក់ មកទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥ សិស្សថ្នាក់ទី១០ ចំនួន៤០នាក់ ដឹកនាំដោយលោកគ្រូអ្នកគ្រូចំនួន៥នាក់ មកពីអង្គការដើម្បីភាពញញឹមនៃកុមារ ដែលមានទីតាំងនៅសង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ បានមកទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ សិស្សទាំងនេះភាគច្រើនមានជីវភាពខ្វះខាត និងត្រូវបានជ្រើសរើសចេញពីក្រុមគ្រួសារដែលរស់នៅតាមកន្លែងចាក់សំរាមក្នុងទីក្រុងភ្នំពេញ និងមួយចំនួនទៀតជ្រើសចេញពីក្រុមគ្រួសារដែលកំព្រាឪពុកម្តាយ និងមានឪពុកម្តាយប្រើអំពើហិង្សា, ធ្វើចំណាកស្រុក និងធ្វើជាកម្មករនៅតាមរោងចក្រ សហគ្រាស ដែលគ្មានលទ្ធភាពថែទាំកូន និងបញ្ជូនកូនឱ្យទៅសិក្សារៀនសូត្រ។

ទស្សនកិច្ចសិក្សានេះ មានគោលបំណងដើម្បីឱ្យសិស្សសិក្សាស្វែងយល់អំពីកិច្ចការរបស់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្តោតសំខាន់លើសិក្សាស្រាវជ្រាវ ប្រមែប្រមូល ចងក្រង បោះពុម្ពផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រ



សិស្សមកពីអង្គការដើម្បីភាពញញឹមនៃកុមារចំនួន៤០នាក់ មកទស្សនកិច្ចព្រះរាជបណ្ណាល័យ ហួងម៉ៃ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)






កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងប្រវត្តិសាស្ត្រកម្ពុជាទូទៅ។ លោក ឆាំង យុ និងក្រុមការងាររបស់ព្រះរាជបណ្ណាល័យ ហួងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន៖ អ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក រស់ សំពៅ ប្រធានព្រះរាជបណ្ណាល័យ ហួងម៉ៃ, បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងលោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានស្វាគមន៍ និងធ្វើបទបង្ហាញសង្ខេបអំពីកិច្ចការរបស់ព្រះរាជបណ្ណាល័យ ហួងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅតាមសាលាចំណេះដឹងទូទៅរបស់រដ្ឋ និងឯកជន និងនៅតាមមូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា ព្រមទាំងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម។ បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជាមានសាខាចំនួន១៩ ទីតាំងនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា ដែលមាននិស្សិតស្ម័គ្រចិត្តចំនួន ៣,៤៦៤នាក់ ធ្វើការងារផ្តោតសំខាន់លើប្រវត្តិសាស្ត្រ និងសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៦១,៦២៥នាក់ ដែលបានជួបសម្ភាសន៍កន្លងមក។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ ក្រុមការងារព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមានការបែងចែកសិស្សជាក្រុមពិភាក្សាការទស្សនាពិព័រណ៍អំពីដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមរយៈពេល១៦ឆ្នាំ និងបានផ្តល់ឱកាសឱ្យសិស្សមកពីអង្គការដើម្បីភាពញញឹមនៃកុមារសួរសំណួរចំនួន៣០សំណួរ ទាក់ទងនឹងរបបខ្មែរក្រហម ដើម្បីអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួនៗ បន្ទាប់មក ក្រុមការងារព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), សៀវភៅកំណត់ហេតុរបស់ហ្វូងម៉ែ និងអាវយឺតដល់សិស្សគ្រប់ៗគ្នា។





សិស្សមកពីអង្គការដើម្បីភាពញញឹមនៃកុមារចំនួន៤០នាក់មកទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គការដើម្បីភាពញញឹមនៃកុមារ បង្កើតឡើងដោយជនជាតិបារាំងឈ្មោះ គ្រីស្យង់ ហ្គោកឺ ឡាំងដេប៉ាលីយ៉ែរ នៅឆ្នាំ១៩៩៦។ លោក គ្រីស្យង់ ហ្គោកឺ ឡាំងដេប៉ាលីយ៉ែរ និងភរិយាអ្នកស្រី ម៉ារី ហ្វ្រង់ ដេប៉ាលីយ៉ែរ បានបង្កើតអង្គការមិនយកប្រាក់កម្រៃនេះឡើង ដើម្បីជួយឧបត្ថម្ភដល់ការថែទាំ និងការអប់រំដល់ក្មេងអនាថា ក្មេងរើសសំរាមនៅស្ទឹងមានជ័យ និងក្មេងក្រីក្រជាងមួយម៉ឺននាក់ ចាប់តាំងពីបង្កើតអង្គការនេះដំបូង។ លោក គ្រីស្យង់ ហ្គោកឺ ឡាំងដេប៉ាលីយ៉ែរ បានទទួលមរណភាពនៅឆ្នាំ២០១៦ ប៉ុន្តែបេសកម្មរបស់អង្គការដើម្បីភាពញញឹមនៃកុមារនៅតែបន្តក្នុងគោលបំណងដើម្បីជួយដល់កុមារ យុវជន និងគ្រួសារក្រីក្របំផុត ដោយផ្តោតសំខាន់លើការផ្តល់អាហារ ការព្យាបាល ការការពារ ការជួយសង្គ្រោះ និងថែទាំ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការឧបត្ថម្ភដល់គ្រួសារក្នុងករណីបន្ទាន់។

បច្ចុប្បន្ន អង្គការដើម្បីភាពញញឹមនៃកុមារបាន និងកំពុងផ្តល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងឧបត្ថម្ភអាហារដល់សិស្សក្រីក្រចំនួន៦៥០០នាក់នៅក្នុងមណ្ឌលភ្នំពេញ និងតាមសាលារដ្ឋមួយចំនួនក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ដោយក្នុងនោះមានសិស្សជាង៤៥០០នាក់បានបញ្ចប់ការសិក្សា និងកំពុងបម្រើការក្នុងទីផ្សារការងារ ដូចជា គ្រូបង្រៀន វិស្វករ ជាងម៉ាស៊ីន ចុងភៅ គណនេយ្យករ និងជាងអ៊ុតសក់។

ក្រៅពីសិក្សានៅក្នុងថ្នាក់ក៏មានកម្មវិធីឱ្យសិស្សទៅទស្សនកិច្ចនៅតាមបណ្តាស្ថាប័នសិក្សាស្រាវជ្រាវ និងអប់រំផ្សេងៗ ដើម្បីឱ្យសិស្សបានស្គាល់ និងសិក្សាឈ្វេងយល់បន្ថែម។

យោងតាមច្បាប់ ស្តីពីការអប់រំ នៅប្រទេសកម្ពុជា ត្រង់មាត្រា១៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ បានចែងថា «ការអប់រំចំណេះដឹងទូទៅ» គឺជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា ឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន។

# សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ក្តុលផ្សារ មកសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម

**ឌី ស៊ីថា**



សិស្សមកពីវិទ្យាល័យ ហ៊ុនសែន ក្តុលផ្សារ មកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ សិស្សានុសិស្សចំនួន៧ នាក់ ក្នុងនោះមានប្រុសម្នាក់ នៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ក្តុលផ្សារ បានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងគោលបំណងសិក្សាស្វែងយល់អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម និងព្រឹត្តិការណ៍ថ្មីៗដែលផ្សាភ្ជាប់ទៅនឹងរឿងអតីតកាល។

ជាកិច្ចចាប់ផ្តើមបុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មរី ស៊ីថា បានធ្វើការណែនាំខ្លួន និងរៀបរាប់អំពីការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ទាប់មកទៀត ស៊ីថា បានលើកផែនទីរណ្តៅសាកសព (ពីឆ្នាំ១៩៧៥-១៩៧៩) ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅស្រាវជ្រាវដល់ទីកន្លែង និងបានកំណត់រណ្តៅសាកសពទូទាំងប្រទេស បង្ហាញទៅកាន់សិស្សានុសិស្ស។ គួររំឭកថាមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញវាលពិឃាតចំនួន៣៩០កន្លែង ដែលរួមមាន១៩,០០០រណ្តៅ (មជ្ឈមណ្ឌលឯកសារ

កម្ពុជា ឱ្យនិយមន័យលើពាក្យវាលពិឃាត ថាជារណ្តៅដែលផ្ទុកសាកសពចាប់ពី៤នាក់ទៅដល់ជាង១ពាន់នាក់), ទីតាំងមន្ទីរសន្តិសុខ(គុក) ចំនួន១៩៧កន្លែង និងបូជនីយដ្ឋានចំនួន៨១កន្លែង។ ផ្សារភ្ជាប់ជាមួយទីតាំងគុកខាងលើ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ អង្គការយូណេស្កូ បានអនុម័តជាផ្លូវការបញ្ចូលទីតាំងឧក្រិដ្ឋកម្ម ចំនួន៣កន្លែង ទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក ដែលមានឈ្មោះជារួម «បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព» ដែលបានស្នើដោយរាជរដ្ឋាភិបាលកម្ពុជា។ ទីតាំងឧក្រិដ្ឋកម្មចំនួន៣នេះ រួមមាន៖ ១) អតីតមន្ទីរឃុំឃាំង ម-១៣ ស្ថិតនៅព្រំប្រទល់ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ, ២) សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ស-២១) និង ៣) មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ស្ថិតនៅរាជធានីភ្នំពេញ។

បន្ទាប់មកទៀត សិស្សានុសិស្សបានសិក្សាអំពីបណ្តុំរូបភាពនៅក្នុងរបបខ្មែរក្រហមចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩, ផ្ទាំងរូបភាពក្រោយរបបខ្មែរក្រហមដួលរលំក្នុងខែមករា ឆ្នាំ១៩៧៩ និងផ្ទាំងរូបភាពប្រជាជនកម្ពុជាបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ ផ្ទាំងពិព័រណ៌បង្ហាញពីស្ថានភាពប្រជាជនកម្ពុជាមានសេរីភាពក្នុងការគោរពសាសនា និងប្រកបមុខរបររកស៊ី ក្រោយរបបខ្មែរក្រហមដួលរលំ, ចំណែកកុមារបានត្រឡប់ទៅសាលារៀនវិញ, ក្រុមការងារស្រាវជ្រាវរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាបានគាស់រណ្តៅដើម្បីរើសឆ្អឹងជនរងគ្រោះដែលខ្មែរក្រហមវាយសម្លាប់ ស្ទើរពាសពេញផ្ទៃប្រទេសកម្ពុជា ដើម្បីរៀបចំពិធីបង្សុកូលឧទ្ទិសកុសលជូនដល់អ្នកស្លាប់នៅក្នុងរបបខ្មែរក្រហម។

**ជាចុងក្រោយ សិស្សានុសិស្សបានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖**

**ផាន ពិសិដ្ឋ** ភេទប្រុស អាយុ១៨ឆ្នាំ រៀនថ្នាក់ទី៧ នៃសាលាវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ក្តុលផ្សារ រៀបរាប់ថា ខ្ញុំពិតជាមានអារម្មណ៍រំភើបខ្លាំងណាស់ ដែលបានដឹងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រ ប៉ុន្តែខ្ញុំតក់ស្លុត និងអាណិតអាសូរនៅពេលឃើញឆ្អឹងប្រជាជនខ្មែរជាច្រើន ដែលត្រូវបានខ្មែរក្រហមកាប់សម្លាប់។ ខ្ញុំនឹងខិតខំប្រឹងប្រែងរៀនសូត្រប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនឱ្យបានច្រើន និងរួមសាមគ្គីគ្នាដើម្បីកសាងប្រទេសជាតិឱ្យរីកចម្រើន។

**តភា រីណា** ភេទស្រី អាយុ១៣ឆ្នាំ រៀនថ្នាក់ទី៧ នៃសាលាវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ក្តុលផ្សារ លើកឡើងថា ខ្ញុំចាប់អារម្មណ៍ទៅលើរូបភាពឆ្អឹងដែលបន្សល់ទុកពីរបបខ្មែរក្រហម។ ក្រោយពេលឃើញរូបភាពទាំងនេះ ខ្ញុំអាណិតប្រជាជនដែលត្រូវបានខ្មែរក្រហមធ្វើបាប និងសម្លាប់យ៉ាងឃោរឃៅ។ ជាចុងក្រោយ ខ្ញុំមិនចង់ឱ្យរបបខ្មែរក្រហមកើតឡើងម្តងទៀតទេ។





សិស្សមកពីវិទ្យាល័យ ហ៊ុនសែន ក្តុលផ្សារ មកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សអនុវិទ្យាល័យលំទង មកអានឯកសារ និងស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

**សួត វិចិត្រ**



*សិស្សមកពីអនុវិទ្យាល័យលំទង មកអានឯកសារ និងស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ សិស្សចំនួន ៦នាក់ ក្នុងនោះមានស្រីចំនួន៣នាក់ មកពីអនុវិទ្យាល័យលំទងបានមកអានឯកសារ និងស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាទីកន្លែងសិក្សាស្រាវជ្រាវ និងរក្សាទុកឯកសារប្រវត្តិ-សាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ កន្លងមកមានសិស្សានុសិស្សអ្នកស្រាវជ្រាវជាតិ អន្តរជាតិ គ្រប់ទិសទីបានធ្វើដំណើរមកកាន់មជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែងដើម្បីមកសិក្សាស្វែងយល់រឿងរ៉ាវដែលបានកើតឡើងនៅតំបន់នេះកាលពីអតីតកាល។

ជាកិច្ចស្វាគមន៍បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើបទបង្ហាញនិងពិភាក្សាជាមួយសិស្សានុសិស្សជុំវិញរឿងរ៉ាវ និងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៥

និងឆ្នាំ១៩៧៩ ថាតើសិស្សានុសិស្សបានដឹងអ្វីខ្លះអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម។ ក្នុងចំណោមសិស្សទាំងប្រាំមួយនាក់ គឺម្នាក់ៗសុទ្ធតែបានដឹងពត៌មានពីព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម តាមរយៈឪពុកម្ដាយ និងជីដូនជីតារបស់ខ្លួនដែលបានឆ្លងកាត់ដោយផ្ទាល់។ ទន្ទឹមនឹងការពិភាក្សានេះ វាគ្មិនក៏បានផ្ដល់ឱកាសដល់សិស្សានុសិស្សក្នុងការចោទជាសំណួរដែលខ្លួនចង់ដឹងដូចតទៅ៖ តើនៅក្នុងសម័យខ្មែរក្រហមហេតុអ្វីបានជាមានការសម្លាប់ប្រជាជនខ្មែរខ្លួនឯង? តើមូលហេតុអ្វីបានជាកើតមានរបបខ្មែរក្រហម? តើរបបខ្មែរក្រហម នរណាជាអ្នកគ្រប់គ្រង? តើនៅក្នុងរបបខ្មែរក្រហមការរស់នៅបែបណា? តើប្រជាជនប្រកបរបរអ្វីក្នុងរបបខ្មែរក្រហម? តើនៅក្នុងរបបខ្មែរក្រហមការដាក់ទោសប្រជាជនធ្វើបែបណាខ្លះ? តើប្រជាជនរស់នៅក្នុងរបបខ្មែរក្រហមត្រូវជួបបញ្ហាអ្វីខ្លះ? តើរបបខ្មែរក្រហមមានអ្នកដឹកនាំប៉ុន្មាននាក់? និងមានឈ្មោះអ្វី? តើរបបខ្មែរក្រហមចាប់ផ្ដើមពីថ្ងៃណា ហើយបញ្ចប់ទៅវិញនៅថ្ងៃណា? តើនៅក្នុងរបបខ្មែរក្រហមមានច្បាប់អ្វីខ្លះ? ភ្លាមៗនោះ វាគ្មិនបានឆ្លើយតបនឹងសំណួររបស់សិស្សានុសិស្សជាបន្តបន្ទាប់បានយ៉ាងក្បោះក្បាយ។ សិស្សានុសិស្សក៏បានកត់ត្រានូវចម្លើយទុកនៅក្នុងសៀវភៅរៀងៗខ្លួន។ បន្ទាប់មកទៀតវាគ្មិន បានធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្សអំពីរូបថតព្យួរនៅជញ្ជាំង ដែលមានរូបភាពមេដឹកនាំធំៗក្នុងរបបខ្មែរក្រហម ទាំងប្រាំរូប រួមមាន នួនជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ និង កាំង ហ្គេចអ៊ាវ (ហៅ ឌុច)។

បន្ថែមលើនេះ បណ្ឌិត លី សុខឃាង ក៏បានលើកយកតំបន់ប្រវត្តិសាស្ត្រសំខាន់ៗដែលជាទីកន្លែងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកសិក្សាស្រាវជ្រាវ និងមកកម្សាន្តក្នុងស្រុកអន្លង់វែង។ ជាពិសេស គឺការកែប្រែតំបន់អន្លង់វែងឱ្យក្លាយទៅជាទីក្រុងតូចមួយ ដោយមានការរៀបចំបង្កើតទីកន្លែងទេសចរណ៍ភ្ជាប់ជាមួយតំបន់ប្រវត្តិសាស្ត្រ និងមានភោជនីយដ្ឋាន ប្រព័ន្ធទឹក ផ្លូវ សំណង់អាគារ ពេងចក្រ និងប្រជាជនជាដើម។ ចំណុចទាំងអស់នេះបានធ្វើឱ្យភ្ញៀវទេសចរមកដល់អន្លង់វែង មានភាពសប្បាយរីករាយ និងចងចាំមិនភ្លេចអំពីតំបន់នេះ។ ចំណែកប្រជាជននៅតាមមូលដ្ឋានអាចទទួលបានផលកម្រៃពីភ្ញៀវទេសចរ បន្តឱ្យប្រជាជនមានជីវភាពធូរធារជាងមុនមួយកម្រិត។

នៅចុងបញ្ចប់នៃបទបង្ហាញសិស្សានុសិស្សបានសម្ដែងនូវការអរគុណដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានបង្កើតកម្មវិធីបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្នុងគោលបំណងពង្រឹងចំណេះដឹងបន្ថែមដល់សិស្ស។ បន្ថែមពីនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានផ្ដល់ឱកាសដល់សិស្សានុសិស្សបានមកសិក្សាស្រាវជ្រាវ និងអានឯកសារខ្មែរក្រហមដែលបានរក្សាទុកនៅមជ្ឈមណ្ឌលនេះ»។

បន្ទាប់ពីទស្សនា «រូបថតគម្រោងអភិវឌ្ឍន៍ទីតាំងអន្លង់វែងទៅជាកន្លែងទេសចរណ៍» សិស្សានុសិស្សទាំង៦នាក់បានសម្ដែងការយល់ឃើញរបស់ខ្លួនដូចខាងក្រោម៖

**សៀន លីឆាង** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី៨ នៃអនុវិទ្យាល័យលំទង បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា «ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានមកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំពិតជាសរសើរដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានបង្កើតកន្លែងស្រាវជ្រាវនេះឡើង ដែលធ្វើឱ្យខ្ញុំយល់ដឹងកាន់តែច្បាស់បន្ថែមទៀតពីប្រវត្តិសាស្ត្ររបស់ខ្មែរ»។

**ចិន ពៅ** ភេទប្រុស អាយុ១៨ឆ្នាំ បានលើកឡើងថា «ក្រោយពីបានសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួចមក ខ្ញុំគិតថានៅក្នុងរបបនេះមានច្បាប់តឹងតែងខ្លាំងណាស់ ធ្វើឱ្យមានការកាប់សម្លាប់ប្រជាជនជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ ខ្ញុំក៏មានអារម្មណ៍រីករាយដែលបានចូលរួមសិក្សាពីប្រវត្តិសាស្ត្រ

ប្រទេសកម្ពុជា ដើម្បីឱ្យខ្ញុំបានយល់ដឹងកាន់តែច្រើនអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំពិតជាចង់ឱ្យស្រុកអន្លង់វែងទាំងមូលមានភាពរីកចម្រើន និងអភិវឌ្ឍន៍លើគ្រប់វិស័យ»។

**ភី ស្រីនុត** ភេទស្រី អាយុ១៣ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា «បន្ទាប់ពីបានសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមរួចមក ខ្ញុំខ្លាចផង រាជាពន់ពេក ព្រោះនៅក្នុងរបបនេះតឹងរឹងក្នុងការហូបចុក កាប់សម្លាប់គ្នា និងមិនមានភាពសាមគ្គីគ្នា។ ទោះបីជាយ៉ាងណា ខ្ញុំក៏មានការសប្បាយចិត្តដែលបានសិក្សាពីប្រវត្តិសាស្ត្រដ៏ជូរចត់នេះ និងបានដឹងពីការរស់នៅរបស់ប្រជាជននាពេលនោះ។ បន្ថែមពីនេះ ខ្ញុំចង់ឱ្យគ្រប់បណ្តាខេត្ត និងស្រុកដែលនៅជាប់ព្រំដែនទូទាំងប្រទេសកម្ពុជាមានភាពរីកចម្រើននាថ្ងៃអនាគត»។

**រិន នីសា** ភេទស្រី អាយុ១៤ឆ្នាំ បានយល់ឃើញថា «នៅក្នុងរបបខ្មែរក្រហម ពិតជាមានការលំបាកខ្លាំងណាស់តាំងពីការធ្វើការងារ ការហូបចុក បែកបាក់ក្រុមគ្រួសារ ជាពិសេសធ្វើឱ្យប្រជាជនបាត់បង់ជីវិតជាច្រើននាក់។ កុមារមិនបានទទួលការសិក្សារៀនសូត្រ កូនមិនអាចជួបម្តាយ និងត្រូវរស់នៅដាច់ដោយឡែកពីគ្នា។ ខ្ញុំសង្ឃឹមថានៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែងនឹងមានការអភិវឌ្ឍន៍ និងជាកន្លែងសម្រាប់ភ្ញៀវមកទស្សនា និងកម្សាន្តនៅពេលខាងមុខ»។

**ហ៊ាង រ៉ាយុទ្ធ** ភេទប្រុស អាយុ១៤ឆ្នាំ បានលើកឡើងពីអារម្មណ៍ផ្ទាល់ខ្លួនថា «របបខ្មែរក្រហមពិតជាមានភាពសាហាវឃោរឃៅខ្លាំងណាស់ ព្រោះបានសម្លាប់មនុស្សគ្មានកំហុសជាច្រើនលាននាក់ ព្រមទាំងមានការធ្វើទារុណកម្មយ៉ាងឃោរឃៅបំផុត។ ចំពោះគម្រោងអភិវឌ្ឍន៍ក្នុងស្រុកអន្លង់វែងដែលប្រែក្លាយតំបន់នេះទៅជាទីក្រុង និងកន្លែងសេដ្ឋកិច្ច ធ្វើឱ្យខ្ញុំសប្បាយចិត្តណាស់ព្រោះជាស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំស្រមៃថាអន្លង់វែងនឹងអាចក្លាយទៅជាទីក្រុងដ៏ស្រស់ស្អាតនាថ្ងៃអនាគត។

**ស៊ិន សុផាត** ភេទប្រុស អាយុ១៣ឆ្នាំ បានលើកឡើងថា «ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងបានយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពរស់នៅ ការធ្វើការងារ ការហូបចុករបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម។ នៅថ្ងៃអនាគត ខ្ញុំចង់ឃើញប្រទេសជាតិ ក៏ដូចជាស្រុកអន្លង់វែងមានការរីកចម្រើន»។







សិស្សមកពីអនុវិទ្យាល័យលំទង មកអានឯកសារ និងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទីតាំងឧក្រិដ្ឋកម្ម៣កន្លែងត្រូវដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោករបស់អង្គការយូណេស្កូ

**អេង សុខម៉េង**




*អតីតមន្ទីរសន្តិសុខស-២១ (ប៉ុកកុកទួលស្លែង)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ អង្គការយូណេស្កូ បានអនុម័តជាផ្លូវការបញ្ចូល ទីតាំងឧក្រិដ្ឋកម្មចំនួន៣កន្លែង ទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក ដែលមានឈ្មោះជារួម «បូជនីយដ្ឋានបងចាំនៃកម្ពុជា ៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព» ដែលបានស្នើដោយរាជរដ្ឋាភិបាលកម្ពុជា។ ទីតាំងឧក្រិដ្ឋកម្មចំនួន៣នេះរួមមាន ៖ ១) អតីតមន្ទីរឃុំឃាំង ម-១៣ ស្ថិតនៅព្រំប្រទល់ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ, ២) សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ស-២១) និង ៣) មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ស្ថិតនៅរាជធានីភ្នំពេញ។

## ១) អតីតមន្ទីរឃុំឃាំងម-១៣

យោងតាមគម្រោងស្រាវជ្រាវទីតាំងឧក្រិដ្ឋកម្មរបបខ្មែរក្រហម របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មន្ទីរម-១៣ ស្ថិតនៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង

ខេត្តកំពង់ស្ពឺ ជាមន្ទីរដែលបានបង្កើតឡើងដោយចលនាតស៊ូខ្មែរក្រហម ដើម្បីសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់លើអ្នកទោសដែលខ្មែរក្រហមចោទថាជាគិញមកពីតំបន់ដែលគ្រប់គ្រងដោយ លន់ នល់ ។ កាំង ហ្កេចអ៊ាវ ហៅ ឌុច គឺជាប្រធានមន្ទីរនេះ និងបានស្លាប់កាលពីឆ្នាំ២០២០ បន្ទាប់ពីត្រូវបានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ឌុច ធ្លាប់បានលើកឡើងក្នុងបន្ទប់សវនាការថាការសម្លាប់ជាគោលការណ៍ចម្បងនៅមន្ទីរនេះ [អតីតមន្ទីរឃុំឃាំងម-១៣] និងបន្តថាបេសកកម្មរបស់គាត់នៅ ម-១៣ គឺការពារប្រជាជននៅតំបន់រំដោះ។ ឌុច ក៏បានលើកឡើងពីគោលបំណងរបស់ម-១៣ គឺជាតម្រូវការរបស់បដិវត្តន៍ខ្មែរក្រហម។ ហម អ៊ិន ដែលជាឆ្មាំនៅអតីតមន្ទីរឃុំឃាំងម-១៣ បាននិយាយថា មនុស្សចំនួន ៣០,០០០នាក់ ត្រូវបានសម្លាប់, ស្លាប់ដោយសារជំងឺ និងស្លាប់ដោយសារទឹកជំនន់នៅ ម-១៣។ គាត់អះអាងថា នេះជាការទទួលខុសត្រូវរបស់ ឌុច តែម្នាក់គត់ ព្រោះបញ្ជារបស់ ឌុច មិនអាចជំទាស់បាន។ មន្ទីរ ម-១៣ គ្រប់គ្រងដោយមនុស្សសំខាន់ៗប្រាំនាក់គឺ ឌុច គឺជាប្រធាន, ចាន់ គឺអនុប្រធាន, ប៉ុន, ផល និង មាស គឺជាសមាជិក ហើយអ្នកទាំងប្រាំនាក់នេះ គឺជា «ជនចម្រើន» របស់បដិវត្តន៍ដែលអង្គការបក្សទុកចិត្តបំផុត។

កងការពារនៅមន្ទីរ ម-១៣ ត្រូវបានចលនាតស៊ូខ្មែរក្រហមជ្រើសរើសតែក្មេងៗ ដែលមានអាយុក្រោម១៥ឆ្នាំ ។ ឌុច ជ្រើសរើសកងការពារដោយផ្ទាល់ ដូចជា ស៊ុម វ៉ុន ហៅ ឌិន, ចាន់ វឿន, និង ចាន់ ខន ។ ការគ្រប់គ្រងនៅមន្ទីរម-១៣ មានការប្រយ័ត្នប្រយែងបំផុត ដោយមានរបងឫស្សីកិន និងឈើក្រាក់យ៉ាងខ្ពស់ (៥ ទៅ ៦ ម៉ែត្រ) សង់ព័ទ្ធជុំវិញ ។ ក្នុងនោះមានផ្ទះលើសពីបួនសម្រាប់ជាទីស្នាក់អាស្រ័យរបស់កម្មាភិបាលដឹកនាំ, កន្លែងសួរចម្លើយ និងមន្ទីរមួយទៀតសម្រាប់កងការពារស្នាក់នៅ។ ដំបូងអ្នកទោសភាគច្រើនគឺជាទាហាន និងប្រជាជនមូលដ្ឋានដែលមិនដើរតាមមាគ៌ារបស់បក្ស។ រណ្តៅជាច្រើនមានទំហំ ៤ ម៉ែត្រការ៉េ ជម្រៅ ៥ ទៅ ៦ ម៉ែត្រ ដែលមានបង្គោលក្រាក់មួយចំកណ្តាល ត្រូវបានជីកសម្រាប់ឃុំឃាំង និងការធ្វើទារុណកម្មអ្នកទោស។ អ្នកទោសត្រូវបានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ រហូតដល់ស្លាប់ប្រសិនបើផ្តល់ចម្លើយមិនត្រឹមត្រូវតាមអ្វីដែលអ្នកសួរចង់បាន។ ឧបករណ៍ដែលប្រើសម្រាប់ការសួរចម្លើយរួមមាន៖ ម្ជុល, ច្រវាក់, ញញួរ, បន្ទាត់, និងដង្កាប់ ។ វិធីធ្វើទារុណកម្មរួមមានការចងដៃជាប់នឹងបង្គោល ទាញជើងឱ្យហើបពីដី, វាយបញ្ចូលម្ជុលទៅក្នុងក្រចកដៃ, ប្រើកាំបិតចាក់លើរាងកាយ, វាយញញួរឈើលើទ្រូង និងខ្នង, និងបញ្ច្រកទឹកសាប៊ូចូលពោះដោយប្រើទុយោ។ ឌុច ជាមនុស្សកាចជាងគេក្នុងការសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោស។

អ្នកទោសដែលនៅសេសសល់ពីការសម្លាប់ និងអ្នកទោសថ្មី ត្រូវបានបង្ខំឱ្យធ្វើការងារជារៀងរាល់ថ្ងៃទាំងជាប់ច្រវាក់ និងចំណង ក្រោមការមើលការខុសត្រូវយ៉ាងម៉ឺងម៉ាត់ពីកងការពារ ។ កងការពារមានសិទ្ធិបាញ់សម្លាប់អ្នកទោសនៅពេលព្យាយាមលួចរត់។ អ្នកទោសមួយភាគបានស្លាប់ដោយសារការបាក់កម្លាំង និងគ្មានរបបអាហារគ្រប់គ្រាន់ ។ ការងារអ្នកទោសមានលើកទំនប់, ដាំដំឡូង, កាប់ឆ្ការព្រៃ, និងរានដីធ្វើស្រែ។ របបអាហាររបស់អ្នកទោសពឹងផ្អែកទាំងស្រុងលើការចាត់ចែងរបស់កម្មាភិបាលកាន់កាប់រោងបាយ។ អ្នកទោសម្នាក់ទទួលបានបបរាវមួយបំពង់ឫស្សីតូចប៉ុណ្ណោះក្នុងមួយពេល។ របបអាហាររបស់កងការពារវិញ គឺបាយមួយចានលាយជាមួយដំឡូងមី និងពោត។ របបអាហាររបស់ថ្នាក់កម្មាភិបាលគឺបាយគ្រប់ពេល និងម្ហូបគ្រាន់បើ។

## ២) សារមន្ទីរទួលស្លែង (មន្ទីរ ស-២១)

មន្ទីរ ស-២១ បច្ចុប្បន្នស្ថិតនៅខណ្ឌបឹងកេងកង រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលសន្តិសុខសំខាន់បំផុតក្នុងរបបខ្មែរក្រហម។ គោលបំណងរបស់មន្ទីរ ស-២១ គឺឃុំ និងធ្វើទារុណកម្មអ្នកទោសដើម្បីយកចម្លើយសារភាព បន្ទាប់មកអ្នកទោសនឹងត្រូវសម្លាប់ ហើយចម្លើយសារភាព ត្រូវបានបញ្ជូនទៅឱ្យថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។



ឌុច (រូបខាងស្តាំដៃបង្អស់) អតីតប្រធានមន្ទីរសន្តិសុខស-២១ (ប៊ុគុកទួលស្លែង) ដើរពិនិត្យមើលកម្មាភិបាលខ្មែរក្រហមដែលបម្រើការងារនៅមន្ទីរសន្តិសុខស-២១ ពេលកំពុងហូបអាហារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានចាប់ខ្លួនអ្នកទោសប្រមាណជាង ១៥,០០០ ទៅ២០,០០០នាក់ ពីទូទាំងប្រទេសមកឃុំឃាំងនៅមន្ទីរ ស-២១ ក្នុងចំណោមនោះក៏មានសមាជិកនៃចលនាខ្មែរក្រហមដែលជាប់ចោទពីបទក្បត់បដិវត្តន៍, មេដឹកនាំនយោបាយ, កម្មាភិបាលភូមិភាគបូព៌ា, ពាយ័ព្យ, ជនជាតិបរទេស និងបុគ្គលិកស៊ីវិល និងកងទ័ពវៀតណាមជាដើម។ អ្នកទោសមួយចំនួនតូចត្រូវបានខ្មែរក្រហមដោះលែងក្រោយចាប់មកឃុំឃាំងនៅមន្ទីរ ស-២១ ហើយក្នុងចំណោមនោះមានជនរងគ្រោះតែ១២នាក់តែប៉ុណ្ណោះដែលមានជីវិតនៅពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានរំដោះទីក្រុងភ្នំពេញ។ ក្នុងចំណោមជនរងគ្រោះ១២នាក់ មានកុមារ៤នាក់។

បុគ្គលិកមន្ទីរ ស-២១តែងតែវាយអ្នកទោសជាប់ឃុំជាទៀងទាត់។ ដោយដាក់អ្នកឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ដូចគ្នានឹងបុរសដែរនោះ ស្ត្រី និងកុមារក៏ត្រូវបានសួរចម្លើយ វាយដំ ធ្វើបាបដោយយង់ឃ្នង ធ្វើទារុណកម្ម និងសម្លាប់។ ការចាប់ខ្លួន និងការប្រហារជីវិតស្ត្រីជាភរិយា និងកុមារ ត្រូវបានធ្វើឡើងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថា «ជីកស្មៅ ត្រូវជីកទាំងឫស»។

មន្ទីរ ស-២១ គឺជាអង្គភាពរដ្ឋបាលមានការរៀបចំកម្រិតខ្ពស់ បានរក្សាការកត់ត្រាដោយលម្អិតនូវ បញ្ជីអ្នកទោសចូល និងរូបថតរបស់អ្នកទោស។ នៅពេលអ្នកទោសមកដល់ ក៏មានសៀវភៅកំណត់អំពីការប្រើទារុណកម្ម, បញ្ជីឈ្មោះអ្នកដែលត្រូវកម្ទេច និងឯកសារដទៃទៀតស្តីពីការឃុំឃាំងអ្នកទោស។ ចំនួនអ្នកជាប់ឃុំក្នុងមន្ទីរ ស-២១ ប្រែប្រួលពីមួយពេលទៅមួយពេល តែចំណុះច្រើនបំផុតគឺប្រមាណ១៥០០នាក់ ក្នុងនោះមានស្ត្រី និងកុមារដែរ។

អ្នកទោសថ្មីនៅមន្ទីរ ស-២១ ត្រូវបានដឹកមកដោយរុំមុខ និងស្ថិតក្រោមកិច្ចការពារដោយអាវុធជា



រឿយៗតែងតែត្រូវបានដឹកតាមរថយន្តធំៗធ្វើដំណើរមកជាច្រើនម៉ោង ពេលខ្លះមកម្តងជាង១០នាក់ក៏មានៗ អ្នកទោសត្រូវបានគេដាក់ខ្នោះជើង, បង្ខំឱ្យដេកលើឥដ្ឋប្រជ្រៀតគ្នាណែនក្នុងបន្ទប់តូច និងបង្អត់បាយៗ អ្នកទោសត្រូវដាក់ឱ្យស្ថិតនៅក្រោមការឃាមកាមដោយអាវុធគ្រប់ពេលវេលា ហើយអង្គការវិន័យត្រូវបង្ខំឱ្យគោរពជាដាច់ខាតៗ អ្នកទោសមិនត្រូវអនុញ្ញាតឱ្យនិយាយរកគ្នា, ហាត់ប្រាណបុលុបលាងខ្លួនប្រាណទេ ហើយអ្នកទោសបានទទួលរងទារុណកម្មដើម្បីបង្ខំទាញយកចម្លើយសារភាពៗ វិធីធ្វើទារុណ-កម្មរួមមាន៖ ការវាយដំនឹងព្រនង់, ខ្សែភ្លើង, វាយនឹងរំពាត់, ខ្សែតី, ឆក់ខ្សែភ្លើង, ដុតនឹងអំពូលភ្លើងអគ្គិសនី, ចាក់ឬដកក្រចកដៃ ក្រចកជើង, ជ្រមុជក្បាលក្នុងធុងទឹក, បញ្ច្រាកក្បាលនឹងថង់ផ្លាស្ទិក ចងព្យួរជើងឡើងលើ និងបង្ខំឱ្យស៊ីលាមក និងផឹកទឹកនោមៗ

កាំង ហ្កេចអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរនេះ និងបានស្លាប់កាលពីឆ្នាំ២០២០បន្ទាប់ពីត្រូវបានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតៗ

## ៣) មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក

អ្នកជាប់ឃុំនៅ មន្ទីរ ស-២១ ភាគច្រើនត្រូវបាន



ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ (ឬគុកទួលស្លែង)ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាំទៅសម្លាប់នៅជើងឯក (បច្ចុប្បន្នជាមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក និងជារមណីយដ្ឋានទេសចរណ៍បែបប្រវត្តិសាស្ត្រ) ដែលស្ថិតនៅភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ចម្ងាយប្រមាណ១៨គីឡូម៉ែត្រភាគខាងត្បូងរាជធានីភ្នំពេញៗ ពេលយប់អ្នកជាប់ឃុំត្រូវបានដឹកពីមន្ទីរ-ស២១ ទៅបឹងជើងឯកដោយរំភ្លែកនិងមានអ្នកទោសចំនួនពី៣០ ទៅ៤០នាក់ ពេលដឹកម្តងៗៗ នៅទីនោះអ្នកទោសត្រូវបានសម្លាប់ដោយមធ្យោបាយផ្សេងៗ រួមទាំងការវាយនឹងដំបងរហូតដល់ស្លាប់ៗ នៅបឹងជើងឯក អ្នកទោសបានស្លាប់ក្នុងពេលធ្វើទារុណកម្ម, គ្មានអាហារបរិភោគ, ជំងឺ និងលក្ខខណ្ឌរស់នៅអមនុស្សធម៌ ព្រមទាំងអ្នកទោសខ្លះបានធ្វើអត្តឃាតៗ ពេលរបបខ្មែរក្រហមដួលរលំ នៅដើមឆ្នាំ១៩៧៩ អ្នកទោសនៅជើងឯកភាគច្រើនត្រូវបានដឹកចេញតាមឡានធំៗដើម្បីយកទៅសម្លាប់ចំណែកអ្នកទោសដែលមានឋានៈខ្ពស់ៗ ត្រូវបានសម្លាប់នៅនឹងកន្លែង ហើយមានអ្នកទោសតិចតួចណាស់ដែលមានជីវិតៗ

យោងតាមទិន្នន័យស្រាវជ្រាវទីតាំងរណ្តៅពិឃាតនៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រក្នុងការស្វែងរក និងគូរផែនទីរណ្តៅសាកសពរួមជាមួយនឹងការចុះទៅស្រាវជ្រាវដល់ទីកន្លែង រហូតមកដល់ពេលនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញវាលពិឃាតចំនួន៣៩០កន្លែង រួមមាន១៩,០០០រណ្តៅ (មជ្ឈមណ្ឌលឯកសារកម្ពុជាឱ្យនិយមន័យទៅលើពាក្យ វាលពិឃាតថា ជារណ្តៅដែលផ្ទុកសាកសពចាប់ពី៤នាក់រហូតដល់ទៅជាង១,០០០នាក់)។ ជាងនេះទៀតមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញទីតាំងគុកចំនួន១៩៧កន្លែង និងទីតាំងបូជនីយដ្ឋានដែលសាងសង់ឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យចំនួន៨១កន្លែង។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍ថា ប្រទេសកម្ពុជា «នៅតែតស៊ូជាមួយនឹងកេរដំណែលដ៏ឈឺចាប់នៃអំពើប្រល័យពូជសាសន៍, ការធ្វើទារុណកម្ម និងអំពើឃោរឃៅទ្រង់ទ្រាយធំ»។ ប៉ុន្តែការដាក់ឈ្មោះទីតាំងទាំងបី[អតីតមន្ទីរឃុំឃាំងម-១៣, សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក] ទៅក្នុងបញ្ជីយូណេស្កូនឹងដើរតួនាទីសំខាន់ក្នុងការអប់រំយុវជនខ្មែរជំនាន់ក្រោយ និងមនុស្សដទៃទៀតទូទាំងពិភពលោក។ លោកមានប្រសាសន៍បន្តថា៖ «ទោះបីជាទីតាំងដែលបានដាក់បញ្ចូលជាកន្លែងធ្លាប់ប្រព្រឹត្តអំពើហិង្សាក៏ដោយ ប៉ុន្តែទីតាំងទាំងនោះក៏អាចនឹងរួមចំណែកព្យាបាលរបួសដែលបានបន្សល់ឡើងកាលពីអតីតកាលដែលនៅមិនទាន់ជាសះស្បើយនៅឡើយ»។





ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ (ប្តុកទួលស្លែង)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកភូមិកោះញ៉ៅ ទទួលបានសេវាសុខភាព និង សង្គម តាមរយៈការធ្វើដំណើរដោយទូកចម្លង សហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស៊ាង ចិន្តា**



*បណ្ណាល័យបណ្តែតទឹក ផែបណ្តែតទឹក និងទូក របស់មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង សម្រាប់បម្រើដល់ការសិក្សារបស់សិស្ស និងការធ្វើដំណើររបស់ប្រជាជនដែលរស់នៅតាមកោះ នៃសហគមន៍អូរស្វាយ ស្ថិតនៅក្នុងឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ អ៊ំប្រុស ភួយ ខាំផែន អាយុ៧៥ឆ្នាំ រស់នៅភូមិកោះញ៉ៅ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង មិនមានទូកសម្រាប់ជិះឆ្លងទៅជួប និងទទួលថ្នាំសម្រាប់អ្នកជំងឺលើសឈាមតាមការណាត់ជួបរបស់គ្រូពេទ្យឡើយ ដូច្នេះគ្រូពេទ្យនៅមណ្ឌលសុខភាព «ព្រះនរោត្តមសីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ» អូរស្វាយ ក៏បានធ្វើការស្នើសុំប្រើប្រាស់សេវាដឹកជញ្ជូនដោយមិនគិតកម្រៃសម្រាប់ការពិនិត្យសុខភាព និងការទទួលបានសេវាសង្គមនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកទូកចម្លងអ៊ំប្រុស ខាំផែនមកដល់ផែរង់ចាំអូរស្វាយ និងជូនគាត់ទៅកាន់មណ្ឌលសុខភាព «ព្រះនរោត្តមសីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ» អូរស្វាយ ដែលគ្រូពេទ្យរង់ចាំទទួលពិនិត្យតាមដានសុខភាពរបស់គាត់ និងបានផ្តល់ថ្នាំបន្ថែមដល់គាត់ដែលមានជំងឺលើសឈាម។ លោក ស៊ីន សុវណ្ណ

ឌីន ប្រធានមណ្ឌលសុខភាព «ព្រះនរោត្តម សីហនុ រាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ» អូរស្វាយ បានលើកឡើងថា «ប្រសិនបើអ្នកជំងឺពន្យារពេលមកបើកថ្នាំបន្ថែមទៀត អ្នកជំងឺអាចប្រឈមបញ្ហាសុខភាពធ្ងន់ធ្ងរជៀសមិនផុតឡើយ»។

បន្ទាប់ពីបានពិនិត្យសុខភាព និងទទួលបានថ្នាំសម្រាប់អ្នកជំងឺលើសឈាមរួចរាល់មក អ៊ំប្រុស ខាំផែន បានចូលទស្សនាអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) និងផែរង់ចាំអូរស្វាយ ដែលជាមជ្ឈមណ្ឌលសហគមន៍របស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ក្នុងអំឡុងពេលទស្សនកិច្ចអ៊ំប្រុស ខាំផែនបានចែករំលែកសាវតារ និងបទពិសោធន៍របស់ខ្លួនក្នុងពេលសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដូចខាងក្រោម ៖



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង ជូនប្រជាជនដែលរស់នៅតាមកោះ ក្នុងសហគមន៍អូរស្វាយ មកទទួលថ្នាំ និងពិនិត្យជំងឺនៅមន្ទីរពេទ្យបង្អែក សម្តេចឪ-សម្តេចម៉ែ បុរីអូរស្វាយសែនជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«ខ្ញុំមានទីកន្លែងកំណើតនៅខេត្តស្ទឹងត្រែង។ ខ្ញុំបានផ្លាស់មករស់នៅភូមិកោះព្នៅ ស្រុកបុរីអូរស្វាយសែនជ័យ នៅឆ្នាំ១៩៧៩ គឺភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ឪពុករបស់ខ្ញុំឈ្មោះ ភួយ និងម្តាយឈ្មោះ ដា។ ខ្ញុំគឺជាកូនប្រុសពៅក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៤នាក់។ កាលពីក្មេង ខ្ញុំរៀនសូត្រនៅសាលាបឋមសិក្សាបន្ទាយខ្មៅ ត្រឹមថ្នាក់ទី១០ ហើយនៅពេលទំនេរ ខ្ញុំក៏ទៅរៀននៅសាលាបាលីក្នុងវត្ត។ ខ្ញុំចេះអាន និងសរសេរបានខ្លះៗ។ ដោយសារតែជីវភាពក្រីក្រ ខ្ញុំបានបោះបង់ការសិក្សាទាំងនៅសាលារដ្ឋ និងសាលាបាលីនៅវត្ត ហើយទៅរស់នៅជាមួយបងប្រុសធ្វើជាទាហាន។ នៅឆ្នាំ១៩៦៨ ខ្ញុំសម្រេចចិត្តចូលធ្វើជាទាហានក្នុងសម័យសង្គមរាស្ត្រនិយម។ នៅពេលនោះ ខ្ញុំមានអាយុទើបតែ១៨ឆ្នាំ។ រហូតដល់ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទើបអង្គភាពរបស់ខ្ញុំដែលមានប្រធានកងពលឈ្មោះ ត្រឹង បានបានផ្លាស់មកក្រោមការគ្រប់គ្រងរបស់ លន់ នល់ វិញ។ នៅចុងឆ្នាំ១៩៧០ អង្គភាពរបស់ខ្ញុំត្រូវបានកងទ័ពខ្មែរក្រហមវាយបណ្តាលឱ្យបាក់ទ័ព។ ខ្ញុំបានរត់គេចខ្លួនទៅដល់ស្រុកមឿងខុង ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ។ ខ្ញុំចេះនិយាយភាសាឡាវ និងបន្តរស់នៅទីនោះ។ ខ្ញុំក៏ឃើញមានទាហានបាក់ទ័ព លន់ នល់ និងប្រជាជនខ្មែរផ្សេងទៀត រត់ចេញពីភូមិចូលទៅដល់ស្រុកមឿងខុងជាបន្តបន្ទាប់ដែរ ដោយសារតែសង្គ្រាម និងការទម្លាក់គ្រាប់របស់ទាហាន លន់ នល់ និងទាហានអាមេរិក។

នៅចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម បានផ្ទុះឡើងកាន់តែខ្លាំងឡើង ហើយកងទ័ពខ្មែរក្រហមបានវាយកាន់កាប់ទីតាំង និងភូមិសាស្ត្រជាបន្តបន្ទាប់។ នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានរំកិលកងទ័ពរបស់ខ្លួនចូលទៅហ៊ុមព័ទ្ធទីក្រុងភ្នំពេញ។ ខ្ញុំ និងទាហានបាក់ទ័ពចំនួន៤ទៅ៥នាក់ រួមទាំង

ប្រជាជនខ្មែរភៀសខ្លួននៅស្រុកមឿងខុង ត្រូវបានប្រមូលផ្តុំ ដើម្បីកេណ្ឌទ័ពសម្រាប់យកទៅទប់ទល់ជាមួយកងទ័ពខ្មែរក្រហមនៅសមរភូមិជាយទីក្រុងភ្នំពេញ។ ខ្ញុំធ្លាប់ឮថា លន់ នល់ គឺជាអ្នកប្រកាសកេណ្ឌទាហានទាំងនេះ។ បន្ទាប់មក ទាហានដែលទើបតែកេណ្ឌបានសរុបចំនួនជិត១០០០នាក់ រួមទាំងរូបខ្ញុំ ត្រូវបានដឹកជញ្ជូនតាមយន្តហោះមកចុះចតនៅព្រលានយន្តហោះពោធិចិនតុង និងបន្តដឹកតាមរថយន្តទៅកាន់សមរភូមិមុខ ត្រៀមវាយទប់ទល់ជាមួយកងទ័ពខ្មែរក្រហម។ ទាហានទាំងអស់ស្ថិតនៅក្នុងកងពលរបស់ឧត្តមសេនីយ៍ ស៊ី សាអាត។ នៅពេលនោះ ខ្ញុំមិនដឹងអំពីភូមិសាស្ត្រដែលខ្ញុំបានឈរជើងនៅពេលនោះទេ ពីព្រោះខ្ញុំគ្រាន់តែឃើញភ្នំ និងទន្លេ ហើយខ្ញុំត្រូវនៅត្រៀមប្រយុទ្ធក្នុងរណ្តៅត្រង់សេ។

បន្ទាប់ពីខ្ញុំឈរជើងនៅសមរភូមិមិនបានប៉ុន្មានថ្ងៃផង ទាហាន លន់ នល់ ទទួលរងបរាជ័យ និងបានរត់ខ្ចាត់ខ្ចាយអស់។ ខ្ញុំ និងទាហានបាក់ទ័ព៤ទៅ៥នាក់ បានរត់ភៀសខ្លួនដោយបានពាក់សម្លៀកបំពាក់ស៊ីវិល ក្នុងដំណើរឆ្ពោះទៅខេត្តបន្ទាយមានជ័យ វិលត្រឡប់ទៅស្រុកមឿងខុង ប្រទេស ឡាវវិញ។ មិនយូរប៉ុន្មាន កងទ័ពខ្មែរក្រហមបានវាយចូលកាន់កាប់ទីក្រុងភ្នំពេញ។ ពេលខ្ញុំធ្វើដំណើរមកកាន់ខេត្តបន្ទាយមានជ័យ, មានអ្នកសួរនាំ ហើយខ្ញុំបានប្រាប់ថា ភ្នំពេញបែកហើយ។ ខ្ញុំ និងគ្នីគ្នា៥នាក់ផ្សេងទៀត បន្តដំណើរអស់រយៈពេលជាច្រើនថ្ងៃទើបទៅដល់ប្រទេស ឡាវ។

នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្ញុំមិនបានរស់នៅក្នុងប្រទេសកម្ពុជានោះទេ ពីព្រោះតែខ្លាចខ្មែរក្រហមសម្លាប់ចោល។ នៅក្នុងរបបខ្មែរក្រហម ប្រជាជន ឡាវ បានប្រាប់ថា កងទ័ពខ្មែរក្រហមធ្លាប់បានបាញ់សម្លាប់ប្រជានេសាទ ឡាវដែលចូលមកនេសាទត្រីនៅកោះស្តៅ ដែលស្ថិតនៅក្បែរព្រំដែនទឹក។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំក៏សម្រេចចិត្តចូលមករស់នៅប្រទេសកំណើតវិញ ហើយបានរៀបការប្រពន្ធដែលជាអ្នករស់នៅលើកោះញ៉ែនេះតែម្តង»។

បន្ទាប់ពីការចែករំលែករឿងរ៉ាវជីវិត និងបទពិសោធន៍ឆ្លងកាត់សង្គ្រាម និងជាជនភៀសខ្លួននៅប្រទេស ឡាវ អ៊ំប្រុស ខាំផែន ក៏បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ចំពោះសុខភាពរបស់គាត់ និងបានស្តាប់អំពីរឿងរ៉ាវរបស់គាត់។ ជាចុងក្រោយ អ៊ំប្រុស ខាំផែន ទទួលបានសៀវភៅព័ត៌មានអំពីការថែទាំសុខភាពដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីអាន។







ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង ជូនប្រជាជនដែលរស់នៅតាមកោះ ក្នុងសហគមន៍អូរស្វាយមកទស្សនកិច្ចនៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ បុរីអូរស្វាយ-សែនជ័យ នៃមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កំពង់លាវ

ជាវ៉ារដ្ឋ រមេត្តា







សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ មកចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការឆ្លើយតបនូវចម្ងល់របស់សិស្សទាក់ទឹងរឿងរ៉ាវប្រវត្តិសាស្ត្រដែលបានកើតឡើងក្នុងរបបខ្មែរក្រហម តាមការស្នើសុំពីគ្រូទទួលបន្ទុកថ្នាក់ទី១១ ផ្នែកប្រវត្តិវិទ្យា នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ សិស្សដែលបានមកចូលរួមវេទិកាថ្នាក់រៀន មានចំនួន៩នាក់ ក្នុងនោះមានស្រីចំនួន៦នាក់។ គោលបំណងរបស់សិស្សមកចូលរួមវេទិកាថ្នាក់រៀននេះ គឺដើម្បីឈ្វេងយល់ និងចង់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ វេទិកាថ្នាក់រៀននេះក៏ជាផ្នែកមួយនៃការចូលរួមទប់ស្កាត់កុំឱ្យកើតមានអំពើប្រល័យពូជសាសន៍នាពេលអនាគតដែរ។

ឆ្លើយតបទៅនឹងគោលបំណងរបស់សិស្សខាងលើ លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងជាគ្រូឧទ្ទេស បានស្នើឱ្យសិស្សានុសិស្សបំពេញនូវកម្រងសំណួរមុនវេទិកាថ្នាក់រៀនចាប់ផ្តើមរយៈពេល១០នាទី ដើម្បីស្ទាបស្ទង់

ចំណេះដឹងដំបូងរបស់សិស្ស។ បន្ទាប់មក លោក ផេង ពង្សរ៉ាស៊ី ពិភាក្សាជាមួយសិស្សានុសិស្ស និងឆ្លើយតបទៅនឹងចម្ងល់របស់សិស្សដែលបានលើកឡើងដូចជា ៖ ការជម្លៀសប្រជាជនចេញពីទីក្រុងដោយកងទ័ពខ្មែរក្រហម ដោយលោកបានលើកយកមូលហេតុសំខាន់ៗចំនួន៣គឺ ខ្លាចអាមេរិកទម្លាក់គ្រាប់បែក, មិនមានស្បៀងអាហារគ្រប់គ្រាន់ដូច្នេះប្រជាជនត្រូវចេញទៅយកស្បៀងដោយខ្លួនឯង និងការបោសសម្អាតទីក្រុង។ ទន្ទឹមនោះ លោក ផេង ពង្សរ៉ាស៊ី លើកយកគោលនយោបាយ ៨ចំណុច និង ផែនការ៤ឆ្នាំ (១៩៧៧-១៩៨០) របស់ខ្មែរក្រហម ដែលបង្កឱ្យប្រជាជនរងការអត់ឃ្លាន និងស្លាប់ជាច្រើន ព្រមទាំងប្រឈមការលំបាកក្រោយរបបខ្មែរក្រហមដួលរលំ។

តមក សិស្សទាំងអស់បានទស្សនាខ្សែភាពយន្តឯកសារ «កុមារកម្ពុជា» ដែលបានបង្ហាញអំពីកុមារក្រោយរបបខ្មែរក្រហមខ្មែរក្រហម។ របបខ្មែរក្រហមធ្វើឱ្យកុមារក្លាយទៅជាក្មេងកំព្រា ធ្វើឱ្យប្រជាជនកម្ពុជាបែកបាក់គ្រួសារ និងបានបន្សល់គ្រាប់មីនពេញផ្ទៃប្រទេស។ បន្ទាប់ពីទស្សនាខ្សែភាពយន្តចប់ លោក ផេង ពង្សរ៉ាស៊ី បានធ្វើការពន្យល់ពាក្យ «និយមន័យអំពើប្រល័យពូជសាសន៍» ដោយផ្តោតលើធាតុផ្សំសំខាន់ៗចំនួន៣គឺ៖ (១)អំពើទាំងឡាយណាដែលរួមបញ្ចូលទាំងការសម្លាប់ ការជម្លៀស ការបំបែកបំបាក់ ការធ្វើទារុណកម្ម និងអំពើដទៃៗទៀត។ (២)ការប្រព្រឹត្តឡើងក្នុងគោលបំណងឬចេតនាគិតទុកជាមុនក្នុងការបំផ្លិចបំផ្លាញ។ និង(៣)ក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ឬសាសនា។

ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សដែលបានមកចូលរួមវេទិកាថ្នាក់រៀនស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ឬប្រវត្តិសាស្ត្ររបបខ្មែរក្រហម៖

**នេព ដានី** ភេទស្រី អាយុ១៥ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យ ហ៊ុន សែនកំពង់លាវ បានរៀបរាប់ថា បន្ទាប់ពីខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនរួច ខ្ញុំទទួលបានចំណេះដឹងច្រើនទាក់ទងនឹងព្រឹត្តិការណ៍របបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានកើតឡើងនៅឆ្នាំ១៩៧៥ ដូចជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ, ការសម្លាប់អ្នកចេះដឹង, ការសម្លាប់អតីតទាហាន លន់ នល់ និងបណ្តេញជនជាតិវៀតណាម ជនជាតិចិនចេញពីប្រទេសកម្ពុជា។ លើសពីនេះទៀត ខ្ញុំបានដឹងច្បាស់ពីទុក្ខលំបាករបស់ប្រជាជន ដែលត្រូវបានខ្មែរក្រហមរំលោភបំពានបំបិទសិទ្ធិសេរីភាព និងត្រូវបានគាបសង្កត់ឱ្យធ្វើការហួសកម្លាំង។ នៅក្នុងរបបនោះ សាសនា ប្រពៃណីទំនៀមទម្លាប់ ទីផ្សារ លុយកាក់ និងទ្រព្យសម្បត្តិឯកជន ត្រូវបានលុបបំបាត់ចោលទាំងស្រុង។ ទាក់ទងនឹងមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលលោកគ្រូបានបង្រៀន ខ្ញុំមានការចាប់អារម្មណ៍ និងចងចាំជាងគេនៅត្រង់ចំណុច ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយមូលហេតុចំនួន៣គឺ៖ អាមេរិកទម្លាក់គ្រាប់បែក, ឱ្យប្រជាជនចេញទៅរកស្បៀងអាហារនៅតាមជនបទ និងបោសសម្អាតទីក្រុង។ ខ្ញុំយល់ថា ការសិក្សារៀនសូត្រពីប្រវត្តិ-សាស្ត្រខ្មែរក្រហម គឺអាចជួយទប់ស្កាត់របបប្រល័យពូជសាសន៍មិនឱ្យកើតឡើងវិញម្តងទៀតបាន។ វេទិកាថ្នាក់រៀន ពិតជាមានសារសំខាន់ណាស់ ព្រោះបានធ្វើឱ្យខ្ញុំ និងមិត្តភក្តិរួមថ្នាក់យល់ដឹងពីព្រឹត្តិការណ៍សំខាន់នានា ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំចង់ដឹងបន្ថែមទៀតទាក់ទងនឹងរបបខ្មែរក្រហម និង ក្រោយរបបខ្មែរក្រហម រួមមាន៖ ១) តើនៅពេលដែលសង្គ្រាម ឬរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ទៅ អ្នកដែលបានធ្វើជាកងទ័ពនៅរបបខ្មែរក្រហម ត្រូវទទួលរងនូវការរើសអើង និង ទទួលរងនូវការស្អប់ខ្ពើមពីប្រជាជនកម្ពុជាដែរឬទេ? ២) នៅពេលដែលកើតមានរបបខ្មែរក្រហម តើសម្តេចតា និង សម្តេចយាយទ្រង់គង់នៅឯណា?

**ផាត លីណា** ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្ស

ថ្នាក់ទី១១ នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ បានលើកឡើងថា បន្ទាប់ពីខ្ញុំបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនរួច ខ្ញុំទទួលបានចំណេះដឹងទាក់ទងនឹងរបបខ្មែរក្រហមដូចជា៖ បានដឹងពីការគ្រប់គ្រង, ដឹងពីតថភាពក្នុងសង្គម, ដឹងពីគុណវិបត្តិ ដឹងពីទុក្ខលំបាកវេទនារបស់ប្រជាជន ដឹងពីគោលនយោបាយរបស់ខ្មែរក្រហម, ដឹងពីការបំបិទសិទ្ធិសេរីភាព និងការជម្លៀសប្រជាជនៗ ចំពោះមេរៀនដែលគ្រូខ្ទេសបានលើកមកធ្វើបទបង្ហាញ ខ្ញុំមានចំណាប់អារម្មណ៍និងចងចាំមេរៀនត្រង់ចំណុច ក្រោយរបបខ្មែរក្រហមបញ្ចប់ បានបន្សល់ទុកនូវក្មេងកំព្រារាប់សែននាក់ គ្រាប់មីនរាប់សែនគ្រាប់ ការបែកបាក់សមាជិកគ្រួសារ និងភាពប្រេះស្រាំនៅក្នុងសង្គមៗ ខ្ញុំយល់ថា ការសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម ពិតជាជួយទប់ស្កាត់កុំឱ្យកើតមានឡើងវិញនៃរបបខ្មែរក្រហមម្តងទៀតៗ ខ្ញុំឃើញរបបខ្មែរក្រហមបានកើតឡើងដោយសារការរើសអើងវណ្ណៈ ពូជសាសន៍ពណ៌សម្បុរ និងការប្រើអំពើហិង្សាជាដើមៗ វេទិកាថ្នាក់រៀននេះមានសារសំខាន់ណាស់សម្រាប់ខ្ញុំ ព្រោះបានបង្ហាញឱ្យមនុស្សជំនាន់ក្រោយបានយល់ដឹងអំពីការគ្រប់គ្រងប្រទេសបែបកុម្មុយនីស្តៗ ប៉ុល ពត បានសម្លាប់ប្រជាជនខ្មែរគ្នាឯងដោយមិនញញើតដៃ និងបង្ហាញពីទុក្ខវេទនារបស់ប្រជាជន ព្រមទាំងការដឹកនាំប្រទេសឱ្យធ្លាក់ដុនដាប ពិបាកនឹងស្តារឡើងវិញៗ ជាចុងក្រោយ ខ្ញុំមានសំណូមពរឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបើកទូលំទូលាយដើម្បីឱ្យអ្នកចង់ដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរក្រហមបានទៅសិក្សាឈ្វេងយល់បន្ថែមៗ

**សំណែល ម៉េងស័រ** ភេទប្រុស អាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យ ហ៊ុនសែនកំពង់លាវ ឱ្យដឹងថា បន្ទាប់ពីខ្ញុំបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនរួច ខ្ញុំទទួលបានចំណេះដឹងទាក់ទងរបបខ្មែរក្រហមបានច្រើន និងច្បាស់ជាងមុន ដូចជា៖ ដឹងពីទុក្ខលំបាករបស់មនុស្សជំនាន់ខ្មែរក្រហមរងនូវការធ្វើទារុណកម្មគ្រប់បែបយ៉ាង និងត្រូវបង្ខំឱ្យធ្វើការងារហួសកម្លាំង ហើយប្រជាជនត្រូវបែកបាក់ពីសាច់ញាតិក្រុមគ្រួសារ និងឪពុកម្តាយៗ ចំពោះមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំមានការចាប់អារម្មណ៍និងចងចាំមេរៀនអំពីការបង្ខិតបង្ខំឱ្យប្រជាជនចេញពីទីក្រុងភ្នំពេញ និងការបង្ខំឱ្យប្រជាជនធ្វើការងារហួសកម្លាំងៗ ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមបានជួយទប់ស្កាត់នូវរបបខ្មែរក្រហមមិនឱ្យកើតឡើងវិញម្តងទៀតៗ ខ្ញុំគិតថា វេទិកាថ្នាក់រៀនមានសារសំខាន់ណាស់ ព្រោះបានបង្រៀនឱ្យសិស្សានុ-សិស្ស និងក្មេងៗជំនាន់ក្រោយ សិក្សាឈ្វេងយល់ និងដឹងពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដែលជារបបប្រល័យពូជសាសន៍កាន់តែច្បាស់ថែមទៀតៗ





សិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ មកចូលរួមវេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំកិច្ចពិភាក្សាអន្តរជំនាន់ រវាងសិស្សានុសិស្ស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

**មឿន ស្រីណុច**



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកចូលរួមវេទិកាពិភាក្សាអន្តរជំនាន់រវាងសិស្ស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានទទួលស្វាគមន៍សិស្សានុ-សិស្សថ្នាក់ទី១០ នៃវិទ្យាល័យហ៊ុនសែនប្រម៉ោយ ចំនួន១១នាក់ មកចូលរួមអានសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម និងស្តាប់ការចែករំលែករឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានអញ្ជើញអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឈ្មោះ ម៉ៅ អ៊ុត ភេទស្រី អាយុ៧៨ឆ្នាំ រស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ មកធ្វើជាវាគ្មិនចែករំលែករឿងរ៉ាវក្នុងអំឡុងពេលសង្គ្រាម ជាពិសេសរឿងរ៉ាវក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្ស។

ជាកិច្ចចាប់ផ្តើម ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើការណែនាំខ្លួន និងធ្វើបទបង្ហាញជាសង្ខេបពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងបេសកកម្មដែលត្រូវបំពេញនាថ្ងៃ

ខាងមុខ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានលើកអំពីគោលបំណងនៃកិច្ចពិភាក្សានៅថ្ងៃនេះមាន រួមមាន៖ ចង់ឱ្យសិស្សានុសិស្សបានសិក្សាស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), សិក្សាពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហម, ការបង្កើតទំនាក់ទំនងល្អរវាងសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

តមក ម៉ៅ អ៊ុត បានធ្វើការចែករំលែកអំពីបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហមទៅកាន់សិស្សានុសិស្សដូចខាងក្រោម៖

«ខ្ញុំឈ្មោះ ម៉ៅ អ៊ុត ភេទស្រី អាយុ៧៨ឆ្នាំ កើតនៅក្នុងភូមិចំការចេកខាងជើង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស (បច្ចុប្បន្នក្រុងពោធិ៍សាត់) ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លុយ និងម្តាយឈ្មោះ ទូច អៃ។ ឪពុកម្តាយខ្ញុំស្លាប់ក្នុងសម័យសង្គមរាស្ត្រនិយម ដោយសារជំងឺ។ ខ្ញុំមានបងប្អូនស្រីចំនួន៣នាក់ ហើយខ្ញុំគឺជាកូនច្បងក្នុងគ្រួសារ។ ប្តីខ្ញុំឈ្មោះ ឈឹម បិត បានស្លាប់ក្នុងរបបខ្មែរក្រហម។ ខ្ញុំមានកូនចំនួន២នាក់ ក្នុងនោះមានស្រីម្នាក់ ប៉ុន្តែបានស្លាប់ក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃខ្ញុំនៅសល់តែកូនប្រុសម្នាក់ ឈ្មោះ ម៉ៅ ជ្រឹង។

កាលពីដើម ឪពុករបស់ខ្ញុំគឺជាមន្ត្រីប៉ូលីសយាមនៅពន្ធធនាគារខេត្តពោធិ៍សាត់។ ចំណែកម្តាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ និងដាំបន្លែបន្តិចបន្តួចយកទៅលក់នៅផ្សារពោធិ៍សាត់។ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាពោធិ៍សាត់ បានត្រឹមថ្នាក់ទី១០ពីសង្គមចាស់។ ខ្ញុំអាចអានអក្សរ និងសរសេរអក្សរបានបន្តិចបន្តួចប៉ុណ្ណោះ។ បន្ទាប់ពីឈប់រៀន ខ្ញុំត្រឡប់ទៅជួយធ្វើការងារនៅផ្ទះ រួមមានឃ្វាលគោ ចិញ្ចឹមជ្រូក និងមើលថែប្អូនស្រី។ បន្តមកទៀត ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនមានជំងឺរហូតបាត់បង់ជីវិត។ បន្ទាប់ពីឪពុកខ្ញុំស្លាប់រយៈពេល៣ខែ ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺបន្តទៀត។ ហេតុនេះ ខ្ញុំត្រូវរ៉ាប់រងកិច្ចការទាំងឡាយនៅក្នុងផ្ទះ និងមើលថែរក្សាប្អូនៗ។

នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានយន្តហោះមកទម្លាក់គ្រាប់បែកនៅភូមិមួយចំនួននៅក្បែរៗភូមិចំការចេកខាងជើង។ សំឡេងយន្តហោះធ្វើឱ្យខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ហើយខ្ញុំបាននាំប្អូនៗរត់ចូលពួនក្នុងលេណដ្ឋានជាមួយសាច់ញាតិ និងអ្នកភូមិចំការចេកខាងជើង។ ក្រោយស្ថានភាពទម្លាក់គ្រាប់បែកស្ងប់ស្ងាត់ទៅវិញ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ឈឹម បិត ដែលមានតួនាទីជាទាហាន លន់ នល់។ បន្ទាប់ពីរៀបការរួច ខ្ញុំប្រកបមុខរបរលក់ផ្លែឈើព្រៃ ដូចជា ផ្លែមាន ផ្លែដកពាយ ផ្លែក្បៀវ និងស្ងោរដំឡូង យកទៅលក់នៅក្នុងសាលាបឋមសិក្សាពោធិ៍សាត់ ដើម្បីចិញ្ចឹមប្អូនស្រីរបស់ខ្ញុំ និងជួយជីវភាពក្នុងគ្រួសារ។ ចំណែកប្តីរបស់ខ្ញុំគឺជាទាហានត្រូវយាមនៅរបងសាលាខេត្តពោធិ៍សាត់។ នៅឆ្នាំ១៩៧៣ ខ្ញុំសម្រាលបានកូនស្រីម្នាក់។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនឱ្យចាកចេញពីភូមិចំការចេកខាងជើងរយៈពេលបីថ្ងៃសិនចាំត្រឡប់មកវិញ។ ហេតុនេះ ខ្ញុំនិងប្អូនស្រីបានរៀបចំសម្លៀកបំពាក់ ម្ហូបអាហារ និងសម្ភារចាំបាច់មួយចំនួនច្រកចូលក្នុងបាវ ព្រមទាំងដឹកគោចេញទៅជាមួយ។ អំឡុងពេលធ្វើដំណើរ អង្គការបានប្រកាសទៀតថា សូមឱ្យប្រជាជនទាំងអស់ធ្វើដំណើរទៅកាន់ស្រុកកំណើតរៀងៗខ្លួន។ ប្តីរបស់ខ្ញុំបានសម្រេចចិត្តនាំក្រុមគ្រួសារធ្វើដំណើរចេញទៅកាន់ស្រុកកំណើតរបស់គាត់នៅភូមិធ្លកឃុំស្បា ស្រុកកណ្តៀងខេត្តពោធិ៍សាត់។ បន្ទាប់មកប្តីរបស់ខ្ញុំ ត្រូវអង្គការចាត់តាំងឱ្យចូលធ្វើការក្នុងកងនេសាទស្រុកកណ្តៀង និងត្រូវចេញទៅនេសាទជារៀងរាល់ថ្ងៃ ដើម្បីយកត្រីមកផ្គត់ផ្គង់ក្នុងសហករណ៍។ ចំណែកខ្ញុំត្រូវសម្រាលកូនទីពីរ។

បន្ទាប់ពីសម្រាលកូនបានមួយសប្តាហ៍ ខ្ញុំបានទទួលដំណឹងថាអង្គការឱ្យអតីតទាហាន លន់ នល់ ទាំងអស់រៀបចំខ្លួនទៅរៀនសូត្របន្ថែម។ ខ្ញុំចាំបានពូម៉ែន អន អតីតទាហាន លន់ នល់ បានស្លៀកពាក់ស្អាតបាតដើរកាត់មុខផ្ទះរបស់ខ្ញុំរួចចូលមកប្រាប់ប្តីខ្ញុំថា «បិត អើយមិនបាច់ទាន់ទៅរៀនទេ ប្រពន្ធឯងកូនខ្ចីនៅមើលថែប្រពន្ធសិនទៅចាំខ្ញុំទៅមុន»។ លុះក្រោយមក ខ្ញុំបានឮអ្នកភូមិនិយាយតៗថា អតីតទាហាន លន់ នល់ ទាំងអស់ដែលត្រូវបញ្ជូនទៅរៀនសូត្រ ត្រូវខ្មែរក្រហមវាយសម្លាប់ចោលនៅទួលពោធិ៍ជ្រៃទាំងអស់។ បន្ទាប់ពីសម្រាលកូនបានរយៈពេល១ខែ អង្គការបានប្រើខ្ញុំឱ្យទៅកិនស្រូវ និងវែងអង្ករ។ ក្នុងមួយថ្ងៃខ្ញុំត្រូវកិនស្រូវដើម្បីវែងយកអង្ករឱ្យបានប្រហែល៣ទៅ៤បាវ ទើបបណ្តាលឱ្យខ្ញុំឈឺទាស់។ ចំណែករបបអាហារខ្ញុំទទួលបានក្នុងមួយថ្ងៃ២ពេល ប៉ុន្តែខ្ញុំហូបមិនបានគ្រប់គ្រាន់ឡើយ។ ហេតុនេះរាល់ពេលប្តីរបស់ខ្ញុំត្រឡប់មកពីនេសាទត្រី គាត់តែងតែលួចយកត្រីមកអាំងនៅពេលយប់ឱ្យខ្ញុំហូបជាមួយបបរដើម្បីមានទឹកដោះបំបៅកូន។ ដោយសារការបរិភោគអាហារមិនបានគ្រប់គ្រាន់បណ្តាលឱ្យកូនស្រីរបស់ខ្ញុំបានស្លាប់ដោយសារអត់ឃ្លាន។

នៅចុងឆ្នាំ១៩៧៥ អង្គការបាននិយាយលួងលោមថា «សោកស្តាយដែលបានយកអ្នកចេះដឹង និងអតីតទាហាន លន់ នល់ មួយចំនួនទៅសម្លាប់ចោល បើទុកអ្នកទាំងនោះឱ្យមានជីវិតរស់នៅ នឹងមានគំនិតល្អក្នុងការអភិវឌ្ឍន៍ បង្កើតបច្ចេកវិទ្យា និងអាចបង្កបង្កើនផលស្រូវបានដោយងាយស្រួល»។ ប៉ុន្តែអង្គការតែងតែស៊ើបអំពីជីវប្រវត្តិរបស់ខ្ញុំស្ទើររៀងរាល់ថ្ងៃ។ ក្រោយមកអង្គការបានជ្រើសរើសប្តីរបស់ខ្ញុំ និងក្រុមកងនេសាទឱ្យទៅរៀនសូត្រដើម្បីមានជំនាញអភិវឌ្ឍន៍ក្នុងភូមិឃុំបន្តទៀត។ រយៈពេលប្រហែលជាបីថ្ងៃក្រោយ ខ្ញុំទទួលដំណឹងថា ប្តីរបស់ខ្ញុំស្លាប់ហើយ»។



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកចូលរួមវេទិកាពិភាក្សាអន្តរជំនាន់រវាងសិស្ស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីស្តាប់ការចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម សិស្សានុសិស្សបានសំណួរមួយចំនួនទៅកាន់ ម៉ៅ អ៊ុត និងបានបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម៖

**ឆ្វច ស្រីនិច** ៖ «ខ្ញុំមានអារម្មណ៍សប្បាយរីករាយដែលបានចូលរួមស្តាប់សាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំបានដឹងថាការរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក៏ដូចជាប្រជាជនគឺមានការលំបាកខ្លាំង ហើយខ្ញុំមានការសោកស្តាយចំពោះសមាជិកគ្រួសាររបស់លោកយាយចំនួន៣នាក់ដែលត្រូវបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ប្តីរបស់យាយត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅរៀនសូត្រ ប៉ុន្តែបែរជាត្រូវយកទៅសម្លាប់ចោលដោយគ្មានក្តីអាណិត។ ខ្ញុំគិតថារបបខ្មែរក្រហមពិតជាសាហាវឃោរឃៅ និងមានភាពផ្តាច់ការខ្លាំងជាទីបំផុត។ ខ្ញុំមិនចង់ឱ្យមានរបបខ្មែរក្រហមនេះទៀតទេ»។

**ហ៊ីង ស្រីនីន** ៖ «ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយដែលបានសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលធ្វើឱ្យខ្ញុំបានយល់ដឹងកាន់តែច្បាស់ពីផលវិបាកទៅលើប្រជាជន ដូចជា អាហារហូបចុកមិនបានគ្រប់គ្រាន់ និងប្រើឱ្យធ្វើការងារហួសកម្លាំង។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈ-មណ្ឌលផ្សះផ្សាវាលវែង ដែលអនុញ្ញាតឱ្យក្រុមនាងខ្ញុំចូលមកស្តាប់រឿងរ៉ាវ និងទុកលំបាករបស់យាយ ម៉ៅ អ៊ុត ដែលជាអ្នករស់រានមានជីវិតពីក្នុងរបបខ្មែរក្រហម»។

**តា ណារីន** ៖ «នាងខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយដែលបានមកសិក្សា និងស្តាប់រឿងរ៉ាវរបស់យាយ ម៉ៅ អ៊ុត ដែលជាអ្នករស់រានមានជីវិតពីក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីស្តាប់រឿងរ៉ាវរបស់យាយ ខ្ញុំពិតជាមានចិត្តអាណិតអាសូរដល់យាយដែលបានបាត់បង់ប្តី ប្អូនស្រី និងកូនជាទីស្រឡាញ់នៅក្នុងរបបខ្មែរក្រហម។ សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំមិនចង់ឱ្យរបបខ្មែរក្រហមកើតឡើងម្តងទៀតទេ ព្រោះរបបខ្មែរក្រហមបានធ្វើឱ្យប្រជាជនជាច្រើនរងទុក្ខវេទនា បែកបាក់គ្រួសារ និងបានសម្លាប់អ្នកមានចំណេះដឹងជាច្រើននាក់»។





សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកចូលរួមវេទិកាពិភាក្សាអន្តរជំនាន់រវាងសិស្ស និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលខេត្ត និងសមាគម អង្គការសង្គមស៊ីវិល ប្រចាំខេត្តកំពង់ចាម

**ទូច វណ្ណេត**






លោក លី ដេវីត និងលោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម ចូលរួមវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលខេត្ត និងសមាគម អង្គការសង្គមស៊ីវិល ប្រចាំខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥ លោក ទូច វណ្ណេត និងលោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចូលរួមក្នុងវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលខេត្ត និងសមាគម អង្គការសង្គមស៊ីវិល ប្រចាំខេត្តកំពង់ចាមក្រោមអធិបតីភាព ឯកឧត្តម ខ្លូត ចិន្តា អភិបាលរងអភិបាលខេត្តកំពង់ចាម ជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម អ៊ុន ចិន្តា អភិបាលនៃគណៈអភិបាលខេត្ត និងមានការចូលរួមពីសំណាក់ មន្ត្រីរាជការរដ្ឋបាលសាលាខេត្ត ក្រុង ស្រុក និងប្រធានតំណាងអង្គការសមាគម ជុំវិញខេត្តកំពង់ចាមសរុបប្រមាណ៨៥រូប។ វេទិកានេះធ្វើឡើងក្នុងគោលបំណង ស្តាប់នូវលទ្ធផលការងារផ្សេងៗ ដែលសមាគម អង្គការសង្គមស៊ីវិលនៅក្នុងខេត្តកំពង់ចាមបានធ្វើនាពេលកន្លងមក និងសំណូមពរក៏ដូចជាបញ្ហាប្រឈមនានាដែលសមាគម អង្គការសង្គមស៊ីវិល បានជួបប្រទះនៅពេលដែលបំពេញការងារ និងជាវេទិកាសម្រាប់បង្កើនទំនាក់ទំនងថែមទៀតរវាងរដ្ឋបាលខេត្ត និងសមាគម អង្គការសង្គមស៊ីវិល ដើម្បីរួមគ្នាក្នុងការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានខេត្តកំពង់ចាម។

ឯកឧត្តម ខ្លូត ចិន្តា មានប្រសាសន៍ក្នុងការបើកវេទិកាពិគ្រោះយោបល់ ពីបញ្ហាប្រឈម និងសួរសុខទុក្ខសំណេះសំណាលជាមួយអភិបាលនៃគណៈអភិបាលក្រុង/ស្រុក ប្រធានមន្ទីរ អង្គភាពជុំវិញ

ខេត្ត និងតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាលប្រចាំខេត្តកំពង់ចាម។ ឯកឧត្តមក៏បានលើកឡើងបញ្ហាជម្លោះព្រំដែន និងបានបញ្ជាក់ថែមដែរថា នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ ខាងមុខនេះ រដ្ឋបាលខេត្ត និងថ្នាក់ដឹកនាំទៅជួបសួរសុខទុក្ខជាមួយកងទ័ពជួរមុខដែលការពារព្រំដែននៅមុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច និងប្រាសាទតាក្របី ដើម្បីយកស្បៀងអាហារជូនកងទ័ព។ បន្ថែមលើនេះទៀត ឯកឧត្តម ខ្លូត ចិន្តា មានប្រសាសន៍ទាក់ទងទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោកដែលបានធ្វើឱ្យសមាគមអង្គការសង្គមស៊ីវិលមានបញ្ហាហិរញ្ញវត្ថុកើតឡើង។ ឯកឧត្តមគណៈអធិបតីក៏បានកោតសរសើរសមាគមអង្គការសង្គមស៊ីវិល ទាំងអស់ដែលបានចូលរួមជាមួយរដ្ឋបាលខេត្តកំពង់ចាមនៅក្នុងការងារសង្គម ព្រឹត្តិការណ៍នានាដែលរដ្ឋបាលខេត្តបានរៀបចំនាពេលកន្លងមក ជាពិសេសក្នុងការអភិវឌ្ឍន៍ខេត្តកំពង់ចាមទាំងមូល។

ជាកិច្ចបន្តលោកប្រធានអន្តរវិស័យមានប្រសាសន៍លើកឡើងពីសកម្មភាពការងារ វឌ្ឍនភាព និងការអនុវត្តរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ លោក លី ដេវីត តំណាងមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តកំពង់ចាម បានលើកឡើងពីសកម្មភាពការងារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តកំពង់ចាម ដូចជា ការរៀបចំកម្មវិធីពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការរៀបចំវេទិកាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការងារមួយចំនួនទៀតទាក់ទងនឹងការអភិវឌ្ឍន៍សហគមន៍ និងការអប់រំក្រៅប្រព័ន្ធ។




វេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលខេត្ត និងសមាគម អង្គការសង្គមស៊ីវិល ប្រចាំខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាស្រាវជ្រាវស្តីពី «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករស់រាន មានជីវិតពីរបបខ្មែរក្រហមដែលជានិគមជនសង្គមរាស្ត្រនិយម»

ស្រេង លីដា







មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែងរៀបចំវេទិកាស្រាវជ្រាវអំពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជានិគមជនសង្គមរាស្ត្រនិយម ដោយមានការចូលរួមពីសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យបុរីអូរស្វាយ សែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង បានរៀបចំវេទិកាស្រាវជ្រាវស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជានិគមជនសង្គមរាស្ត្រនិយម» ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១០ នៃវិទ្យាល័យបុរីអូរស្វាយ សែនជ័យ សរុបចំនួន៣០នាក់ នៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។

គោលបំណងនៃវេទិកាស្រាវជ្រាវ គឺដើម្បីផ្តល់ឱកាសដល់យុវជន-យុវនារីបានបង្កើនចំណេះដឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, ប្រវត្តិសហគមន៍បុរីអូរស្វាយ សែនជ័យ ជាពិសេសយុវជន-យុវនារីជាកត្តាចូលរួមចំណែកដ៏សំខាន់ក្នុងការជួយទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឱ្យកើតមានឡើងនាពេលអនាគត។ ក្នុងវេទិកាស្រាវជ្រាវនេះ រួមបញ្ចូលការទស្សនាពិព័រណ៍ព្រះឆាយាលក្ខណ៍, ការចូលអានសៀវភៅនៅបណ្ណាល័យ, ការធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយលោកតា ស៊ុង សារ៉ាង ជានិគមជនសង្គមរាស្ត្រនិយម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាកិច្ចស្វាគមន៍ចំពោះ យុវជន-យុវនារី បុគ្គលិកប្រចាំការនៅមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង ឈ្មោះ ស្រេង លីដា បានធ្វើបទបង្ហាញអំពីបេសកកម្ម និងការបង្កើតឡើងនូវអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាមជ្ឈមណ្ឌលសហគមន៍មួយរបស់ព្រះរាជបណ្ណាល័យហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មក សិស្សានុសិស្សទាំងអស់បានចូលទស្សនាពិព័រណ៌ព្រះឆាយាល័ក្ខណ៍ និងអានបណ្ដុំសៀវភៅដែលជាព្រះរាជទាន និងជាស្នាព្រះហស្តរបស់ហ្លួងម៉ែ។ តមក លោក ស្រេង លីដា បានដឹកនាំសិស្សានុសិស្សទាំងអស់ ទៅស្វែងយល់អំពីបណ្ណាល័យរបស់អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលសិស្សានុសិស្សទាំងអស់អាចចំណាយពេលវេលាអានសៀវភៅ និងឯកសារជាច្រើនដើម្បីបង្កើនចំណេះដឹងរបស់ខ្លួន។

ជាកិច្ចបន្ទាប់លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្ដើមធ្វើបទបង្ហាញទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម ដោយផ្ដោតលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗមានដូចជា៖ រដ្ឋប្រហារ លន់ នល់ នៅដើមឆ្នាំ១៩៧០, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, ការរស់នៅប្រចាំថ្ងៃ និងការកាប់សម្លាប់ប្រជាជននៅក្នុងរបបខ្មែរក្រហម។ ក្រៅពីនោះ ក៏រំលេចឡើងអំពីស្ថានភាពប្រជាពលរដ្ឋរស់នៅក្នុងភូមិអូរស្វាយក្រោមរបបខ្មែរក្រហម។ មិនខុសពីប្រជាជនរស់នៅកន្លែងផ្សេង ប្រជាជនរស់នៅបុរីអូរស្វាយក៏ទទួលរងការលំបាក និងការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត, ការបង្ខំឱ្យធ្វើការងារជាទម្ងន់, ការបង្អត់អាហារ និងការចាប់យកទៅសម្លាប់។ ខ្មែរក្រហមកំណត់គោលដៅទៅលើក្រុមប្រជាជនដែលត្រូវសម្លាប់ គឺប្រជាជនថ្មីដែលត្រូវបានស្គាល់ជាទូទៅថា «ប្រជាជន១៧ មេសា» និងនិគមជនដែលសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានបញ្ជូនមកតាំងទីលំនៅចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០។ ប្រជាជនទាំងក្រុម២ត្រូវបានខ្មែរក្រហមដាក់គោលដៅស្វែងរក និងចាប់ខ្លួនដើម្បីយកទៅសម្លាប់។ នេះគឺជាហេតុផលដែលបណ្ដាលឱ្យមានការស្លាប់ប្រជាជនថ្មី និងនិគមជនជាច្រើនគ្រួសារក្នុងរបបខ្មែរក្រហម។

ដើម្បីបង្កើនការយល់ដឹងកាន់តែស៊ីជម្រៅថែមទៀត សិស្សានុសិស្សទាំងអស់បានចូលរួមកិច្ចសន្ទនាអន្តរជំនាន់ជាមួយ និគមជនសង្គមរាស្ត្រនិយម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស៊ុង សាវ៉ាង។ ស៊ឹង សាវ៉ាង នៅតែចងចាំអំពីព្រឹត្តិការណ៍នៃការមកដល់ជាលើកដំបូងក្នុងទឹកដីបុរីអូរស្វាយ, ការទៅទទួលព្រះរាជដំណើរសម្តេចព្រះ នរោត្តម សីហនុ ដែលយាងមកសម្ពោធសមិទ្ធផលនៅបុរីអូរស្វាយ, ការរស់នៅឆ្លងកាត់សង្គ្រាម និងបទពិសោធន៍ក្នុងរបបខ្មែរក្រហម។ ខាងក្រោមនេះ គឺជាការរៀបរាប់ និងចែករំលែកទៅកាន់សិស្សានុសិស្សអំពីប្រវត្តិ និងបទពិសោធន៍របស់ ស៊ុង សាវ៉ាង៖

«ជាបឋម ខ្ញុំមានចិត្តសប្បាយរីករាយណាស់ ដែលឃើញក្មួយប្រុសក្មួយស្រីចូលរួមវេទិកាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអាចស្ដាប់អំពីប្រវត្តិសាស្ត្រសហគមន៍បុរីអូរស្វាយ។ ខ្ញុំឈ្មោះ ស៊ឹង សាវ៉ាង អាយុ៧០ឆ្នាំ កើតនៅខេត្តកណ្ដាល ប៉ុន្តែបច្ចុប្បន្នខ្ញុំរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានឪពុកឈ្មោះ សើង ឡាង និងម្ដាយឈ្មោះ យិម កៀង។ ខ្ញុំបានផ្លាស់ទីលំនៅមករស់នៅទីនេះជាមួយឪពុក ដែលជានាយទាហានចូលនិវត្តន៍ ចាប់តាំងពីឆ្នាំ១៩៦៣។ នៅពេលនោះ ខ្ញុំទើបតែមានអាយុ១១ឆ្នាំតែប៉ុណ្ណោះ។ បុរីអូរស្វាយគឺជាតំបន់ហ៊ុមព័ទ្ធទៅដោយព្រៃក្រាស់ៗនៅឡើយ និងមានប្រជាជនមួយចំនួនបានមកតាំងទីលំនៅ។ បញ្ហាប្រឈមក្នុងជីវភាពរស់នៅខ្លាំងជាងគេនោះគឺជំងឺគ្រុនចាញ់ ដែលបានធ្វើឱ្យប្រជាជនបាត់បង់ជីវិតជាច្រើននាក់។ នៅឆ្នាំ១៩៦៤ តំបន់អូរស្វាយចាប់ផ្ដើមមានការអភិវឌ្ឍន៍។ លោក ម៉ៅ សង្សែម បានចល័តកងទ័ពប្រមាណ៥០០នាក់ ដើម្បីមកឈរដើង និងសាងសង់បន្ទាយកងទ័ព ដែលបច្ចុប្បន្ននេះស្ថិតនៅក្នុងបរិវេណវត្តអូរស្វាយ។ គោលបំណងនៃការ

នាំយកទាហានមកឈរជើង និងប្រជាជនមករស់នៅបុរីអូរស្វាយ គឺដើម្បីកិច្ចការងារការពារបូរណភាពទឹកដី ដែលជាប់ជាមួយព្រំដែនប្រទេសជិតខាង និងធ្វើការអភិវឌ្ឍន៍នៅតំបន់ៗ ដោយកិច្ចផ្តួចផ្តើមពីព្រះករុណា កងទ័ព និងប្រជាជនបានពួតដៃគ្នាកសាងសមិទ្ធផលជាច្រើនមានដូចជា ផ្សារសហគមន៍, សួនច្បារ, មន្ទីរពេទ្យ, សាលារៀន, ទីចាត់ការ និងវត្តអារាមជាដើមៗ ពីឆ្នាំ១៩៦៤ ដល់ ឆ្នាំ១៩៦៥ លោក ម៉ៅ សង្ឃេម ក៏បានបង្កើតវង់តន្ត្រីមួយសម្រាប់ការកម្សាន្ត ដែលមានឈ្មោះថា«វង់តន្ត្រីយោធាភិរម្យ» ដែលមានកងសិល្បៈរបស់ទាហាន ធ្វើការសម្តែង និងលេងភ្លេងៗ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គរាជានុញ្ញាតឱ្យប្រជាជនរបស់ព្រះអង្គ ដែលមានបំណងចង់មករស់នៅតំបន់អូរស្វាយ ដោយមិនប្រកាន់និន្នាការ និងវណ្ណៈឡើយៗ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋបានរៀបចំចែកផ្ទះកា ឡុង, ដីស្រែចំនួន៥ហិចតា និងការឧបត្ថម្ភផ្សេងៗទៀតសម្រាប់ប្រជាជនថ្មីដែលស្ម័គ្រចិត្តមករស់នៅបុរីអូរស្វាយៗ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គយាងចុះផ្ទាល់មកកាន់បុរីអូរស្វាយ នៅឆ្នាំ១៩៦៨ ដើម្បីយាងសម្ពោធសមិទ្ធ-ផលនានា និងបានចែកក្រណាត់សមួយដុំ ដែលមានប៉ាក់អក្សរ«សង្គមរាស្ត្រនិយម» ជូនដល់ប្រជានុរាស្ត្រ ដែលជាកូនចៅរបស់ព្រះអង្គៗ បន្ទាប់មក សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គបន្តយាងចុះសួរសុខទុក្ខប្រជាជនរស់នៅអូរស្វាយ និងទតផ្ទះនិគមជនអូរស្វាយៗ

នៅក្នុងអំឡុងពេលសង្គ្រាម១៩៧០-១៩៧៥, បុរីអូរស្វាយត្រូវទទួលរងគ្រោះពីការទម្លាក់គ្រាប់បែកៗ ប្រជាជនរស់នៅបុរីអូរស្វាយមិនអាចរត់គេចខ្លួនចេញពីភូមិបានទេ ដោយហេតុថាតំបន់បុរីអូរស្វាយនៅទីដាច់ស្រយាល និងហ៊ុមព័ទ្ធទៅដោយព្រៃក្រាស់ៗៗ ប្រជាជនបានជីករណ្តៅជាទ្រង់ទ្រាយអក្សរ«អេ» សម្រាប់គេចខ្លួនពីអំបែងគ្រាប់ដែលទាហានអាមេរិកទម្លាក់មកៗ សមិទ្ធផល និងសំណង់នានានៅបុរីអូរស្វាយត្រូវទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរៗ

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែល ២០ឆ្នាំ ខ្មែរក្រហមបានចាត់តាំងខ្ញុំទៅលើកទំនប់អូរននោងៗ ខ្ញុំត្រូវធ្វើការងារជាទម្ងន់ និងទទួលបានរបបអាហារមិនគ្រប់គ្រាន់ៗ ដើម្បីបំពេញការស្រេកឃ្លាន, ខ្ញុំបានលួចជីកមើមពោន, មើមរកា និងមើមក្តួចយកមកហូបៗ នៅថ្ងៃមួយ បងស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ស៊ីង ធីខេន ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ៗ បន្ថែមពីលើនេះទៀត ខ្មែរក្រហមក៏បានធ្វើប្រវត្តិរូបស្វែងរកអ្នកដែលជាប់ពាក់ព័ន្ធពីរបបសង្គមរាស្ត្រនិយម និងរបបលន់ នល់ៗ ខ្ញុំស្ទើរតែត្រូវបានចាប់យកទៅសម្លាប់ ប៉ុន្តែខ្ញុំអាចរួចផុតពីសេចក្តីស្លាប់ នៅពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយរំដោះប្រជាជន និងប្រទេសពីខ្មែរក្រហមៗ យ៉ាងណាក៏ដោយ ខ្ញុំនៅចងចាំបងស្រីរបស់ខ្ញុំ ដែលត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់»ៗ

នៅចុងបញ្ចប់នៃវេទិកាស្រាវជ្រាវ សិស្សានុសិស្សដែលបានចូលរួមបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

**សុខ ស៊ីងហ័ង** ជាសិស្សថ្នាក់ទី១០ នៃវិទ្យាល័យបុរីអូរស្វាយ សែនជ័យ បង្ហាញចំណាប់អារម្មណ៍ថា៖ «វេទិកាស្រាវជ្រាវនៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)



មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែងរៀបចំវេទិកាស្រាវជ្រាវអំពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករានមានជីវិតពីរបបខ្មែរក្រហម ដែលជានិគមជនសង្គមរាស្ត្រនិយម ដោយមានការចូលរួមពីសិស្សចំនួន៣០នាក់ មកពីវិទ្យាបុរីអូរស្វាយសែនជ័យៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គឺពិតជាល្អសម្រាប់ខ្ញុំជាសិស្សានុសិស្សថ្នាក់វិទ្យាល័យ អាចទទួលបានចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា និងប្រវត្តិសាស្ត្រសហគមន៍។ ខ្ញុំធ្លាប់បានស្តាប់រឿងរ៉ាវអំពីរបបខ្មែរក្រហមពីយាយរបស់ខ្ញុំ ឈ្មោះ ស៊ឹម ណារី ដែលបាននិយាយប្រាប់ខ្ញុំថា នៅក្នុងរបបខ្មែរក្រហម មានការសម្លាប់មនុស្សជាច្រើន ហើយប្រជាជនធ្វើអ្វីក៏ខុសដែរ។ ចំណុចល្អមួយក្នុងរបបខ្មែរក្រហម គឺផ្នែកសីលធម៌ ប្រជាជនមិនហ៊ានប្រព្រឹត្តខុសសីលធម៌ឡើយ។ ចំណេះដឹងថ្មី ដែលខ្ញុំទទួលបានក្នុងវេទិកា គឺមានពីរចំណុច៖ ទី១) គឺប្រវត្តិការបង្កើតបុរីអូរស្វាយ ដោយសម្តេចព្រះ នរោត្តម សីហនុ ដែលព្រះអង្គបានកៀរគរ និងប្រមែប្រមូលប្រជាជនដែលជាយោធាចូលនិវត្តន៍ និងប្រជាជនដែលមានជីវភាពក្រីក្រ ឱ្យមករស់នៅទីនេះ ដើម្បីអភិវឌ្ឍន៍សហគមន៍ដាច់ស្រយាល និងការពារបូរណភាពទឹកដីពីការឈ្លានពានប្រទេសជិតខាង។ ទី២) គឺខាងវិស័យសុខាភិបាល ឬការព្យាបាលប្រជាជននៅមូលដ្ឋាន។ ជាចុងក្រោយគឺវាគ្មិនអ៊ំប្រុស សាវ៉ាង ក៏ជួយបញ្ជាក់ផងដែរថា ការព្យាបាល និងការសម្រាលកូន នៅក្នុងរបបខ្មែរក្រហម មិនមានពេទ្យដែលមានជំនាញវិជ្ជាជីវៈ ទើបការព្យាបាល និងការសម្រាលកូនរបស់ស្ត្រីមានផ្ទៃពោះអាចប្រឈមគ្រោះថ្នាក់ខ្ពស់»។

**ទី ថារី** ជាសិស្សថ្នាក់ទី១០ នៃវិទ្យាល័យបុរីអូរស្វាយ សែនជ័យ លើកឡើងថា៖ «ខ្ញុំបានស្តាប់បទបង្ហាញរបស់លោក ស៊ាង ចិន្តា ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្តាប់ការនិយាយចែករំលែកអំពីបទពិសោធន៍របស់ អ៊ំ សាវ៉ាង ដែលជានិគមជនសង្គមរាស្ត្រនិយម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ចំណេះដឹងដែលខ្ញុំទទួលបានមានដូចជា៖ ការបង្កើតឡើងបុរីអូរស្វាយ ដែលផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍តំបន់ដាច់ស្រយាលរបស់សម្តេចព្រះ នរោត្តម សីហនុ និងការការពារបូរណភាពទឹកដី, ផលលំបាកនៃសង្គ្រាមដែលប្រជាជនបុរីអូរស្វាយបានឆ្លងកាត់, ជីវិតប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម និងការកាប់សម្លាប់ប្រជាជន»។



មជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែងរៀបចំវេទិកាស្រាវជ្រាវអំពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់អ្នករានមានជីវិតពីរបបខ្មែរក្រហមដែលជានិគមជនសង្គមរាស្ត្រនិយម ដោយមានការចូលរួមពីសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យបុរីអូរស្វាយ សែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)














# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ដំណើរស្វែងរកប្អូនស្រីដែលបាត់ខ្លួន

អាណា ម៉ា



*សាច់ញាតិរបស់* Quach Chor Sang ( Kuch Chor San *ហៅ* Aunt Muoi )។
*( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )*



*ឪពុកឈ្មោះ ៖* Quach Van Vien (Kouch Bun iam)។
*( បណ្ណសារមជ្ឈមណ្ឌលឯកសារម្ពុជា )*

បន្ទាប់ពីការបែកគ្នារយៈពេល ៥០ឆ្នាំ អ្នកស្រី Quach Chor Sang សង្ឃឹមថានឹងអាចរកឃើញប្អូនស្រីពៅរបស់គាត់ គឺអ្នកស្រី Quach Hue Sang។

ប្រហែលឆ្នាំ១៩៧៤ ក្រុមគ្រួសាររបស់លោកស្រី Quach Chor Sang ( កើត៖ ១៩៥៥ ) រួមមាន៖ឪពុកម្តាយ បងប្អូន៦នាក់ បានបែកគ្នានៅក្នុងប្រទេសកម្ពុជា។

នៅពេលមករស់នៅប្រទេសកម្ពុជា គ្រួសារនេះមានហាងបបរស ឈ្មោះ Cong Doan មានអាសយដ្ឋានផ្ទះលេខ ៥៦ វិថីខកញ៉ា អ៊ិនរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ អ្នកស្រី Quach Duy Sang (ត្រូវជាបងស្រីច្បង) មានហាងស្បែកជើងឈ្មោះ Tan Bata ទល់មុខរោងមហោស្រព My Le Do ( ប្រទេសកម្ពុជា )។

នៅឆ្នាំ១៩៧៥ គ្រួសាររបស់អ្នកស្រី Quach Chor Sang បានផ្លាស់ទៅរស់នៅប្រទេសវៀតណាម។ នៅឆ្នាំ១៩៨១ គ្រួសារមួយដែលត្រូវជាមិត្តភក្តិ Quach Chor Sang បាននិយាយថា នាងបានជួបអ្នកស្រី Quach Hue Sang (ត្រូវជាប្អូនស្រីពៅរបស់អ្នកស្រី Quach Chor Sang ដែលគេស្គាល់ជាទូទៅថា Houi San ឬ Sa Muoi ) នៅអាងហែលទឹក Phu Lam សង្កាត់ទី៦ ទីក្រុងហូជីមិញ។ ៥០ឆ្នាំបានកន្លងផុត



*ម្តាយឈ្មោះ ៖* Quach Hue San (Kuch Houi San)។
*( បណ្ណសារមជ្ឈមណ្ឌលឯកសារម្ពុជា )*

ទៅ គ្រួសារប្រាថ្នាចង់ជួបមុខគ្នាម្តងទៀតៗ ជាពិសេស អ្នកស្រី Quach Chor Sang ចង់ជួបប្អូនស្រីពៅ។

ដូច្នេះ ប្រសិនបើបងប្អូនណាដឹងថាអ្នកស្រី Quach Hue Sang រស់នៅទីណា? សូមទាក់ទងមកក្រុមគ្រួសារអ្នកស្រី Quach Chor Sang តាមរយៈ: លេខទូរសព្ទ ៖ ០៩១៣-៩០៦-៧៨៧ (ឈ្មោះ Luc ត្រូវជាប្អូនថ្លៃរបស់អ្នកស្រី Quach Chor Sang) ឬ លេខទូរសព្ទ៖ ០៨១-៧៨៧-៦០០០ (ឈ្មោះ Long ត្រូវជាកូនប្រុសរបស់អ្នកស្រី Quach Chor Sang)។ ក្រុមគ្រួសារអ្នកស្រី Quach Chor Sang សូមថ្លែងអំណរគុណទុកជាមុន។

**ព័ត៌មានអំពីឪពុកម្តាយ និងបងប្អូនអ្នកស្រី Quach Chor Sang ៖**

ឪពុកឈ្មោះ ៖ Quach Van Vien (ហៅ Kouch Bun Iam)

ម្តាយឈ្មោះ ៖ អ្នកស្រី Tran Hoa Nhung (ហៅ Tan Hoa Yon)

**កូនប្រុស និងកូនស្រី**

- ឈ្មោះ Quach Duy Sang (Kuch Doui San) ត្រូវជាកូនស្រីទី១ក្នុងគ្រួសារ
- ឈ្មោះ Quach Chor Sang ត្រូវជាកូនស្រីទី២ក្នុងគ្រួសារ
- ឈ្មោះ Quach Mien Tin (Kouch Mien Chhe) ត្រូវជាកូនប្រុសទី៣
- Quach Mien Vinh (Kuch Mien Veng) ត្រូវជាកូនប្រុសទី៤ក្នុងគ្រួសារ
- Quach Mien Hung (គួច មៀនហេង) ត្រូវជាកូនប្រុសទី៥ក្នុងគ្រួសារ
- Quach Hue Sang (Kuch Houi San) ត្រូវជាកូនស្រីទី៦ក្នុងគ្រួសារ

**កូនប្រសារ និងចៅ**

- Hua Tran Thoai (Kor Chin Soui) ត្រូវជាប្តីរបស់អ្នកស្រី Quach Duy Sang
- Trinh Thuc Hien (Te Sok Hien) - ត្រូវជាប្រពន្ធរបស់ឈ្មោះ Quach Mien Tin
- Quach Trien Nguyen (Kuch Chin Ngoun) - ត្រូវជាកូនប្រុសរបស់ឈ្មោះ Quach Mien Tin



សាច់ញាតិរបស់ Quach Chor Sang (Kuch Chor San ហៅ Aunt Muoi)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

កងទ័ពថៃទម្លាក់គ្រាប់បែក MK-82 ទម្ងន់ប្រមាណ២៣០គីឡូក្រាម និងផ្លោងគ្រាប់១៥៥មីលីម៉ែត្ររួមជាមួយគ្រាប់បែកចង្កោម កម្ទេចប្រាសាទព្រះវិហារ អំឡុងពេលវាយប្រហារលើទឹកដីកម្ពុជាចន្លោះពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨។

(ប្រភពរូបថត៖ ទូរទស្សន៍អនឡាញ ព័ត៌មានប្រជាជនកម្ពុជា)

រូបក្របក្រោយ៖

ក្របក្រោយ៖ កងទ័ពថៃទម្លាក់គ្រាប់បែក MK-82 ទម្ងន់ប្រមាណ២៣០គីឡូក្រាម និងផ្លោងគ្រាប់១៥៥មីលីម៉ែត្ររួមជាមួយគ្រាប់បែកចង្កោម កម្ទេចប្រាសាទព្រះវិហារ អំឡុងពេលវាយប្រហារលើទឹកដីកម្ពុជាចន្លោះពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨។

(ប្រភពរូបថត៖ ទូរទស្សន៍អនឡាញ ព័ត៌មានប្រជាជនកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 307, July 2025

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.